CrossConnect
MINISTRIES

# សេចក្ដីសន្យារបស់ព្រះជាម្ចាស់

# ព្រះពររបស់យើង

ជែកឃី អ៊ូស

## លោកុប្បត្តិ ១២-២៥

**មេរៀនទី១: ព្រះបន្ទូលសន្យា - លោក អ័ប្រាហាំបានជឿលើព្រះជាម្ចាស់**

**មេរៀនទី២: ការចងសម្ព័ន្ធមេត្រី - យើងនឹងធ្វើជាព្រះរបស់អ្នក**

**មេរៀនទី៣: មានភ្ញៀវមកលេង - តើមានការអ្វីដែលលំបាករហូតព្រះជាម្ចាស់ធ្វើមិនបាន?**

**មេរៀនទី៤: ការទូលអង្វរ - សម្រាប់ប្រយោជន៍សម្រាប់អ្នកទាំង១០**

**មេរៀនទី៥: វិនាសកម្ម - សម្រេកយ៉ាងកងរំពង**

**មេរៀនទី៦: ការថ្វាយយញ្ញបូជា - តើចៀមដែលត្រូវថ្វាយយញ្ញបូជានៅឯណា?**

"...ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត"
ទំនុកដំកើង ១១៩:១១

ផលិតដោយ គ្រឹះស្ថានបោះពុម្ពTENTHPOWERPUBLISHING

www.tenthpowerpublishing.com

រក្សាសិទ្ធិ © ឆ្នាំ២០១៤ ដោយព័ន្ធកិច្ច CrossConnect Ministries

www.crosscm.org

រក្សាសិទ្ធិគ្រប់យ៉ាង។ គ្មានចំណែកណាមួយក្នុងសៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញដោយគ្មានការអនុញ្ញាតិពីអ្នកនិពន្ធ ឡើយ លើកលែងតែអ្នកត្រួតពិនិត្យដែលស្រង់យកអត្ថបទសង្ខេបខ្លះមកពិនិត្យ។ រាល់ការបោះពុម្ពឡើងវិញ ការរក្សាទុកក្នុងប្រព័ន្ធកុំព្យូទ័រ ដោយថតចម្លង ឬតាមមធ្យោបាយណាមួយ ដែលគ្មានការអនុញ្ញាតិពីអ្នកនិពន្ធ គឺសុទ្ធតែត្រូវបានហាមឃាត់។

គ្រប់បទគម្ពីរ ត្រូវបានដកស្រង់ពីព្រះគម្ពីរបរិសុទ្ធ រក្សាសិទ្ធិ© ឆ្នាំ១៩៥៤និង © ឆ្នាំ១៩៦២ ដោយសមាគមព្រះគម្ពីរកម្ពុជា ប្រើប្រាស់ដោយមានការអនុញ្ញាតិ និងរក្សាសិទ្ធគ្រប់យ៉ាង

រចនាទំព័រដោយ Inkwell Creative

# ការចាប់ផ្ដើម

លោកអ្នកកំពុងផ្ដោតនៅលើដំណើរផ្សងប្រេងមួយដែលនឹងជួយជុសខាត់ជីវិតរបស់លោកអ្នក។ ការធ្វើដំណើរនេះគឺមានតែមួយគត់សម្រាប់លោកអ្នក ហើយត្រូវបានកំណត់នៅក្នុងផ្នែកមួយនៃការខិតខំខ្នែងរបស់លោកអ្នក រួមទាំងបំណងប្រាថ្នាចង់រីកលូតលាស់ក្នុងការយល់ដឹងរបស់លោកអ្នកអំពីសៀវភៅមួយដែលត្រូវបានគេហៅថា ព្រះគម្ពីរបរិសុទ្ធ។ ការប្ដេជ្ញាចិត្តក្នុងការសិក្សារបស់លោកអ្នក សន្យាថាលោកអ្នកប្រាកដជាបានចម្រើនក្នុងជីវិតដូចដែលព្រះជាម្ចាស់ទ្រង់មានបន្ទូលមកកាន់លោកអ្នកតាមរយៈព្រះបន្ទូលរបស់ទ្រង់។

ខណៈពេលដែលលោកអ្នកសិក្សា យើងខ្ញុំសូមលើកទឹកចិត្តឲ្យមានសំភារៈប្រើប្រាស់ខ្លះៗដូចជា៖

1. ព្រះគម្ពីរ មេរៀនៈ *សេចក្ដីសន្យារបស់ព្រះជាម្ចាស់ ព្រះពររបស់យើង*
2. ព្រះគម្ពីរបរិសុទ្ធ ((1ÆÜª#6–˚1 ˛˚ß˛#9ˇß¹Ü1#Ì–#7ª ˇ#+Ì Ê#%Ë˛ ˚ˇ) សំគាល់: ប្រសិនបើលោកអ្នកត្រូវព្រះគម្ពីរថ្មី សូមស្វែងរកព្រះគម្ពីរដែលមានៈ
   ក. ខរយោងនៅគ្រប់ទំព័រនិមួយៗ
   ខ. ទំព័រខយោង ជាធម្មតាយើងអាចរកឃើញនៅទំព័រខាងក្រោយនៃព្រះគម្ពីរ
   គ. រួមទាំងមានផែនទីខ្លះៗនៅទំព័រខាងក្រោយនៃព្រះគម្ពីរផងដែរ។
3. ប៊ិច និង ខ្មៅដៃ
4. ក្រដាសកត់ចំណាំ

ជាមួយនឹងលក្ខណ្ឌសំខាន់ៗទាំងបីដូចបានរៀបរាប់ខាងលើ ត្រង់ចំណុចទី ២ លោកអ្នកនឹងត្រូវបានទទួលការផ្ដល់ជូន និង ត្រៀមខ្លួនជាស្រេចក្នុងការរុករកតាមរយៈមេរៀនទាំងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើនេះគឺជាលើកដំបូងក្នុងការស្គាល់ព្រះគម្ពីរ លោកអ្នកអាចនឹងគិតថាគួរតែចាប់ផ្ដើមជាមួយនឹង *ការរុករកនៅក្នុងព្រះគម្ពីរ* វិញ។ ការសិក្សានេះ ត្រូវបានរចនាឡើងនូវឧបករណ៍ជំនួយសម្រាប់ជួយអភិវឌ្ឍន៍ជំនាញលោកអ្នកបន្ថែម នឹងធ្វើទៅជាអ្នកសិក្សាព្រះគម្ពីរដ៏មានទំនុកចិត្តម្នាក់។ *ការរុករកនៅក្នុងព្រះគម្ពីរ* លោកអ្នកអាចទាញយកពីក្នុងគេហទំព័រ www.crosscm.org បាន។ ទោះបីជាយ៉ាងណាក៏ដោយការសិក្សានេះមិនទាមទារឲ្យសិក្សា *សេចក្ដីសន្យារបស់ព្រះ ជាព្រះពររបស់យើង* នោះឡើយ។

ចូរកុំឲ្យមានការស្ទាក់ស្ទើរក្នុងការគូសចំណាំនៅក្នុងព្រះគម្ពីររបស់លោកអ្នកឡើយ ព្រោះនេះគឺជាគម្ពីរសម្រាប់សិក្សា គឺលោកអ្នកអាចគូសចំណាំបែបណាក៏បានតាមចំណូលចិត្ត ទោះបី ជាហាយឡាយ គូស

បន្ទាប់ពីក្រោម ឬ គូសរង្វង់ ឬបែបណាមួយដែលលោកអ្នកចូលចិត្ត! លោកអ្នកអាចនឹងជ្រើសរើសយក ឡែបថប់ ឬ អាយផែត សម្រាប់កត់ត្រា ឬ ថតចម្លងនូវសំនួរសំខាន់ៗ និងកត់ត្រាដំណើរការនៃការសិក្សារបស់លោកអ្នកជាមិនខាន។

សម្ភារៈសិក្សាត្រូវរៀបរាប់ប្រាប់រួចជាស្រេចហើយ ដូច្នេះលោកអ្នកអាចនឹងសិក្សាដោយខ្លួនឯងបាន ជាមួយនឹងការការយល់ព្រមក្នុងការដាក់វិន័យខ្លួនឯងចំពោះការលំបាក់បន្តិចបន្តួចដែលនឹងកើតមាន។ ក្នុងពេលជាមួយគ្នានោះលោកអ្នកនឹងទទួលបានពត៌មានថ្មីៗ ការចែករំលែកថ្មីៗ ក៏ដូចជាសំនួរមួយចំនួនដែលលោកអ្នកនឹងទទួចសួររកចម្លើយ។ ជាការឆ្លើយតបទៅនឹងការប្រមើលមើលនេះ ត្រូវបានលើកទឹកចិត្តយ៉ាងពេញទំហឹង ក្នុងការអញ្ជើញគូរស្វាមីភរិយាមិត្តភ័ក្ររបស់អ្នកដើម្បីចូលរួមសិក្សាជាមួយលោកអ្នក។

លោកអ្នកនឹងជួយនូវភាពសប្បាយរីករាយក្នុងពេលកំពុងសិក្សា ក្នុងដួងចិត្តរបស់លោកអ្នកនឹងទទួលដឹងថាហាក់ដូចជាព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់អ្នកតាមរយៈព្រះបន្ទូលទ្រង់យ៉ាងដូច្នេះដែរ។ សូមឲ្យសាច់ក្នុងព្រះគម្ពីរទាំងនេះ ផ្តល់ឲ្យលោកអ្នកនូវសេចក្តីស្រលាញ់យ៉ាងអស្ចារ្យដែលបានប្រទានមកតាមព្រះយេស៊ូវគ្រីស្ទជាព្រះបុត្រា និង អម្ចាស់សង្គ្រោះ។

# មេរៀនទី ១

# លោក អប្រាហាំ បានជឿលើព្រះអម្ចាស់

## លោកុប្បត្តិ ១២,១៥-១៦ - សេចក្តីសន្យា

---

### មាតិកាសំខាន់ៗក្នុងមេរៀនទី ១

**ទិដ្ឋភាពទូទៅ៖ លោកុប្បត្តិ ១២,១៥-១៦**
**សេចក្តីណែនាំ**
**មេរៀនទី១: លោកុប្បត្តិ ១២,១៥-១៦**

- ការចងសម្ព័ន្ធមេត្រីនៃជីវិតពនេតចរ...............................
- ខ្ញុំនឹង...ខ្ញុំនឹង...ខ្ញុំនឹង................................................
- ការធានាអះអាងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ .................
- បានសុចរិតតាមរយៈសេចក្តីជំនឿ.................................
- នាងហាហ្គា និង អ៊ីស្មាអែល ......................................

# សេចក្ដីណែនាំ

សាច់រឿងទាំងឡាយគឺជាផ្នែកមួយយ៉ាងសំខាន់នៃដំណើរជីវិតរបស់យើង ព្រោះវាគឺជាចំណែកមួយបន្ថែមនៅក្នុងជីវិតរបស់យើងជារៀងរាល់ថ្ងៃ ចំពោះរឿងរ៉ាវនានាដែលបានកើតឡើង។ ជីវិតយើងម្នាក់ៗសុទ្ធសឹងតែមានសាច់រឿងផ្សេងៗពីគ្នា ដែលបាននឹងកំពុងតែវិកល្ធតលាស់ និង អភិវឌ្ឍន៍ជាប្រចាំ។ កាលៈទេសៈដែលបានកើតឡើងក្នុងជីវិតផ្សេងៗពីគ្នា វានឹងធ្វើឲ្យដំណើរជីវិតផ្ទាល់ខ្លួនយើងម្នាក់ៗបានទៅជាអ្វីមួយមានលក្ខណៈពិសេសដែលអ្នកដទៃមិនមានដូចៗ។ តាមរយៈបទពិសោធន៍ និងការប្រស្រ័យទាក់ទងរបស់យើងនិមួយៗ គឺជាជម្រើសសម្រាប់យើងថាតើយើងត្រូវជ្រើសរើសបែបណា។ មានរឿងមួយចំនួនយើងបានដឹងខ្លួនជាមុន ប៉ុន្តែមានរឿងខ្លះៗទៀតគឺមិនបានដឹងជាមុននោះឡើយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏វាគឺជាជម្រើសសម្រាប់ជីវិតរបស់យើងម្នាក់ៗដែរ។

*សេចក្ដីសន្យារបស់ព្រះ ជាព្រះពររបស់យើង* គឺជាសាច់រឿងរបស់លោក អាប់រ៉ាម ដែលព្រះជាម្ចាស់បានប្ដូរឈ្មោះទៅជា អប្រាហាំ (លោកុប្បត្តិ ១៧:៥) ហើយយើងនឹងសិក្សាសាច់រឿងជាច្រើនទៀតដែលនិយាយអំពីដំណើរជីវិតរបស់គាត់។ ដំណើរសាច់រឿងទាំងនោះនឹងបង្ហាញឲ្យយើងយើងអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះជាម្ចាស់ និង អំពីរបៀបដែលព្រះជាម្ចាស់ប្រើគាត់ដើម្បីសម្រេចព្រះបន្ទូលរបស់ទ្រង់ដែលបានសន្យាជាមួយនឹងលោក អដាំ និង នាងអេវ៉ាកាលនៅក្នុងសួនច្បារអេដែននោះ (លោកុប្បត្តិ ៣:១៥)។ តាមរយៈសាច់រឿងនិមួយៗយើងនឹងបានសិក្សាអំពោះ អាប្បកិរិយា និង ចរិតលក្ខណៈរបស់គាត់ ក៏ដូចជាទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះជាម្ចាស់ផងដែរ។ ជាមួយគ្នានោះ យើងនឹងបានសិក្សាអំពីទំនាក់ទំនងក្នុងក្រុមគ្រួសារ ទំនាក់ទំនងជាមួយក្មួនចៅរបស់គាត់ ហើយនឹងប្រត្តិកម្មរបស់ព្រះជាម្ចាស់នៅក្នុងវង្សក្រុមគ្រួសាររបស់គាត់ទៀតផង។ តាមរយៈសាច់រឿងទាំងនោះវានឹងឆ្លុះបញ្ចាំងអំពីជីវិតផ្ទាល់របស់យើងជាមិនខាន ហើយសំនួរសំខាន់ៗមួយចំនួននឹងត្រូវបានចោទសួរក្នុងខណៈពេលយើងកំពុងមើលទៅលើកិច្ចការនានា ដែលព្រះជាម្ចាស់បាននិងកំពុងធ្វើក្នុងចំណោមពួកយើងម្នាក់ៗ។

ខណៈពេលដែលយើងកំពុងឈានចូលទៅដល់ការសិក្សា និង រីករាយជាមួយនឹងសាច់រឿងនៃដំណើរជីវិតរបស់លោក អប្រាហាំ សូមលោកអ្នកយកសៀវភៅកត់ត្រារបស់លោកអ្នកកត់ត្រានូវគំនិត និង បទពិសោធន៍សំខាន់ៗទាំងឡាយដែលបានជួយធ្វើឲ្យលោក អប្រាហាំ បានក្លាយទៅជាមនុស្សម្នាក់ដែលមានពេញដោយសេចក្ដីជំនឿ។ ចូរពិនិត្យឲ្យបានម៉ត់ចត់អំពីព្រះជាម្ចាស់ ដែលទ្រង់បានបើកសម្ដែងអង្គត្រង់តាមរយៈពាក្យពេជ្រ ឃ្លា ព្រយោគ សំខាន់ដែលបញ្ជាក់ថាព្រះអង្គមានសេចក្ដីស្រលាញ់ចំពោះគ្រប់

មនុស្សទាំងអស់។ ហើយចូរសង្កេតមើលអំពីសាច់រឿងនៃដំណើរជីវិតរបស់លោក អប្រាហាំ ថាតើមានវិធីអ្វី ឬ ហេតុផលអ្វីដែលដំណើររឿងរបស់គាត់មានឥទ្ធិពលមកលើជីវិតរបស់លោកអ្នក។

នៅក្នុងមេរៀន *សេចក្ដីសន្យារបស់ព្រះ ជាព្រះពររបស់យើង* គឺជាការសិក្សាប្រមើលមើលពីភាពពិតនៃផ្ទៃរឿង ដោយចំណាយពេលវេលាអានសាច់រឿង រួចសួរនូវសំនួរ។ ចូរសម្លឹងរកមើលអំពីសេចក្ដីពិតដែលព្រះជាម្ចាស់បានបើកសម្ដែងអំពីអង្គទ្រង់ ក្នុងការឆ្លើយតបចំពោះអំពើបាបរបស់មនុស្សដែលទ្រង់បានបង្កើតមក។ បន្ទាប់មកពិចារណាទៅនឹងសាច់រឿងក្នុងបទគម្ពីរទាំងឡាយណាដែលបានប៉ះពាល់ដល់ចិត្ត និង ជីវិតរបស់លោកអ្នក រួចសួរថា "ដូច្នេះបានយ៉ាងដូចម្ដេច"? ឬអាចសួរម្យ៉ាងទៀតថា តើសាច់រឿងនេះមានន័យដូចម្ដេចចំពោះជីវិតរបស់ខ្ញុំ? សំនួរនេះនឹងត្រូវស្រាយបំភ្លឺនៅក្នុងការអនុវត្តន៍ផ្ទាល់ខ្លួន និងផ្សារភ្ជាប់ជីវិតរបស់ខ្ញុំទៅនឹងព្រះជាម្ចាស់ដូចគ្នាទៅនឹងកិច្ចការ ឬ តាមរយៈកិច្ចការដែលទ្រង់បានធ្វើនៅក្នុងជីវិតរបស់លោក អប្រាហាំដែរ។

ឥឡូវនេះដល់ពេលដែលយើងត្រូវចាប់ផ្ដើមចេញដំណើរហើយ! សូមលោកអ្នកបានរីករាយជាមួយនឹងសាច់រឿង រីករាយជាមួយនឹងការសិក្សាទាំងអស់គ្នា! ចូរបើកព្រះគម្ពីររបស់លោកអ្នកទៅ ព្រះគម្ពីរលោកុប្បត្តិ ជំពូក ១១ ចាប់ផ្ដើមត្រង់ខទី ២៧ តទៅ....!

# សេចក្តីណែនាំ

មានភាពច្របូលច្របល់មួយបានកើតឡើងក្នុងរង្វង់ក្រុមគ្រួសាររបស់លោក អប្រាហាំ។ ព្រះបន្ទូលសន្យាបានកន្លងផុតទៅ ១០ ឆ្នាំទៅហើយ លោកស្រីសារ៉ា នៅតែមិនទាន់មានផ្ទៃពោះដដែល។ ចំណែងឯនាង ហាកា បានមានផ្ទៃពោះបង្កើតបានកូនប្រុសមួយឲ្យលោលអប្រាហាំ ឈ្មោះថាអ៊ីស្មាអែល។ លោកស្រី សារ៉ា និង នាង ហាការ នៅតែរួមរស់នៅ ជាមួយគ្នាដដែល។ រយៈពេល ១៣ ឆ្នាំបានកន្លងផុតទៅ ដំណើររឿងរបស់លោក អប្រាហាំនៅតែបន្តទៅមុខទៀតដូច មាននៅក្នុងព្រះគម្ពីរលោកុប្បត្តិ ជំពូក ១៧ រហូតដល់លោក អប្រាហាំមានអាយុ ៩៩ ឆ្នាំ។

## ផ្នែកទី ១

**សេចក្តីណែនាំៈ** ដំណើរពនេតចរចាកចេញពីទឹកដី អ៊ើរស្រុកខាល់ដេ (លោកុប្បត្តិ ១១:៣១) រួចក៏បានមកតាំងទីលំនៅស្រុកកាណាន។ សង្កេតមើលផែនទៅនៅក្នុងព្រះគម្ពីររបស់លោកអ្នក រួចកំណត់ទីតាំងនៃ អ៊ើរ ឈ្ពោះទៅកាន់ភាគពាយព្យចុងខាងជើង នៃឈូងសមុទ្រងពែក្ស។ ទឹកដីនៃស្រុកកាណានប្រហែលជាមិនមែនងាយស្រួលក្នុងការកំណត់សំគាល់នោះទេ។ តំបន់នេះគឺនៅភាគខាងលិចនៃទឹកដី អ៊ើរ ហើយស្រុកកាណាគឺជាតំបន់តូចមួយនៅតាមបណ្តោយផ្នែកខាងលិចនៃវាលខ្សាច់អារ៉ាប់ រួចព័ទមកផ្នែកខាងកើតនៃឆ្នេរសមុទ្រមេឌីទែរ៉ានេ។ យើងនឹងធ្វើការកំណាប់ព្រំប្រទល់នៃទឹកដីកាណាននៅពេលក្រោយតាមរយៈការសិក្សារបស់យើង។ អ្វីដែលសំខាន់សម្រាប់លោកអ្នកក្នុងការសង្កេតមើលលើផែនទី គឺជាផ្ទៃដីលាតសន្ធឹងយ៉ាងធំនៅចន្លោះវាលខ្សាច់អារ៉ាប់ អ៊ើរ និង ស្រុកកាណាន។ ពួកអ្នកពនេចរទាំងនេះត្រូវធ្វើដំណើរចាប់ពីភាគខាងជើងមកតាមបណ្តោយទន្លេ អ៊ីប្រាត ពួកគេត្រូវធ្វើដំណើរដ៏សែនឆ្ងាយដោយមានយកទាំងសត្វចិញ្ចឹមជាច្រើនទៅជាមួយផង ហើយគ្រប់ៗគ្នាត្រូវការទឹកជាចាំបាច់តាមពិតទៅ ការធ្វើដំណើរពីភាគខាងជើងសំដៅឈ្ពោះទៅភាគខាងលិចវាមិនមែនជាដំណើរផ្លូវខ្លីនោះទេ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺត្រូវគិតគូរពីសុខមាលភាពសមាជិកក្រុមគ្រួសារ អ្នកបម្រើ និង សត្វចិញ្ចឹងទាំងអស់។

**ការបង្រៀនៈ** តើពួកគេទាំងអស់នោះគឺជានរណា? នៅខចុងក្រោយមួយចំនួននៃព្រះគម្ពីរលោកុប្បត្តិ ជំពូក ១១ នឹងប្រាប់ថាពួកគេទាំងអស់នោះគឺជានរណា ដោយចាប់ផ្តើមពីខ ២៧ តទៅ "ទាំងនេះគឺជាមនុស្សក្នុងជំនាន់លោក ថេរ៉ា" សូមអានក្នុងខ ២៧-៣២ ឥឡូវនេះចូររំលឹកសារឡើងវិញ។ លោក ថេរ៉ា ត្រូវជា ________________ របស់លោកអប្រាហាំ។ សារ៉ាយត្រូវជា __________ របស់លោកអប្រាហាំ។ មានសាច់រឿងមួយសំខាន់ដែលយើងបានសិក្សាអំពីលោក អាប់រ៉ាម និង លោកស្រីសារ៉ាយគឺពួកគេគ្មាន __________________ ប៉ុន្តែលោកស្រីសារ៉ាយបាន ________។

នេះគឺជាចំណុចសំខាន់មួយឆ្លងតាមការបង្រៀននៃវប្បធម៌បានឲ្យដឹងថា ស្ត្រីអារ (ស្ត្រីដែលគ្មានកូន) គឺជាស្ត្រីមិនគ្រប់លក្ខណៈ ដែលត្រូវទទួលរងការមើលងាយ និង មិនត្រូវបានគេឲ្យតម្លៃដូចស្ត្រីដទៃទៀតនៅក្នុងសហគមទេ តាមធម្មតាស្ត្រីប្រភេទនេះគឺជាបណ្តាសារមួយចំពោះស្វាមីរបស់នាង។

លោក ថេរ៉ា គឺជាមេដឹងនាំនៃកុលសម្ព័ន្ធមួយ ឬពូជពង្សវង្សត្រកូលនៃគ្រួសារមួយ គាត់បានយកលោក អាប់រ៉ាម និង សារ៉ាយទៅជាមួយនឹងគាត់ដែរ។ នៅក្នុងលក្ខ័ណ្ឌនោះដែរ គាត់ក៏បានយកចៅប្រុសរបស់គាត់គឺ _______________ ទៅជាមួយនឹងគាត់ផងដែរ។ ឪពុករបស់លោក ឡុតត្រូវបានស្លាប់នៅមុនពេលពួកគេបានចាកចេញពី អ៊ើរ ម្យ៉ាងដោយសារលោក ឡុត មានជាប់ខ្សែលោហិតក្នុងត្រកូលនោះដែរ ហេតុដូច្នេះហើយ ទើបបានជាលោក ឡុតត្រូវបានធ្វើដំណើរទៅជាមួយជីតារបស់គាត់ ក្នុងកាលដែលពួកគេទាំងអស់គ្នាមកតាំងលំនៅលើទឹកដីស្រុក កាណាន។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលពួគគេបានធ្វើដំណើរមកដល់ ហារ៉ាន ពួកគេ _______________ (លោកុប្បត្តិ ១១:៣១)។ លោក ថេរ៉ា រស់នៅបានអាយុ ______ ឆ្នាំរួចក៏ស្លាប់ទៅពេលគាត់មានអាយុ _______ ឆ្នាំ។ យើងមិនបានដឹងថាតើគាត់រស់នៅបានប៉ុន្មានឆ្នាំនៅលើទឹកដី ហារ៉ាន មុនពេលគាត់បានស្លាប់នោះទេ។ ប៉ុន្តែអ្វីដែលយើងបានដឹងគឺថាគាត់បានមកតាំងទីលំនៅ នៅទីនោះ ហើយគាត់ក៏មិនបានបន្តដំណើរឆ្ពោះទៅកាន់ទឹកដីកាណានដែរ។

ក្នុងព្រះគម្ពីរលោកុប្បត្តិ ជំពូក ១២ គឺជាចំណុចចាប់ផ្តើននៃដំណើររឿងរ៉ាវរបស់លោក អាប់រ៉ាម។ លោក អាប់រ៉ាបក្រោយពីគាត់បានទទួលយក ពួកអ្នកបម្រើ សត្វចិញ្ចឹម និង ទ្រព្យសម្បត្តិដែលជាចំណែករបស់គាត់ តាមការពិតលោក អាប់រ៉ាម គឺជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តមម្នាក់។ មកដល់ត្រឹមនេះ មានរឿងរ៉ាវជាច្រើនទៀតដែលយើងមិនដឹងអំពីលោក អាប់រ៉ាម និង លោកស្រី សារ៉ាយ ប៉ុន្តែ អ្វីដែលយើងបានដឹង គឺថាព្រះជាម្ចាស់បានជ្រើសរើស សាងទំនាក់ទំនងមួយយ៉ាងជិតស្និទ្ធជាមួយនឹងគាត់ដែលធ្វើមានការផ្លាស់ប្តូរប្រត្តិសាស្ត្រជារៀងរហូត។ នៅពេលណាដែលព្រះជាម្ចាស់យាងទៅគង់ក្នុងជីវិតរបស់មនុស្សណាម្នាក់ គឺអ្វីៗគ្រប់បែបយ៉ាងនឹងនៅដដែលទៀតឡើយ។

**កិច្ចការអនុវត្ត:** ចូរអានព្រះគម្ពីរលោកុប្បត្តិ ជំពូក ១២ រួចធ្វើការកត់ចំណាំជាពិសេសចាប់ពីខ ១ ដល់ខ ៩។ ជាការពិតណាស់ គឺនឹងមានឈ្មោះមនុស្ស និង ទីកន្លែងជាច្រើនដែលបានលើកឡើង ដោយផ្តោតទៅចំពោះលោក អាប់រ៉ាម និង លោកស្រី សារ៉ាយ។ លោកអ្នកអាចនឹងជ្រើសរើសក្នុងការកំណត់ចំណាំ ឈ្មោះមនុស្ស និង ឈ្មោះទីកន្លែងផ្សេងៗពីគ្នាដោយកត់ត្រាចូលទៅក្នុងសៀវភៅរបស់លោកអ្នកដើម្បីទុកធ្វើជាឯកសារយោងទៅថ្ងៃក្រោយ។

**លំហាត់:** នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១២:១-៣ ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅកាន់លោកអាប់រ៉ាម ហើយបានបង្ហាញទិសដៅមួយដល់គាត់។ ក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្ដោតសំខាន់ គឺព្រះអង្គបាន បានមានព្រះបន្ទូលថា បើអ្នកធ្វើកិច្ចការនេះ យើងនឹងធ្វើកិច្ចការនោះ។ ព្រះជាម្ចាស់បានត្រាស់ហៅលោក អាប់រ៉ាម ដើម្បីចូលរួមក្នុងព្រះរាជកិច្ចរបស់ទ្រង់ដើម្បីសង្គ្រោះមនុស្សលោកឲ្យរួចផុតពីអំពើបាបដែលនាំឲ្យពួកគេស្លាប់រហូតអស់កល្ប។ ***សំគាល់:*** *ចូរចងចាំថា សមរភូមិគឺជាកំហឹងដែលមាននៅក្នុងចិត្តរបស់មនុស្សគ្រប់ៗរូប។ សមរភូមិរវាងព្រះជាម្ចាស់ជាមួយនឹងសាតាំង សមរភូមិរវាងការអាក្រក់ជាមួយនឹងការល្អ។* មកដល់ពេលនេះ ព្រះជាម្ចាស់បានជ្រើសរើសដើម្បីផែនការណ៍របស់ទ្រង់បានសម្រេចដូចដែលទ្រង់បានសន្យានៅក្នុងសួនច្បារអេដែន (លោកុប្បត្តិ ៣:១៥)។ នៅក្នុងដំណើររឿងនេះមានលក្ខណៈពិសេសនៅត្រង់ថាតាមរយៈលោក អាប់រ៉ាម ព្រះជាម្ចាស់បានធ្វើឲ្យមានជាទាយាទនៃខ្សែលោហិតកំណើតព្រះយេស៊ូវ គឺជាជើងឯងរបស់ទ្រង់ និង គឺជាតួអង្គព្រះសង្គ្រោះ។

1. នៅក្នុងខគម្ពីរនេះតើលោក អាប់រ៉ាបបានធ្វើអ្វីខ្លះ? ____________________ សម្រាប់ប្រទេសជាតិរបស់លោកអ្នក សម្រាប់សាច់ញាត្តិ ក្រុមគ្រួសាររបស់លោកអ្នក ហើយបន្តទៅ ________________________ ខ្ញុំនឹងបង្ហាញដល់អ្នក។
2. ពេលនេះចូរចាត់ទុកថារូបលោកអ្នកគឺជាលោក អាប់រ៉ាម ដែលត្រូវបានព្រះជាម្ចាស់ត្រាស់ គឺត្រូវឃ្លាតចេញពីអ្វីដែលខ្លួនមាន ហើយត្រូវធ្វើដំណើរឈ្ពោះទៅទីកន្លែងមួយដែលមិនបានដឹងនៅឡើយ។ ព្រះជាម្ចាស់ប្រហែលជាមានព្រះបន្ទូលថា "ចូរចេញទៅ! បញ្ហាផ្សេងៗដទៃទៀតយើងទុកឲ្យយើងទទួលខុសត្រូវ"។ ចំពោះរូបខ្ញុំប្រហែលជានឹងឆ្លើយតបវិញថា "ល្អណាស់"! ចូរសញ្ជឹងគិតអំពីការឆ្លើយតមរបស់លោកអ្នកផ្ទាល់ ______________________

   ______________________________________________________
3. តើលោកអ្នកនឹងត្រូវការពត៌មានបន្ថែមអំពីដំណើរនោះដែរឬទេ? គឺប្រហែលជាលោកអ្នកបានកាត់ត្រារួចជាស្រេចអំពីការធ្វើដំណើរដ៏ស្រពិចស្រពិលមួយមិនខាន។ ម្យ៉ាងទៀតលោកអ្នកអាចជាមនុស្សដែលត្រូវការស្គាល់ស្ថានភាពផ្លូវឲ្យបានច្បាស់ និង ពេលវេលាយូរប៉ុណ្ណាដែលត្រូវទៅដល់គោលដៅទៀតផងមើល៎ទៅ។ ចំណែកខ្ញុំវិញប្រាកដជានិយាយថា "បានហើយ! អាប់រ៉ាម ចូរអ្នកចេញដំណើរទៅ ពេលណាអ្នកទៅដល់ ខ្ញុំនឹងទៅតាមក្រោយ"។ ចូរចំណាយពេលវេលាខ្លះដើម្បីកាត់ត្រានូវអ្វីដែលចាំបាច់មួយចំនួនដែលលោកអ្នកត្រូវការ បើសិនជាព្រះជាម្ចាស់ទ្រង់មានព្រះបន្ទូលមកកាន់លោកអ្នកថា "ចូរចេញទៅ..." ______________

   ______________________________________________________

## ផ្នែកទី ២

**លំហាត់:** លោក អាប់រ៉ាម ត្រូវបានចាកចេញ ហើយធ្វើដំណើរទៅ! គឺផ្នែកទី២នៃព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ចំពោះលោក អាប់រ៉ាប។ សេចក្តីសន្យាទាំងឡាយត្រូវបានចាប់ផ្តើមដោយ "_ ____________________" ព្រះជាម្ចាស់ជាអ្នកប្រទានសេចក្តីសន្យាទាំងអស់។ តាមពិតតើទ្រង់បានសន្យាអ្វីខ្លះ? ក្នុង១២: "យើងនឹង ____________________________" ហើយយើងនឹង __________________________ រីឯចំណែកឯងវិញ _____________ និង ____________________________________________________________" ក្នុង១៣: "យើងនឹង _________________________________________________ ហើយនឹង _________________________________________ យើងនឹង ______________ ______________________________ ដល់ឯងទាំងអស់ ___________________ __________________________ នៅលើផែនដីនឹងបានជា ____________________

## ការបង្រៀន:

1. សេចក្តីសន្យាទីមួយដែលព្រះជាម្ចាស់បានសន្យានឹងលោក អាប់រ៉ាម គឺថា ព្រះអង្គធ្វើកូនចៅរបស់គាត់ទៅប្រជាជាតិមួយដ៏ធំ នេះគឺជាព្រះបន្ទូលសន្យាអំពីកូនចៅពូជពង្ស។ ប៉ុន្តែ ទ្រង់មិនបានមានព្រះបន្ទូលថាលោក អាប់រ៉ាម នឹងមានកូចចៅនោះឡើយ ផ្ទុយទៅវិញទ្រង់មានព្រះបន្ទូលថា "យើងនឹងធ្វើឲ្យអ្នកមាន ___________________________" ចូរអានព្រះគម្ពីរលោកុប្បត្តិ ១១:៣០ សារឡើងវិញម្តងទៀត។ តើមានបញ្ហាអ្វីកើតឡើងចំពោះសេចក្តីសន្យារបស់ព្រះជាម្ចាស់? __________________________
2. ព្រះជាម្ចាស់នៅតែនឹកចាំពីសេចក្តីសន្យារបស់ទ្រង់ ទើបបានជាព្រះអង្គនឹងធ្វើឲ្យលោក អាប់រ៉ាមទៅជា ______________________________ ដ៏ធំមួយ។ តើទ្រង់អាចសម្រេចសេចក្តីសន្យារបស់ទ្រង់ដែរឬទេ? ចូរពិចារណាអំពីសាសនាជាច្រើនដែលបានកើតមាននៅពិភពលោកយើងសព្វថ្ងៃនេះ តើមានសាសនាណាខ្លះដែលមានឫសគល់ចេញពីលោក អប្រាហាំ មក គឺនៅទឹកដីនៃសាសនារបស់ពួកគេបានចាប់ផ្តើមកកើតឡើង? គិតអំពីពួកសាសន៍ យូដា គ្រីស្ទបរិស័ទ ឥស្លាម ជាឧទាហរណ៍ស្រាប់។ ជាការពិតគឺព្រះជាម្ចាស់បានធ្វើលោក អប្រាហាំ ក្លាយទៅជាប្រជាជាតិមួយដ៏ធំពិតប្រាកដមែន។
3. បន្ទាប់មកព្រះជាម្ចាស់បានមានព្រះបន្ទូលទៀតថា ព្រះអង្គនឹងប្រទានពរដល់អ្នកណាដែល បានប្រទានពរដល់លោក អប្រាហាំ ហើយនឹងដាក់បណ្តាសារដល់អ្នកណាដែលបានដាក់ បណ្តាសារដល់គាត់ដែរ។ ព្រះជាម្ចាស់មានព្រះបន្ទូលសង្កត់ធ្ងន់អំពីព្រះពរនេះគឺថា ព្រះអង្គនឹងប្រទានពរ

ដល់លោក អប្រាហាំ ប្រយោជន៏ឲ្យគាត់ប្រទានពរបន្តទៅដល់អ្នកដទៃទៀត។ នៅក្នុង១២ បានប្រាប់យើងថាៈ "យើងនឹង ______________________ ដល់អ្នក" ហើយអ្នកនឹងបានទៅជាព្រះពរដល់មនុស្សគ្រប់ៗគ្នានៅលើផែនដីនេះ។

ព្រះជាម្ចាស់បានត្រាស់ហៅលោក អាប់រាម ដោយបង្គាប់ឲ្យគាត់ចាកចេញពីផ្ទះសំបែង គ្រួសារ សាច់ញាត្តិ និង អ្វីៗគ្រប់យ៉ាងដែលគាត់មានគឺបានបង្គាប់ឲ្យគាត់ *ចេញទៅ* សំដៅឈ្មោះទៅកាន់ទឹកដីមួយកន្លែងដែលទ្រង់នឹងបង្ហាញប្រាប់ដល់គាត់។ ជាមួយគ្នានោះ ព្រះជាម្ចាស់ក៏បានសន្យាចំពោះ អាប់រ៉ាបផងដែរថា ទ្រង់នឹងប្រទានពរយ៉ាងហូរហៀរសម្រាប់គាត់ គឺដើម្បីឲ្យគាត់អាចប្រទានពរដល់អ្នកដទៃបាន។ ហើយលោក អាប់រ៉ាបការបានឆ្លើយតបតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ និង ទទួលយកព្រះបន្ទូលសន្យារបស់ទ្រង់ផងដែរ។ រឿងដែលសំខាន់បំផុតដែលគាត់ត្រូវតែដឹងនោះគឺថា ព្រះជាម្ចាស់បានត្រាស់ហៅរូបគាត់ឲ្យបំរើកិច្ចការរបស់ទ្រង់។

## លំហាត់:

1. តើនរណាដែលជាអ្នកប្រាប់យើងអំពីរឿងរ៉ាវរបស់លោក អាប់រ៉ាម? (១៤) __________
2. តើលោក អាប់រ៉ាមមានអាយុប៉ុន្មានឆ្នាំ? ______________________________
3. តើលោក អាប់រ៉ាមបានយកអ្វីខ្លះ និង នរណាខ្លះទៅជាមួយគាត់? (១៥) ___________

   ______________________________________________________________
4. តើពួកគេបានត្រូវទៅដល់ទឹកន្លែងណា? (១៦) __________________________

**ការឆ្លុះបញ្ចាំងៈ** បើសិនជាលោកស្រី សារ៉ាយ គឺជាស្ត្រីអារ ចំណែកឯ លោក អាប់រ៉ាម មានអាយុ ៧៥ ឆ្នាំទៅ ហើយនៅគ្រានោះព្រះជាម្ចាស់បានត្រាស់ហៅគាត់ ព្រមទាំងបានសន្យាជាមួយលោក អាប់រ៉ាម ថែមទៀតថា ទ្រង់នឹងធ្វើឲ្យតាមរយៈគាត់នឹងបង្កើតបានប្រជាជាតិមួយដ៏ធំ...

1. តើលោកអ្នកគិតថាព្រះជាម្ចាស់ទ្រង់មានព្រះរាជដម្រិះយ៉ាងដូចម្ដេច? ____________
2. តើលោកអ្នកគិតថាលោក អាប់រ៉ាមគិតយ៉ាងដូចម្ដេចដែរ? __________________
3. ចំណែកលោកអ្នកវិញ តើមានគំនិតយ៉ាងដូចម្ដេចដែរ? ចូរធ្វើការស្រមើស្រមៃ ហើយឧបមាថា លោកអ្នកកំពុងតែពាក់ស្បែកជើងរបស់លោក អាប់រ៉ាម ចូរសរសេរអំពីឆ្លុះបញ្ចាំងនៃគំនិតរបស់លោកអ្នកផ្ទាល់ ______________________________________

   ______________________________________________________________

## ការអនុវត្តន៍:

1. តើខ្ញុំត្រូវតែឆ្លើយតបយ៉ាងដូចម្តេចទៅនឹងអ្វីមិនបានដឹងច្បាស់លាស់ ហើយ មើលទៅហាក់ដូចជាមិនអាចទៅរួចដូច្នេះ? ____________________

   ____________________

2. ពិចារណាថា បើសិនជានៅជំនាន់នោះ ព្រះជាម្ចាស់បានធ្វើការក្នុងជីវិតខ្ញុំ តើខ្ញុំមានអារម្មណ៍យ៉ាងណា? ____________________

   ____________________

3. លោក អាប់រ៉ាប បានជឿលើព្រះជាម្ចាស់ ហើយគាត់បានធ្វើអ្វីៗគ្រប់ទៅតាមការដែលគាត់បានដឹងអំពីព្រះជាម្ចាស់។ ចុះលោកអ្នកវិញ តើបានដឹងអ្វីខ្លះអំពីទ្រង់ដែរ? តើលោកអ្នកដឹងបានថាបានឆ្លើយតាមទៅតាមអ្វីដែលលោកអ្នកបានដឹងអំពីព្រះជាម្ចាស់ដោយរបៀបណា? ____

   ____________________

   ____________________

**សេចក្តីអធិស្ឋាន:** ព្រះអម្ចាស់អើយ! លោក អាប់រ៉ាម បានឆ្លើយតាមនឹងព្រះអង្គ ហើយស្តាប់បង្គាប់គឺទៅ តាមអ្វីដែលគាត់បានដឹងអំពីទ្រង់ ហើយគាត់បានសុខចិត្តធ្វើដំណើរឈ្ពោះទៅកាន់ទឹកដីមួយដែលទ្រង់នឹងបង្ហាញប្រាប់គាត់ ហើយគាត់ក៏បានជឿលើព្រះបន្ទូល និង សេចក្តីសន្យារបស់ព្រះអង្គដែរ។ សូមព្រះអង្គជួយទូលព្រះបង្គំមានសេចក្តីជំនឿ ទុកចិត្តពេញទី ព្រមទាំងធ្វើអ្វីៗទាំងប៉ុន្មានដែលព្រះអង្គបានបង្គាប់មក ទូលព្រះបង្គំនឹង ____________________

____________________

## ផ្នែកទី ៣

**ការណែនាំ:** ក្នុងដំណើរពនេតចរដ៏វែងឆ្ងាយ ទីបំផុតពួកយើងក៏បានមកដល់ទឹកដី កាណា។ នៅពេលដែលយើងធ្វើដំណើរចេញពីទិសខាងជើងដំដៅទៅទិសខាងត្បូង ហើយលើទឹកដី នោះក៏មានជនជាតិកាណានរស់នៅទីនោះដែរ (លោកុប្បត្តិ ១២:៦)។ ដូច្នេះ ចូរពិចារណាដល់រូបភាពអំពីលោក អាប់រ៉ាម ត្រូវបានចាកចេញពីអ្វីៗគ្រាប់យ៉ាងដែលគាត់ធ្លាប់មានទៅតាមសេចក្តីសន្យារបស់ព្រះជាម្ចាស់អំពីពូជពង្សរបស់គាត់ និង ព្រះបន្ទូលសន្យាអំពីទឹកដីសន្យា។ បើតាមការសង្កេតមើលពីរូបភាពធំនេះ ឃើញថាលោក អាប់រ៉ាម និង គ្នីគ្នារបស់គាត់ទាំងអស់សុទ្ធតែមនុស្សគ្មានសមត្ថភាពក្នុងការវាយដណ្តើមទឹកដី កាណាន ដែលត្រូវបានជនជាតិណាន និង ពួកកុលសម្ព័ន្ធផ្សេងៗទៀតបាននោះទេ? សូមកុំភ្លេចថាលោក អាប់រ៉ាមក៏បាននាំយកភរិយារបស់គាត់ដែលជាស្ត្រីទៅជាមួយនឹងគាត់ផងដែរ ទោះជា

យ៉ាងណាក្តី ព្រះជាម្ចាស់នៅតែមានព្រះបន្ទូលថា "តាមរយៈ**ពូជពង្សកូនចៅ និង ជំណាន់របស់ឯង** យើងនឹងប្រទានឲ្យ**ទឹកដី**មួយកន្លែងដល់ពួកគេ (លោកុប្បត្តិ ២:៧)។ លោកអាប់រ៉ាមត្រូវតែជឿជាក់លើព្រះជាម្ចាស់ ដ្បិតនៅខគម្ពីរដដែលនោះបានប្រាប់ថា "គាត់បានសាងសង់នូវ ____________ ដើម្បីថ្វាយដល់ព្រះជាម្ចាស់" សម្រាប់ធ្វើជាកន្លែងថ្វាយបង្គំ ដោយសារគាត់បានដឹងថា អ្នកដែលបានសន្យា គឺអ្នកនោះហើយដែលត្រូវធ្វើតាមការសន្យា។ លោក អាប់រ៉ាម បានប្រព្រឹត្តតាមអ្នកដែលបានសន្យាជាមួយនឹងគាត់ ជាពិសេសនោះគឺធ្វើតាមអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល មិនមែនធ្វើទៅតាមអ្វីៗដែលគាត់ (អាប់រ៉ាម) បានដឹងនោះទេ ពោលថាពេលនោះ គាត់មានអាយុ ៧៥ ឆ្នាំទៅហើយ នៅជាមួយនឹងលោកស្រី សារ៉ាយ ដែលជាស្ត្រីអារ។ តែទឹកដី កាណានត្រូវគ្រប់គ្រងដោយសាសន៍ដទៃ ដូចជា សាសន៍កាណាន សាសន៍ហេត សាសន៍យេប៊ូស សាសន៍អាម៉ូរី និង សាសន៍ជាច្រើនទៀត។

**កិច្ចការ:** នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក ១២ ដល់ ១៤ យើងបានឃើញថាព្រះជាម្ចាស់បានធ្វើការតាមរយៈជីវិតរបស់លោក អាប់រ៉ាម។ ចំណាំ: ចូរអានព្រះគម្ពីរបីជំពូកនេះ! ចូរសម្លឹងរកមើលអំពីព្រះជាម្ចាស់ចាប់ផ្តើមស្ថាបនាទឹកដីសម្រាប់លោក អាប់រ៉ាម។ បើសិនជាលោកអ្នកមិនបានអាចមេរៀននៅក្នុងពេលនេះទេ ចូរគូសចំណាំទុកសិន លុះត្រឡប់ទៅផ្ទះវិញលោកអ្នកត្រូវអាននូវជំពូកទាំងនេះ។ មិនត្រូវទុកកិច្ចការឲ្យនៅសល់ឡើយ! ត្រូវតែធ្វើឲ្យរួចរាល់ ដ្បិតនៅមានលំហាត់នៅមេរៀនបន្ទាប់ជាច្រើន។

1. ចូរអានព្រះគម្ពីរលោកុប្បត្តិជំពូក ១២:១០-២០ លោក អាប់រ៉ាម និង លោកស្រី សារ៉ាយ បានធ្វើដំណើរទៅកាន់ប្រទេស អេស៊ីព្ទ ដោយព្រោះតែកើតភាពអំណត់អត់ជាខ្លាំងនៅទឹកដីដែលពួកគេរស់នៅ។ យើងឃើញថាលោក អាប់រ៉ាម ពិតជាមានាការព្រួយបារម្ភ និង ភ័យខ្លាចខ្លាំងណាស់ នៅពេលជាមួយគ្នានោះ ព្រះជាម្ចាស់ក៏បានលូកព្រះហត្ថមកការពារពួកគេឲ្យមានសេចក្តីសុខសាន្ត ក្នុង គ្រាដែលពួកបានទៅដល់ទឹកដីសាសន៍ដទៃ។
2. ចូរអានព្រះគម្ពីរលោកុប្បត្តិជំពូក ១៣ នៅក្នុងជំពូកនេះ យើងឃើញអំពីសេចក្តីសប្បុរសរបស់លោក អាប់រ៉ាម ហើយយើងនឹងសិក្សាចរិតលក្ខណៈរបស់លោក ឡុត ដែលជាក្មួយប្រុសរបស់គាត់ផងដែរ ទោះបីជាលោក ឡុត ត្រូវបានទទួលចំណែកដ៏ល្អបំផុតក៏ដោយក្តី ក្នុងគ្រានោះដែរ ព្រះជាម្ចាស់ទ្រង់ ក៏បានយាងមកឯលោក អាប់រ៉ាមជាថ្មីម្តងទៀត។ ព្រះជាម្ចាស់យាងមកម្តងនេះ ទ្រង់បានប្រទាន សេចក្តីសន្យាសារជាថ្មីឡើងវិញជាមួយនឹងលោក អាប់រ៉ាម គឺមានកត់ត្រាទុកយ៉ាងជាក់ច្បាស់នៅក្នុងជំពូក ១៤-១៧។
3. ចូរអានព្រះគម្ពីរលោកុប្បត្តិជំពូក ១៤:៨-១៧ នៅត្រង់ជំពូកនេះ យើងនឹងសិក្សាអំពីសាច់រឿងរបស់លោក ឡុត វិញម្តង។ ក្នុងជំនាន់នោះ មានស្តេចបួនអង្គបានរួមដៃគ្នាដើម្បីធ្វើសង្គ្រាមតទល់ វាយកំចាត់ស្តេចប្រាំអង្គផ្សេងទៀត ស្ថិតនៅក្នុងព្រឹត្តិការណ៍នោះដែរ លោក ឡុត ក៏ត្រូវ

បានគេចាប់ខ្លួន។ ក្រោយពេលដែលលោក អាប់រ៉ាម បានជ្រាបអំពីរឿងនោះ គាត់ក៏បានទៅជួយរំដោះលោក ឡុត ជាក្មួយឲ្យមានសេរីភាពឡើងវិញ។ ព្រះជាម្ចាស់បានជួយឲ្យលោក អាប់រ៉ាមយកជ័យជំនះលើស្តេច កេដូឡោមើ គឺជាស្តេចដែលបានចាប់ខ្លួនលោក ឡុត យកទៅ។ ជាលទ្ធផលក្រោយពីចប់សង្គ្រោះ ស្តេចមួយចំនួនក៏បានចងសម្ព័ន្ធភាពជាមួយ លោក អាប់រ៉ាម ជាហេតុធ្វើឲ្យកិត្តិសព្ទរបស់គាត់បានល្បីល្បាញទីទាំងទឹកដីនោះរហូតតមក។

## លំហាត់:

1. ក្រោយពីលោក អាប់រ៉ាម បានទទួលជ័យជំនះក្នុងសមរភូមិហើយ ព្រះជាម្ចាស់ក៏មានមកឯគាត់ជាថ្មីម្តងទៀតនៅក្នុងការនិមិត្ត។ ចូរអានព្រះគម្ពីរលោកុប្បត្តិជំពូក ១៥:១ តើព្រះបន្ទូលធានាអះអាចរបស់ព្រះជាម្ចាស់ចំពោះលោក អាប់រ៉ាម យ៉ាងដូចម្តេចខ្លះ? ចូរកត់ត្រានូវសេចក្តីសន្យាទាំងនោះ ______________________________________________

   ______________________________________________
2. ដូចធ្លាប់បានដឹងម្តងរួចមកហើយថាលោក អាប់រ៉ាម បានទទួលសេចក្តីសន្យាយ៉ាងគ្រប់គ្រាន់ ហើយពេលនេះគឺតម្រូវឲ្យមានសកម្មភាពត្រឹះខ្លះៗ មានកំណត់សំគាល់ក្នុងខ២ ពេលនោះគាត់បានស្រែកទូលអង្វរទៅកាន់ព្រះជាម្ចាស់ថា "________________________ ព្រះអង្គប្រទានមកទូលបង្គំ ដើម្បីឲ្យទូលបង្គំបន្ត ____________________________?"
3. តើនរណានៅជាប់ខ្សែស្រឡាយក្នុងការគ្រងមរតក (នៅក្នុងខ២)? _____________
4. តើអេលាស៊ើរគឺជានរណា?(ខ៣)? ______________________________
5. ខណៈនោះនៅក្នុងខ ៤ ព្រះជាម្ចាស់ទ្រង់មានព្រះបន្ទូលថា "នេះ ________________នឹងអាចទៅជារបស់អ្នក "________________________ហើយនឹងបានក្លាយទៅជារបស់អ្នក ______________________________________________
6. ព្រះជាម្ចាស់បានទៅដោយធានាអះអាងដល់គាត់ គឺទ្រង់បាននាំលោក អាប់រ៉ាមចេញទីខាងក្រៅរួចទ្រង់មានព្រះបន្ទូលថា "______________________________________ សំដៅទៅឯ ________________ ហើយនឹងចំនួន ______________ បើសិនជាអ្នកអាចរាប់បាន" បន្ទាប់មកព្រះអង្គមានព្រះបន្ទូលទៅគាត់ទៀតថា "____________

   ______________________________________________

   ______________________________________________"

**ខគម្ពីរចងចាំ** លោកុប្បត្តិ ១៥:៦ គឺជាខគម្ពីរមួយដែលលោកអ្នកត្រូវទន្ទេញ វាគឺជាការងាយស្រួលណាស់! បន្ទាប់ពីលោក អាប់រ៉ាម នៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ គាត់បានសួរទៅព្រះអង្គ រួចទ្រង់ក៏មានព្រះបន្ទូលតបទៅគាត់ជាថ្មីម្តងទៀតនូវអ្វីដែលព្រះបានប្រាប់គាត់ការពីដំបូងថា យើងសន្យា យើងប្រាកដជាធ្វើឲ្យបាន។ ខណៈនេះយើងនឹងអាននូវពាក្យពេលទាំងនេះ "[អាប់រ៉ាម] ________________

________________________________________________________________

________________________________________________________________"

គាត់បានជឿ និង ទុកចិត្តនូវអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល និង អ្វីដែលទ្រង់បាននឹងធ្វើ ចូរកត់ត្រា ខគម្ពីរនេះទុកនៅលើក្រដាស់កត់ចំណាំរបស់លោកអ្នករួចទន្ទេញឲ្យបានចងចាំជារៀងរហូតនៅក្នុងចិត្ត និង គំនិតរបស់លោកអ្នក។

## ផ្នែកទី ៤

**ចូលទៅឱ្យកាន់តែជ្រៅថែមទៀតៈ** កំណត់ចំណាំ: មានមនុស្សមួយចំនួន នៅពេលដែលពួកគេបានចូលរួមក្នុងការសិក្សាមួយនេះ គឺពួកគេប្រាកដជាមានបំណងចិត្តចង់អញ្ជើញអ្នកដទៃទៀតឲ្យមកចូលរួមដើម្បីទទួលបានដឹងនូវអ្វីៗដែលមាននៅក្នុងព្រះគម្ពីរទាំងនេះ។ នៅក្នុងផ្នែកនេះ លោកអ្នកប្រាកដជាមានកិច្ចការច្រើនជាងមុនសម្រាប់លោកអ្នក។ ប្រសិនជាលោកអ្នកសម្រេចចិត្តថានៅតែបន្តផ្តោតសំខាន់ទៅលើរឿងរ៉ាវក្នុងព្រះគម្ពីរលោកុប្បត្តិ យើងនឹងបន្តទៅមុខទៀតដោយលំហាត់បន្ទាប់។

1. ទីន្លែងផ្សេងទៀតនៃព្រះគម្ពីរគឺមានអំណះអំណាងនៅក្នុងលោកុប្បត្តិ ១៥:៦។ ចូរមើលខគម្ពីរយោងនៃខ៦ គឺមានពាក្យថា "សុចរិត" និង ការពន្យល់បន្ថែមផ្សេងទៀត។ មានខគម្ពីរយោងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺព្រះគម្ពីររ៉ូម ៤:៣ ហើយបន្តទៅដល់ ១៨-២៥។ ដូចយើងបានប្រាប់រួចហើយអំពីខទាំងនេះថាលោក អាប់រ៉ាម គាត់មិនមានសមត្ថភាពដើម្បីសម្រេចសេចក្តីសន្យានេះបានឡើយ ប៉ុន្តែ សេចក្តីសង្ឃឹមរបស់គាត់គឺនៅលើព្រះជាម្ចាស់ទាំងស្រុង គាត់បានជឿលើព្រះដូចក្នុងខ ២០-២១ បានប្រាប់យើង "ទេ ________________________ ធ្វើឲ្យគាត់ទៅជា ___________________________ នៃព្រះជាម្ចាស់ ប៉ុន្តែគាត់បានចម្រើនខាងឯ ___________________________ ដូចគាត់បានឲ្យ ____________________ ធ្វើអ្វីតាមដែលព្រះជាម្ចាស់បាន ________________________________________"
2. នៅក្នុងខ ២៣-២៤ បាននិយាយអំពីអ្វីដែលបានដាក់ឲ្យលោក អាប់រ៉ាម ហើយក៏ជាកិច្ចការត្រូវបានប្រគល់ឲ្យយើងម្នាក់ៗដែលជាអ្នកជឿលើព្រះជាម្ចាស់ដែរ។ យើងអាចនិយាយម្យ៉ាងទៀតបានថា ព្រះជាម្ចាស់បានឲ្យតម្លៃសេចក្តីសុចរិតដល់យើងជាអ្នកជឿតាមរយៈព្រះយេស៊ូវព្រមទទួលជំនួស និង ត្រូវបានគេភ្ជាប់ទុកជាការជំនុំជំរះសម្រាប់អំពើបាបរបស់យើង ហើយនឹង

សម្រាប់អស់អ្នកណាដែលជឿថាព្រះអង្គមានព្រះជន្មរស់ពីសុគតឡើងវិញ ឥឡូវនេះយើងបានជ្រះស្រឡះចេញពីអំពើបាប! យើងត្រូវបានប្រកាស់ថាជាសុចរិត ហើយយើងក៏មានទំនាក់ទំនងល្អជាមួយព្រះជាម្ចាស់ជាថ្មីឡើងវិញ។ តាមរយៈលិខិតរបស់លោក ប៉ូល ដែលបានសរសេរផ្ញើទៅកាន់ពួកជំនុំនៅទីក្រុងរ៉ូម គឺចង់បញ្ជាក់ឲ្យយើងដឹងថាលោក អាប់រ៉ាម បានរាប់ជាសុចរិតគឺសោយសេចក្តីជំនឿរបស់គាត់ចំពោះព្រះជាម្ចាស់ ហើយយើងទាំងអស់គ្នាក៏ដូច្នោះដែរគឺបានរាប់ជាសុចរិតគឺដោយសារសេចក្តីជំនឿលើព្រះយេស៊ូវ។ បំណុលដែលយើងជំពាក់អំពើបាបទាំងប៉ុន្មានត្រូវបានព្រះជាម្ចាស់បោះត្រាថាបានបង់ថ្លៃសងរួច! "ពេញថ្លៃ"។

**លំហាត់:** ចូរត្រឡប់ទៅព្រះគម្ពីរលោកុប្បត្តិ ១៥:១៨! រក្សាចង្អុលដៃរបស់លោកអ្នកនៅត្រង់ទំព័រនេះរួចបើកទៅមើលផែនទីនៅទំព័រខាងក្រោយនៃព្រះគម្ពីររបស់លោកអ្នក។ លោកអ្នកអាចនឹងត្រូវផែនទីទី២ ឬ ទី៣ ដើម្បីកំណត់ទីតាំង វ៉ាឌី (Wadi) នៃប្រទេស អេស៊ីព្ទ ដែលជាព្រំប្រទល់ផ្នែងខាងត្បូងនៃទឹកដីសន្យាដែលព្រះជាម្ចាស់បានបានប្រគល់ឲ្យលោក អាប់រ៉ាម និង ទន្លេ អ៊ើប្រាត ដែលជាព្រំប្រទល់ផ្នែកខាងជើង។ ចូរចងចាំថាទន្លេ អ៊ើប្រាតគឺជាទន្លេដែលលោក ថេរ៉ាបបានធ្វើដំណើរតាមនោះចាប់តាំងពី អ៊ើរ សំដៅទៅដំបន់ ហារ៉ាន មុនពេលដែលគាត់មកតាំងលំនៅដំបន់នោះ។

## ផ្នែកទី ៥

**លំហាត់:** ចូរអានព្រះគម្ពីរលោកុប្បត្តិជំពូក ១៦ ពីជំពូរថ្មីនេះគឺជាការណែនាំ។ លោក អាប់រ៉ាម និង លោកស្រី សារ៉ាយ បង្ករឲ្យមានបញ្ហាដោយដៃរបស់ពួកគេផ្ទាល់។

1. ខ១លោកស្រី សារ៉ាយគឺជា ____________________ លោក អាប់រ៉ាម។ គាត់គឺជាស្ត្រីអារ!
2. ប៉ុន្តែគាត់មាន __________________ ម្នាក់ នាងមានឈ្មោះថា ________________
3. ខ២តើលោកស្រី សារ៉ាយ មានផែនការណ៍ដូចម្តេចជាមួយនឹងលោក អាប់រ៉ាម? ______

   ______________________________________________________________

   លោកស្រី សារ៉ាយអស់សង្ឃឹម ហើយនាងបានគិតថា នាងនឹងអាចបន្តឲ្យមានគ្រួសារទៅទៀតបានគឺមានតែឲ្យស្ត្រីបម្រើរបស់នាងបង្កើតកូនសម្រាប់នាង។

4. ខ៣-៤ តាំងពីព្រះជាម្ចាស់បានសន្យាជាមួយនឹងលោក អាប់រ៉ាម មកគឺជាង ១០ ឆ្នាំបានកន្លងផុតទៅហើយ ទើបលោកអាប់រ៉ាមបានយល់ស្របតាមគំនិតរបស់ប្រពន្ធគាត់។ លោកស្រី សារ៉ាយបានឲ្យ ________________ សាសន៍ អេស៊ីបទៅលោក អាប់រ៉ាម _____________ លោក អាប់រ៉ាមក៏បាន _________________ជាមួយនឹងនាងហាហ្គា ហើយនាង ក៏បាន

   ______________________________________________________________

5. តើនាងហាហ្គាឆ្លើយតាមបតចំពោះលោកស្រី សារ៉ាយវិញយ៉ាងដូចម្តេច (ខ៩) ________
6. តើលោកស្រីសារ៉ាយបានឆ្លើយតាមចំពោះការប្រព្រឹត្តរបស់នាងហាហ្គាវិញយ៉ាងដូចម្តេច?

____________________________________________

7. តើលោកស្រីសារ៉ាយប្រព្រឹត្តចំពោះនាងហាហ្គាយ៉ាងដូចម្តេច? ________________
8. តើនាងហាហ្គាបានធ្វើអ្វីខ្លះ? (ខ៦) ________________________________
9. តើទេវត្តានៃព្រះជាម្ចាស់រកឃើញនាងហាហ្គានៅឯណា? ____________________
10. សូមលើកទឹកចិត្តលោកអ្នកឲ្យមើលផែនទីជាថ្មីម្តងទៀត។ ទេវត្តានៃព្រះជាម្ចាស់បានរកឃើញនាងហាហ្គានៅវាលរហោស្ថានស៊ើរ។ វាលរហោស្ថានស៊ើរមានទីតាំងនៅ ចន្លោះប្រទេសអេស៊ីប និង ទឹកដីកាណាន (ប្រទេសអ៊ីស្រាអែលសព្វថ្ងៃ)។
11. ខ៨-១២ គឺជាការសន្ទនារបស់ទេវត្តានៃព្រះជាម្ចាស់ជាមួយនឹងនាងហាហ្គា។
   ក. តើទេវត្តាបានសួរនាងហាហ្គាយ៉ាងដូចម្តេច?____________________
   ខ. តើនាងហាហ្គាឆ្លើយតបវិញដូចម្តេច?______________________
   គ. តើនាងហាហ្គាយទទួលការនែនាំដូចម្តេចខ្លះ? ____________________
   ឃ. តើទេវត្តាបានប្រាប់នាងហាហ្គាដូចម្តេចម្តេចទៀត (ខ១០)? ______________

   ____________________________________________

   ង. ក្នុងខ ១១-១២ តើទេវត្តានៃព្រះបានប្រាប់ដូចម្តេចអំពីកូនប្រុសរបស់នាងហាហ្គា?
      ១). នាងនឹងបង្កើតបាន ______________ នាងនឹងហៅឈ្មោះគេថា ____
      ២). អ៊ីស្មាអែល មានន័យថាព្រះ ____________________
      (អាចខយោងខាងក្រោម)
      ៣). ព្រះជាម្ចាស់ស្តាប់នូវការ ________________ របស់អ្នក
      ៤). អ៊ីស្មាអែលនឹងបានទៅជា ____________________
         (១). ______________________________គ្រប់ៗគ្នា
         (២). គ្រប់ៗគ្នា ____________________ជារបស់គាត់
         (៣). គាត់នឹងបាននៅ ________________របស់គាត់ទាំងអស់

         ______________________________
12. នាងហាហ្គាផុញទ្រាន់នឹងកូនប្រុសរបស់លោក អាប់រ៉ាមគឺ ________________។
   តើនៅពេលដែលលោកអាប់រ៉ាមបានកូនប្រុសម្នាក់គាត់មានអាយុប៉ុន្មាន? __________

**ការឆ្លុះបញ្ចាំង:**

1. ក្រោយពីលោកអ្នកបានអានរឿងនេះចប់តើមានគំនិតដូចម្តេច? ________________
____________________________________________
2. តើលោកអ្នកនឹងត្រូវធ្វើយ៉ាងណានៅពេលដែលកូនប្រុសរបស់អ្នកទាស់ទែងគ្នា? ______
____________________________________________

**ការអនុវត្តន៍:** ព្រះជាម្ចាស់បានបង្ហាញការអាណិតអាសូរ និង ភាពក្តួលអាណិតដល់នាងហាហ្កា ទោះបីជានាងទទួលការរើសអើងពីចៅហ្វាយ ហើយទ្រង់បានផ្តល់ផ្លូវល្អសម្រាប់នាង។

1. តើអ្នកនឹងឆ្លើយតបយ៉ាងដូចម្តេចចំពោះនរណាម្នាក់ដែលធ្វើបាបអ្នកឬមិត្តរបស់អ្នក? ___
____________________________________________
2. តើព្រះយេស៊ូវលើកទឹកចិត្តដូចម្តេច? (អានម៉ាថាយ ៥:៤៣-៤៨) ________________
____________________________________________

**សេចក្តីអធិស្ឋាន:** ព្រះជាម្ចាស់អើយ! ជារឿយៗទូលបង្គំខ្វះការអត់ធ្មត់ ហើយបានជ្រើសរើសធ្វើតាមគំនិតរបស់ខ្លួន ជាលទ្ធផលគឺមានតែការឈឺចាប់ប៉ុណ្ណោះ។ សូមទ្រង់បានអត់ទោសដល់ទូលបង្គំ ហើយជួយឲ្យទូលបង្គំបានសម្រាក់យ៉ាងស្ងប់ស្ងាត់ក្នុងព្រះអង្គផង ដើម្បីឲ្យទូលបង្គំបានឆ្លើយតបយ៉ាងសក្តិសមជាអ្នកស្រលាញ់ព្រះអង្គ។ សូមឲ្យសេចក្តីអាណិតមេត្តាករុណារបស់ទ្រង់បានបង្ហូរមកលើទូលបង្គំផងចុះ។ ________________________________________
____________________________________________

## មេរៀនទី ២

# យើងនឹងធ្វើជាព្រះរបស់អ្នក

## លោកុប្បត្តិ ១៧ - ការចងសម្ព័ន្ធមេត្រី

---

## មាតិកាសំខាន់ៗក្នុងមេរៀនទី ២

**ទិដ្ឋភាពទូទៅ៖ លោកុប្បត្តិ ១៧**

**សេចក្តីណែនាំ**

**មេរៀនទី ២: លោកុប្បត្តិ ១៧**


- ការចងសម្ព័ន្ធមេត្រីដ៏នៅអស់កល្បជានិច្ច........................
- ការតស៊ូរបស់លោក អប្រាហាំ.. ...................................
- និយមន័យនៃពាក្យថា "សម្ព័ន្ធមេត្រី" .............................
- ព្រះជាម្ចាស់ប្រទានពរដល់ អ៊ីស្មាអែល ...........................
- ការបណ្តេញនាងហាហ្គា និង អ៊ីស្មាអែល.........................
- ការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ចំពោះ អ៊ីស្មាអែល .................
- រំលឹងសារឡើងវិញ ..................................................

# សេចក្តីណែនាំ

មានភាពចលចលមួយបានកើតឡើងនៅក្នុងជំរុំរបស់លោក អាប់រ៉ាម គឺជាអស់រយៈពេល ១០ ឆ្នាំបានកន្លងផុតទៅបន្ទាប់ពីព្រះជាម្ចាស់បានសន្យាជាមួយគាត់គឺ លោកស្រី សារ៉ាយ នៅតែមិនទាន់មានកូនដដែល។ រីឯនាង ហាហ្គាក៏មានផ្ទៃពោះ ហើយប្រសូត្របានកូនប្រុសម្នាក់ឲ្យលោក អាប់រ៉ាម ឈ្មោះថា អ៊ីស្មាអែល។ ហើយលោកស្រី សារ៉ាយ និង នាងហាហ្គាចេះតែមានរឿងមិនចុះសម្រុងនឹងគ្នា មិនយូរប៉ុន្មាន ១៣ ឆ្នាំបានកន្លងផុតទៅយ៉ាងឆាប់រហ័ស ដំណើររឿងរបស់លោក អាប់រ៉ាម ក៏នៅតែបន្តនៅក្នុងលោកុប្បត្តិជំពូក ១៧ តទៅទៀត រហូតដល់គាត់ឈានចូលដល់អាយុ ៩៩ ឆ្នាំ។

សារជាថ្មីម្តងទៀតព្រះជាម្ចាស់បានលេចមកឯលោក អាប់រ៉ាម តែទ្រង់យាងមកម្តងនេះគឺមកដើម្បីចងសម្ព័ន្ធមេត្រីជាមួយនឹងគាត់ និង កូនចៅដំណរក្រោយៗរបស់គាត់តទៅរហូតអស់កល្បជានិច្ច គឺទ្រង់បានមានព្រះបន្ទូលថា "យើងនឹងធ្វើជាព្រះរបស់អ្នក" គឺជាសម្ព័ន្ធមេត្រីតម្រូវឲ្យធ្វើការកាត់ស្បែករាល់មនុស្សប្រុសទាំងអស់ដែលនៅក្នុងរង្វង់គ្រួសាររបស់គាត់ ហើយពិធីកាត់ស្បែកនេះគឺជាសញ្ញានៃការចងសម្ព័ន្ធមេត្រីរវាងព្រះជាម្ចាស់ជាមួយនឹងលោក អាប់រ៉ាម។

ពិធីនេះក៏ចេះនៅបន្តមកដល់សព្វថ្ងៃ! លោក អាប់រ៉ាម និង លោកស្រី សារ៉ាយនៅតែមិនទាន់មានកូនដដែល! ទោះបីជាយ៉ាងណាក៏ដោយ ព្រះជាម្ចាស់មិនត្រឹមតែបានចងសម្ព័ន្ធមេត្រីជាមួយនឹងគាត់ប៉ុណ្ណោះទេ គឺថែមទាំងបានចងសម្ព័ន្ធមេត្រីជាមួយកូនចៅរបស់គាត់គ្រប់ដំណរទៀតផង ដោយទ្រង់បានប្រកាសថា កូនចៅរបស់គាត់ដំណរក្រោយនឹងបានកើតចំនួនយ៉ាងច្រើនរាប់មិនអស់។ ជាច្រើនឆ្នាំកន្លងទៅនោះលោក អាប់រ៉ាម បានជឿលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដោយឥតសង្ស័យ។ ពេលនេះព្រះអង្គបានប្តូរឈ្មោះរបស់គាត់ពី អាប់រ៉ាម ទៅជា អប្រាហាំ វិញម្តង ដែលមានន័យថាឪពុកនៃមនុស្សជាច្រើន! ហើយក៏បានប្តូរឈ្មោះលោកស្រី សារ៉ាយ ទៅជា សារ៉ា ផងដែរ ដែលមានន័យថាជាម្តាយនៃប្រជាជាតិទាំងឡាយ! តើការនេះនឹងកើតឡើងបានយ៉ាងដូចម្តេច?

ព្រះជាម្ចាស់បានធានាអះអាងចំពោះលោកស្រី សារ៉ា គាត់នឹងមានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយ។ សម្ព័ន្ធមេត្រីនេះនៅតែបន្តរហូត បើដរាបណាគ្មានអ្នកស្នងត្រកូលនៅឡើយ ហើយសម្ព័ន្ធមេត្រីនេះត្រូវបានរាប់បញ្ចូលទាំងកូនចៅដំណរក្រោយៗទៀតផងដែរ។ យើងអាចស្តាប់ឮសំណើចរបស់លោក អប្រាហាំ និង អ្វីដែលគាត់កំពុងគិតថា "ខ្ញុំមានអាយុជិត ១០០ ឆ្នាំ ហើយ ប្រពន្ធខ្ញុំសារ៉ា មានអាយុជិត ៩០ ឆ្នាំទៅហើយតើការនេះកើតឡើងបានយ៉ាងម៉េចទៅ?" ប៉ុន្តែគាត់នៅតែជឿជាក់លើព្រះជាម្ចាស់ដដែល ដូច្នេះហើយទើបបានជាព្រះអង្គបានហៅគាត់ ថាជាអ្នកសុចរិត។

តើលោកអ្នកនឹងអស់សំណើចជាមួយលោក អប្រាហាំ និង លោកស្រី សារ៉ាដែរទេ? ឬ លោកអ្នកប្រហែលជានឹងសើចចំពោះ សេចក្ដីជំនឿល្ងីល្ងើរបស់ពួកគេទាំងពី ដែលបានជឿលើសេចក្ដីសន្យាជាច្រើនឆ្នាំបែបនេះដែរឬទេ? ទោះជាយ៉ាងណាក្ដីព្រះជាម្ចាស់បានសន្យាចំពោះលោក អប្រាហាំ និង កូនចៅជំនាន់ក្រោយៗរបស់គាត់ នៅទីបំផុត អ៊ីសាក់បានកើតមក គឺពិតជាក្ដីអំណរ និង ការអបអរសាទរដ៏ខ្លាំងយ៉ាងណាទៅ! នឹងបានឮគ្រប់ៗគ្នាសើចយ៉ាងក្អាកក្អាយ!

តើត្រូវរង់ចាំដោយសេចក្ដីសង្ឃឹមយ៉ាងដូចម្ដេច បើអ្វីៗគ្រប់យ៉ាងកើតឡើងគ្មានសង្ឃឹមសោះដូច្នេះ? នេះគឺជាសាច់រឿងរបស់លោក អប្រាហាំ និង លោកស្រី សារ៉ា ចុះសាច់រឿងរបស់លោកអ្នកវិញ? តើនៅពេលណាដែលលោកអ្នកសូមអ្វីមួយដែលមិនអាចទៅរួច? តើមានអ្វីដែលធ្វើឲ្យលោកអ្នកនៅតែអាចបន្តរស់នៅទៅទៀតបាន? តើការតស៊ូរបស់លោកអ្នកមានយ៉ាងដូចម្ដេចដែរ? តើលោកអ្នកធ្លាប់អស់សំណើចចំពោះអ្វីដែលខ្លួនឯងមិនជឿដែរឬទេ? តើមានអ្វីខ្លះដែលអ្នកបានទទួលការគាំទ្រ ឬកង្វះខាតពីគ្រួសារ ឬមិត្តរបស់លោកអ្នក? ព្រះជាម្ចាស់នៅតែស្មោះត្រង់ចំពោះលោក អប្រាហាំ នូវអ្វីដែលទ្រង់បានសន្យា និង ការចងសម្ព័ន្ធមេត្រីជាមួយនឹងគាត់ ហើយព្រះអង្គក៏នៅតែស្មោះត្រង់ចំពោះលោកអ្នក និង ខ្ញុំដែរ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏លោក អប្រាហាំ និង លោកស្រី សារ៉ា នៅមិនទាន់ដែលបានឃើញ "ប្រជាជាតិ" ដូចដែលពួកគេបានជឿតាមអ្វីដែលទ្រង់បានមានព្រះបន្ទូលថា "យើងនឹងចងសម្ព័ន្ធមេត្រីរបស់យើងដ៏នៅអស់កល្បជានិច្ចរវាងយើងហើយនឹងអ្នក រួមទាំងកូនចៅដំណរក្រោយៗអ្នកផងដែរ បន្ទាប់ពីអ្នកទៅ នៅជំនាន់ក្រោយមួយទៀតនឹងមកដល់ នឹងបានជាព្រះលើអ្នក"។

## ផ្នែកទី ១

**សេចក្ដីណែនាំ:** ឥឡូវនេះលោក អាប់រ៉ាម មានអាយុ ៩៩ ឆ្នាំហើយ! ព្រះជាម្ចាស់បានមកឯគាត់ម្ដងទៀត គឺមកដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់អំពីសម្ព័ន្ធមេត្រីដែលទ្រង់បានចងជាមួយគាត់កាលពី ២៥ ឆ្នាំមុន។

**កិច្ចការ:** ចូរអានព្រះគម្ពីរលោកុប្បត្តិ ១៧:១-៨

**លំហាត់:** កត់ចំណាំនូវរាល់ព្រះបន្ទូលទាំងប៉ុន្មានដែលព្រះជាម្ចាស់បានបញ្ជាក់លើសម្ព័ន្ធមេត្រីដែលទ្រង់បានចងឡើងជាមួយនឹងលោក អាប់រ៉ាម។

1. ខ២: ព្រះជាម្ចាស់មានព្រះបន្ទូលថាទ្រង់នឹង "______________________ របស់យើង ______________________ រវាងយើងហើយនឹងអ្នក រួមទាំង _____ ______________________ អ្នក ______________ ផងដែរ។

2. ១៣: លោក អាប់រ៉ាម បានអោនមុខចុះដល់ដី ហើយទ្រង់បានប្រកាសអំពីសម្ព័ន្ធមេត្រីរបស់ទ្រង់ថា "យើងធ្វើជា ____________________របស់អ្នក នៃ ________________ ជាច្រើន (១៤)"។
3. ១៥: ព្រះជាម្ចាស់បានប្តូរគាត់ពី អាប់រ៉ាម ទៅជា អប្រាហាំវិញ! **ចំណាំ:** ក្នុងព្រះគម្ពីររបស់លោកអ្នកអាចនឹងមានការកំណត់ចំណាំនៅខាងក្រោមនៃទំព័រ ដែលនឹងប្រាប់លោកអ្នកថាអាប់រ៉ាម មានន័យថា **ឪពុកដែលត្រូវបានលើកដម្កើង** ហើយ អប្រាហាំ មានន័យថា **ឪពុកនៃជាតិសាសន៍ជាច្រើន**។ ឈ្មោះរបស់អ្នកនឹងលែងត្រូវបានហៅថា ___________________ទៀតហើយ ប៉ុន្តែត្រូវបានប្តូរទៅជា ___________________________វិញម្តង ដែលខ្ញុំបានដាក់ឲ្យលោកអ្នកធ្វើជា _______________________________ នៃ ____________ ជាច្រើន។
4. សំគាត់ពាក្យថា "យើងនឹង" នៅក្នុងពាខបន្ទាប់ទៀតនេះ (១៦-៨) លោកអ្នកត្រូវគប្បីគូសចំណាំទុក។
   ក. "យើងនឹង ________________________________________________"
   ខ. "យើងនឹង ________________________________________________"
   គ. "យើងនឹង ________________________________________________
   ________________________________________________________"
   ឃ. ទឹកដីកាណានទាំងមូល ក្នុងពេលនេះគឺមានសុទ្ធសាសន៍ផ្សេងមករស់នៅ និង ព្រះបានមានព្រះបន្ទូលថា "យើងនឹង ______________________________________"
5. នៅក្នុង១៨ តើព្រះជាម្ចាស់បានសន្យានឹងអប្រាហាំអំពូជពង្សកូនចៅរបស់គាត់យ៉ាងដូចម្តេច? ទ្រង់មានព្រះបន្ទូលថា "យើងនឹង ____________________________________"

**ការឆ្លុះបញ្ចាំង:** ចាត់ទុកលោកអ្នកផ្ទាល់គឺជាលោកអប្រាហាំ ព្រះជាម្ចាស់បានសន្យាអស់រយៈពេល ២៥ ឆ្នាំកន្លងផុតទៅហើយ ថាទ្រង់នឹងធ្វើគាត់បានក្លាយទៅជាប្រជាជាតិមួយយ៉ាងធំ (លោកុប្បត្តិ ១២:២) រយៈពេល ១០ ឆ្នាំក្រោយមកលោកស្រី សារ៉ាយ លែងមានសង្ឃឹមថានឹងបានក្លាយទៅជាម្តាយរបស់គេទៀតហើយ ហើយបោះបង់ចោលធាតុពិតរបស់ខ្លួនពីប្តីរបស់នាង ដែលព្រះជាម្ចាស់បានសន្យា តែតាមការពិតសេចក្តីសន្យានោះគឺមិនត្រូវបានរាប់បញ្ចូលរូបនាងទៅជាមួយនោះឡើយ ហេតុនោះហើយ នាងក៏បានប្រគត់អ្នកបម្រើស្រីឈ្មោះ នាង ហាហ្គាទៅឲ្យលោក អាប់រ៉ាមជំនួសវិញ។ លោក អាប់រ៉ាម ប្រាកដជានឹងត្រូវមានវិប្បដិសារីយ៍ដោយសារផែនការណ៍ និង ការប្រព្រឹត្តរបស់គាត់ ព្រោះគាត់មិនបានជឿថាព្រះជាម្ចាស់ ប្រាកដជានឹងធ្វើឲ្យបន្ទូលសន្យារបស់ទ្រង់បានសម្រេចចំពោះគាត់

ទោះបីជាយ៉ាងណាក៏ដោយគាត់បានជ្រើសរើសមធ្យោបាយនេះរួចទៅហើយ មិនតែប៉ុណ្ណោះគាត់ក៏មិនបានរៀបចំធ្វើតាមផែនការណ៍របស់ព្រះជាម្ចាស់ឡើងវិញដែរ។ នៅពេលលោក អាប់រ៉ាម មានអាយុ ៩៩ ឆ្នាំ ព្រះជាម្ចាស់បានលេចមកឯគាត់ម្តងទៀត ហើយទ្រង់បានមានព្រះបន្ទូលជាថ្មីម្តងទៀតនូវអ្វីដែលទ្រង់បានសន្យាជាមួយនឹងគាត់។ ព្រះអង្គបានចងសម្ព័ន្ធមេត្រីជាមួយនឹងលោកអាប់រ៉ាម ហើយបានប្តូរឈ្មោះគាត់ពី អាប់រ៉ាម ទៅជា អប្រាហាំ ថែមទាំងបានប្រកាសប្រាប់គាត់ទៀតថា "យើងនឹង" ធ្វើតាមសេចក្តីសន្យារបស់យើងមិនខាន។

បើសិនអ្នកជាមិត្តសម្លាញ់របស់លោក អប្រាហាំ ហើយគាត់ទុកចិត្តលើអ្នកលើគ្រប់រឿងរ៉ាវទាំងអស់ចាប់តាំងពីមុនពេលគាត់បានចាកចេញពីហារ៉ានមក (លោកុប្បត្តិ ១២:១) រហូតមកដល់បច្ចុប្បន្ន នៅពេលដែលព្រះជាម្ចាស់ បានប្តូរឈ្មោះរបស់គាត់ (លោកុប្បត្តិ ១៧)។ តើលោកអ្នកនឹងនិយាយថាយ៉ាងដូចម្តេចទៅគាត់នៅឥឡូវនេះ នៅពេលដែលគាត់បានមករួមបរិភោគអាហារជាមួយនឹងអ្នកក្នុងជំរុំ និងតើគាត់នឹងរាយការណ៍អំពីការយាងមកលើកចុងក្រោយរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេចដែរ? ___

_______________________________________________

_______________________________________________

## ការអនុវត្តន៍ផ្ទាល់ខ្លួនៈ

1. រំលឹកពេលវេលាពីដើមសារឡើងវិញម្តងទៀត គឺនៅពេលដែលលោកអ្នករង់ចាំ ប្រហែលជាយូរដូចជាលោក អប្រាហាំទេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពតម្រូវឲ្យមានការអត់ធ្មត់ក្នុងការរង់ចាំ _______________________________________________

   _______________________________________________

2. ស្ថិតក្នុងអំឡុងពេលកំពុងរង់ចាំតើលោកអ្នកមានគំនិតដូចម្តេច? _______________

   _______________________________________________

3. តើដំណើររឿងនោះនឹងដល់ទីបញ្ចប់ដោយរបៀបណា? ____________________

   _______________________________________________

**ការឆ្លុះបញ្ចាំងៈ** ក្នុងចំណោមពួកយើងភាគច្រើន មិនសូវជាធ្វើតាមអ្វីដែលខ្លួនបានសន្យានោះទេ។ បើសិនជាយើងមិនបានធ្វើតាមការសន្យា នោះនឹងនាំយើងមានការឈឺចាប់ ហើយ អាចបំផ្លាញទំនាក់ទំនងល្អទៀតផង និយាយដូច្នេះ ប្រហែលជាលោកអ្នកធ្លាប់ត្រូវបាននរណាម្នាក់មិនគោរពតាមពាក្យសន្យាដែរជាមិនខាន។

ការសារភាពអំពីដែលមានការឈឺចាប់ ឬ ការលន់តួរចំពោះនរណាម្នាក់ដែលយើងបានធ្វើឲ្យគេឈឺចាប់ ចូរថ្វាយទៅព្រះជាម្ចាស់ដើម្បីទុកឱកាសសម្រាប់ទ្រង់បានព្យាបាល និង ផ្សះផ្សារទំនាក់ទំនងដែលបាក់បែកឡើងវិញ។ តើនរណាដែលលោកអ្នកនឹកឃើញនៅក្នុងគំនិតក្នុងពេលនេះ? នេះគឺជាពេលវេលាមួយដ៏ប្រសើរក្នុងការអនុវត្តន៍ជាក់ស្តែងនូវបំណងព្យាបាលរបួសគ្រាំគ្រា និង ការបាកបែកពីអ្នកដែលនៅក្នុងគំនិតរបស់លោកអ្នក ហើយចូរទុកឱកាសឲ្យព្រះជាម្ចាស់ធ្វើការផ្សះផ្សារទំនាក់ទំនងឡើងវិញ ________________________________________________

________________________________________________

**សេចក្តីអធិស្ឋានៈ** ឱព្រះអម្ចាស់អើយ! សូមអរព្រះគុណចំពោះភាពស្មោះត្រង់របស់ទ្រង់ជាមួយនឹងលោក អាប្រាហាំ សូមអរព្រះគុណដែលទ្រង់បានប្រទានសេចក្តីជំនឿសម្រាប់គាត់ឲ្យបានជឿលើព្រះបន្ទូលសន្យារបស់ទ្រង់។ ព្រះអង្គមិនដែលភ្លេចសន្យារបស់ទ្រង់ម្តងណាឡើយ! តែទូលបង្គំតែងតែមិនបានគោរពតាមពាក្យសន្យារបស់ទូលបង្គំជាមួយនឹងអ្នកដទៃ។ សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ហើយជួយឲ្យការអនុវត្តន៍សារភាព លន់តួដោយសេចក្តីពិតទូលបង្គំនេះបានសម្រេចជាមួយនឹងអ្នកដទៃផងចុះ សូមឲ្យព្រះអង្គប្រោស ព្យាបាល និង កែច្នៃឡើងវិញជាថ្មីម្តងទៀតនូវ ________________

________________________________________________

________________________________________________

## ផ្នែកទី ២

**លំហាត់:** ព្រះជាម្ចាស់បានប្រទានសេចក្តីសន្យាជាថ្មីឡើងវិញ ដែលទ្រង់បានសន្យាជាមួយនឹងគាត់ទាក់ទងនឹងប្រពន្ធរបស់គាត់ គឺលោកស្រី សារ៉ាយ។ ចូរអានព្រះគម្ពីរលោកុប្បត្តិ ១៧:១៥-១៧, ១៩។

1. តើព្រះជាម្ចាស់មានព្រះបន្ទូលដូចម្តេចខ្លះទាក់ទិននឹងលោកស្រី សារ៉ាយ?
   ក. នៅក្នុងខ ១៥ អំពីឈ្មោះរបស់គាត់: ________________________
   ខ. នៅក្នុងខ ១៦ អំពីសេចក្តីសន្យា: ________________________

   ________________________________________

2. ជាក់ស្តែងលោក អប្រាហាំ បានតស៊ូយ៉ាងស្វិតស្វាញក្នុងការជឿលើសេចក្តីសន្យាដែលព្រះជាម្ចាស់បានសន្យា គាត់ទន្ទឹងរង់ចាំឲ្យបានសម្រេចតាមសេចក្តីសន្យានោះ (ចូរអានខ១៧)។ មានប្រការជាច្រើនបានធ្វើឲ្យគាត់អស់សង្ឃឹម! នៅពេលគាត់មានអាយុ ៨៥ ឆ្នាំ អាប់រ៉ាម នៅតែមានជំនឿច្បាស់ តែដល់ពេលគាត់ឈានចូលអាយុ ១០០ ឆ្នាំ លោកអាប់រ៉ាម និង ភរិយាក៏ផ្តើមមានទស្សនៈអវិជ្ជមាន។ តើមានកត្តាអ្វីខ្លះដែលបណ្តាយឲ្យគាត់អស់សង្ឃឹមយ៉ាងដូច្នេះ?

ក. កត់ចំណាំចំពោះអកប្បកិរិយា និង អារម្មណ៍របស់ឆ្លើយតបនៅក្នុងខ ១៧: _______

________________________________________________

ខ. កត់ចំណាំនូវសំនួររបស់គាត់:

(១). ________________________________________

(២). ________________________________________

3. ព្រះជាម្ចាស់បានឮសម្រែកទូលអង្វរពីក្នុងចិត្តរបស់គាត់ ហើយទ្រង់ក៏បានធានាអះអាងនូវអ្វីដែលទ្រង់បានសន្យានឹងគាត់ថាប្រាកដជានឹងបានសម្រេចជាមិនខាន។ ព្រះជាម្ចាស់ទ្រង់ជ្រាប់ថាលោក អប្រាហាំលែងមានជំនឿថាសេចក្តីសន្យានោះថានឹងបានសម្រេចទៀតហើយ ព្រោះតែគំនិត និង សមត្ថភាពរបស់មនុស្សមានដែនកំណត់ ប៉ុន្តែការដែលបានសម្រេចឬយ៉ាងនោះគឺវាអាស្រ័យនៅលើព្រះជាម្ចាស់ទៅវិញទេ។

ក. នៅក្នុងខ១៩ ខណៈនោះព្រះជាម្ចាស់មានព្រះបន្ទូលថា "សារ៉ាប្រពន្ធរបស់អ្នកនឹង ____

________________________________________________

ខ. ឈ្មោះរបស់គាត់នឹងបានជា ______________________ "យើងនឹង

________________________________________________"

**ការអនុវត្តន៍ផ្ទាល់ខ្លួន:** តើលោកអ្នកធ្លាប់និយាយថា "នេះគឺជារឿងដែលហួសពីសមត្ថភាពរបស់ខ្ញុំ ឬ រឿងនេះខ្ញុំមិនអាចធ្វើអ្វីបានទាល់តែសោះ"? ឬ "នេះគឺជារឿងដែលគ្មានមនុស្សណាម្នាក់អាចនឹងធ្វើបាននោះទេ"? នៅពេលណាមួយយើងម្នាក់ៗក៏ដូច្នេះដែរ! ជួនកាលយើងអស់សង្ឃឹមលើខ្លួនឯងទាំងស្រុង ហើយនឹកងើយឆ្ងល់ថារឿងអាក្រក់ៗទាំងអស់នេះវាកើតឡើងបានយ៉ាងម៉េចទៅ? ព្រះជាម្ចាស់នៅតែស្មោះត្រង់នឹងលោក អប្រាហាំ និង លោកស្រី សារ៉ាជានិច្ច ដោយទ្រង់នៅតែគោរពតាមសន្យាដែលទ្រង់បានចងសម្ព័ន្ធមេត្រីជាមួយនឹងពួកគេដដែល ទោះបីជាពួកគេបាត់សេចក្តីសង្ឃឹមក៏ដោយ តែសេចក្តីសន្យារបស់ទ្រង់នៅតែបានសម្រេចទៅតាមការសន្យារបស់ព្រះអង្គដដែល។ សូមចំណាយពេលខ្លះដើម្បីរកឲ្យឃើញនូវសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់តាមរយៈព្រះគម្ពីរ ទុតិយកថា ៣១:៨ ហើយអរព្រះគុណដល់ទ្រង់សម្រាប់សេចក្តីស្រលាញ់របស់ទ្រង់ដែលមានចំពោះយើង មានព្រះជាម្ចាស់គឺមានគ្រប់គ្រាន់ ________________________________________

________________________________________________

**ការទន្ទេញចងចាំ:** តាំងពីយូរយាណាស់មក បទគម្ពីរត្រូវបានដកស្រង់ចេញពីព្រះគម្ពីរ ទុតិយកថា ៣១:៨ ដែលមាននិយាយទៅកាន់ យ៉ូស្វេ ដែលជាអ្នកដឹកដ៏ចំណានរបស់លោក ម៉ូសេ។ ក្នុងគ្រាដែលលោក ម៉ូសេ ហៀបនឹងទទួលមរណៈភាពទៅ យ៉ូស្វេ ក៏ត្រូវទទួលដំណែងបន្ត ហើយគាត់បានចាកចេញពី យ៉ូស្វេទៅដោយបន្សល់ទុកនៅពាក្យសម្ដីទាំងនេះ សូម្បីតែគាត់ផ្ទាល់ក៏ដឹងថានោះគឺជាការពិតដែរ។ ដំណើរជីវិតរបស់គាត់បានស្ដែងឲ្យបានឃើញយ៉ាងច្បាស់ថាព្រះជាម្ចាស់តែងតែយាងនាំមុខ ដើម្បីរៀបចំទុកជាមុនជានិច្ច និយាយឲ្យងាយស្ដាប់គឺទ្រង់តែងតែគង់ជាមួយ បង្ហាញផ្លូវ តម្រង់ទិសដៅ ហើយនិងតែងតែគង់ជាប់ប្រកិតនឹតគាត់ជាដរាប ទ្រង់មិនដែលបោះបង់គាត់ចោល ឬ បណ្ដោយឲ្យគាត់ជួបការភ័យខ្លាចម្ដងណាឡើយ ដូច្នេះហើយ ទើបជានិច្ចកាល យ៉ូស្វេ តែងតែមានចិត្តរឹងប៉ឹង និង អង់អាចក្លាហានក្នុងការដឹងនាំដោយមិនមានការរាថយឡើយ។ កិច្ចការដែលលោកអ្នកត្រូវទន្ទេញឲ្យបានចាំនោះគឺ ត្រូវសរសេរបទគម្ពីរ ទុតិយកថា ៣១:៨ ទុកក្នុងសៀវភៅកត់ត្រារបស់លោកអ្នក ហើយត្រូវទន្ទេញឲ្យបានចាំមាត់នូវអ្វីលោក ម៉ូសេ បានមានប្រសាសន៍ទៅកាន់ យ៉ូស្វេ ដែលត្រូវបានបន្តរហូតមកបានធ្វើឲ្យមានការពាក់ព័ន្ធជាមួយនឹងពួកយើងទាំងអស់គ្នាមកទល់នឹងសតវត្សរ៍ទី ២១ នេះ។

**ការអនុវត្តន៍ផ្ទាល់ខ្លួន:** ខគម្ពីរទាំងឡាយដែលយើងត្រូវទន្ទេញនឹងថ្មីៗជានិច្ច! ហើយមានអត្ថន័យពាក់ព័ន្ធនឹងយើងម្នាក់ៗ នៅពេលណាដែលយើងប្រើប្រាស់ពាក្យសម្ដីជាមួយអ្នកដទៃ។ តើអ្នកដឹកនាំ ឬនរណាម្នាក់ ដែលលោកអ្នកគិតថានឹងយកពាក្យសម្ដីទាំងនេះទៅប្រាប់ពួកគេ ដោយធានាអះអាងថាវត្តមានរបស់ព្រះជាម្ចាស់គឺតែងតែមានជានិច្ចក្នុងជីវិតរបស់ពួកគេ? អាចឪពុកម្ដាយ ឬ អាណាព្យាបាល លោកគ្រូ អ្នកគ្រូ ចៅហ្វាយ មិត្តភ័ក្ររួមការងារ។ល។ ឬមួយអាចជា មិត្តភ័ក្រណាមួយដែលកំពុងជួបប្រទះនឹងបញ្ហាអ្វីមួយ ឬ ត្រូវរ៉ះកាត់ ឬ អ្នកណាម្នាក់កំពុងធ្វើការបម្រើយ៉ាងកណ្ដោចកណ្ដែងតែម្នាក់ឯងជាដើម។ លោកអ្នកត្រូវតែធ្វើជាសក្ខីភាពឲ្យបានម៉ឺងម៉ាត់រឹងប៉ឹង ក្នុងការចែកចាយប្រាប់ដល់ពួកគេអំពីភាពស្មោះត្រង់ និង ភាពសប្បុរសរបស់ព្រះជាម្ចាស់។ ចូរនឹកគិតថាតើលោកអ្នកគួរតែត្រូវនិយាយដូចម្ដេច? ________________________________________________

________________________________________________________

**សេចក្ដីអធិស្ឋាន:** សូមអរព្រះគុណដល់ព្រះអង្គ សម្រាប់សេចក្ដីស្រលាញ់ ភាពស្មោះត្រង់ចំពោះលោក អប្រាហាំ និង លោកស្រី សារ៉ា ព្រមទាំងទូលបង្គំផងដែរ។ សូមទ្រង់ជួយទូលបង្គំយល់ពីការនេះឲ្យបានកាន់តែច្បាស់ មិនមែនមានន័យថា ទូលបង្គំត្រូវទទួលនូវអ្វីៗទាំងឡាយដែលទូលបង្គំចង់បាននោះទេ ប៉ុន្តែ គឺជាអ្វីៗទៅតាមសេចក្ដីស្រលាញ់ និង ភាពស្មោះត្រង់របស់ទ្រង់ដែលមានសម្រាប់ទូលបង្គំវិញ

________________________________________________________

## ផ្នែកទី ៣

**សេចក្តីបង្រៀន:** សម្ព័ន្ធមេត្រីដែលព្រះជាម្ចាស់បានចងឡើងជាមួយនឹងលោក អប្រាហាំ គឺជាសម្ព័ន្ធមេត្រីមួយដ៏នៅអស់កល្បជានិច្ច ហើយក៏មិនមែនត្រូវបានចងឡើងសម្រាប់តែលោក អប្រាហាំ និង ប្រពន្ធរបស់គាត់ប៉ុណ្ណោះនោះទេ គឺចងសម្រាប់គ្រប់ទាំងដំណរពូជពង្សកូនចៅគ្រប់ជំនាន់ក្រោយៗរបស់គាត់ទៀតផង។ ដើម្បីឲ្យបានយល់កាន់តែច្បាស់អំពីសម្ព័ន្ធមេត្រីដ៏នៅអស់កល្បនេះ យើងត្រូវតែពិនិត្យឲ្យបានល្អិតល្អន់។

**និយមន័យ:** នៃពាក្យថា **សម្ព័ន្ធមេត្រី** គឺមានន័យថាជាសេចក្តីសន្យា ឬ ជាកិច្ចព្រមព្រៀងរវាងពីរភាគី។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១៧:៤ គឺជាសម្ព័ន្ធមេត្រីមួយត្រូវបានផ្តួចផ្តើមឡើងដោយភាគីម្ខាងដែលប្រសើរជាង (គឺជាព្រះជាម្ចាស់) ជាមួយនឹងភាគីម្ខាងទៀតដែលអន់ជាង (គឺជាលោក អប្រាហាំ) ហើយ ភាគីទាំងពីរបានព្រមព្រៀងជាមួយគ្នាដោយយោងទៅតាមលក្ខណ្ឌដោយបានដាក់ចេញដោយភាគីដែលជាអ្នកផ្តួចផ្តើមគំនិរ (គឺជាព្រះជាម្ចាស់)។

ព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់ដល់លោក អប្រាហាំ នូវអ្វីៗដែលព្រះអង្គនឹងត្រូវធ្វើ គឺព្រះអង្គមានព្រះបន្ទូលថា "យើងនឹង" ដូចទៅនឹងអ្វីដែលយើងបានដឹងតាមរយៈផ្នែកទី ១ ស្រាប់។ បន្ទាប់មកទ្រង់បានប្រាប់ទៅលោក អប្រាហាំ នូវអ្វីដែលព្រះជាម្ចាស់តម្រូវឲ្យគាត់ត្រូវធ្វើ វាជាការពិតណាស់ គឺថាសម្ព័ន្ធមេត្រីដ៏នៅអស់កល្បនេះ ត្រូវបានព្រះជាម្ចាស់ជាអ្នកផ្តួចផ្តើមឡើងសម្រាប់លោក អប្រាហាំ និងកូនចៅពូជពង្សជំនាន់ក្រោយៗរបស់គាត់ដែរ។

នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ៩:១៦ យើងនៅចាំបានថាព្រះជាម្ចាស់បានចងសម្ព័ន្ធមេត្រីដ៏នៅអស់កល្បជាមួយនឹងគាត់ព្រមទាំង "គ្រប់ទាំងអ្វីដែលមានជីវិតរស់នៅលើផែនដីនេះផង" នេះគឺជាសម្ព័ន្ធមេត្រីមួយដែលបានចង់ឡើងជាមួយនឹងលោក ណូអេ សម្ព័ន្ធមេត្រីទាំងនេះមានលក្ខណៈខុសៗពីគ្នា។ អ្នកផ្តួចផ្តើមគំនិតគឺជាព្រះជាម្ចាស់ ហើយអ្នកដាក់លក្ខណ្ឌក៏ជាទ្រង់ដែរ រីឯអ្នកដែលត្រូវគោរពតាមលក្ខណ្ឌនោះគឺជាទ្រង់តែមួយអង្គឯងដដែល។ ឥន្ទធនូគឺជាទីសម្គាល់ នឹងរំលឹងអំពីសម្ព័ន្ធមេត្រីនោះ ការនេះគឺនៅតែមានបន្តរហូតមកដល់សព្វថ្ងៃនេះ។

**លំហាត់:** ចូរពួកយើងនាំគ្នាពិនិត្យឲ្យបានកាន់តែច្បាស់ថែមទៀតចំពោះសម្ព័ន្ធមេត្រីដែលព្រះជាម្ចាស់បានចងឡើងជាមួយនឹងលោក អប្រាហាំ តាមរយៈព្រះគម្ពីរលោកុប្បត្តិជំពូកទី ១៧។

1. ចូរយើងអាននៅត្រង់ចុងខទី ៧! តើនៅផ្នែកដំបូងបង្អស់នៃសេចក្តីសន្យានៃសម្ព័ន្ធមេត្រីដែលទ្រង់បានសន្យា? "យើងនឹង ____________________________________"

2. បន្ទាប់ពីព្រះអង្គបានសន្យាថាទ្រង់នឹងធ្វើជាព្រះជាម្ចាស់របស់ពួកគេ ហើយនិងកូនចៅគ្រប់ជំនាន់របស់ពួកគេដែលជារាស្ត្ររបស់ទ្រង់ ដូចព្រះអង្គមានព្រះបន្ទូលនៅក្នុងខ៨ថា "យើងនឹងឲ្យ ______________________ ដល់អ្នក និង ________________________ របស់អ្នក នៅបន្ទាប់ពី ________________________ របស់អ្នកទាំងអស់ ______________ ហើយនិងទឹកដីទាំងអស់នៃ __________________________________________ ____________________________________________ដ៏នៅអស់កល្បជានិច្ច"។
3. ជាថ្មីម្តងទៀត ទ្រង់បានសន្យានៅក្នុងខ៨ ថា "...ហើយយើងនឹងធ្វើជា ____________ ____________________________________________ របស់ពួកគេដែរ"។
4. បន្ទាប់មកទៀតទ្រង់ក៏បានចងសម្ព័ន្ធមេត្រីជាមួយនឹងលោក អប្រាហាំ ដោយបានប្រាប់នូវអ្វីដែលទ្រង់សព្វព្រះហឫទ័យចង់ឲ្យលោក អប្រាហាំ កូនចៅពូជពង្សជំនាន់ក្រោយៗរបស់គាត់ត្រូវអនុវត្តតាម។ នៅក្នុងខ ៩-១៤ ព្រះជាម្ចាស់បានចេញនូវលក្ខណ្ឌនានាដែលពួកគេត្រូវតែធ្វើតាម (សូមអានបទគម្ពីរទាំងនេះសារឡើងវិញ រួចកត់ត្រាទុកនូវខ ១០ និង ខ ១១)។ "មនុស្សប្រុសទាំងអស់ ________________________________________________

____________________________________________________________

____________________________________________ រវាងអ្នក និង យើង"។
5. នៅក្នុងខ ១២ និង ១៣ គឺជាពត៌មានបន្ថែមអំពីអ្វីដែលជាសេចក្តីណែនាំរបស់ព្រះជាម្ចាស់ចំពោះពិធីកាត់ស្បែកសម្រាប់មនុស្សប្រុសទាំងអស់នៅក្នុងរង្វង់ក្រុមគ្រួសាររបស់ អប្រាហាំ រួមទាំងពូជពង្សជំនាន់ក្រោយៗទៀតរបស់គាត់ដែរ: ________________________

____________________________________________________________

____________________________________________________________

## ផ្នែកទី ៤

**សេចក្តីបង្រៀន:** ព្រះជាម្ចាស់ទ្រង់ទាមទារឲ្យចេះស្តាប់បង្គាប់ នោះសេចក្តីសន្យានឹងប្រទានពរដល់អស់អ្នកណាដែលបានគោរពតាមសម្ព័ន្ធមេត្រី និង អស់អ្នកដែលបានទទួលពិធីកាត់ស្បែក ហើយក៏នឹងមានជាលទ្ធផលសម្រាប់អស់អ្នកដែលមិនស្តាប់បង្គាប់ និង អ្នកមិនកាត់ស្បែកដែរ។

នៅក្នុងព្រះគម្ពីរ លោកុប្បត្តិ ១៧:១៤ គឺជាអ្វីដែលព្រះជាម្ចាស់មានបន្ទូលចំពោះអស់អ្នកណាដែលមិនស្តាប់បង្គាប់ ______________________________________________________ ព្រះជាម្ចាស់មិនបានដាក់លក្ខណ្ឌក្នុងសម្ព័ន្ធមេត្រីរបស់ទ្រង់ងាយៗពេកនោះទេ។ ព្រះអង្គនៅតែរក្សា និង

គោរពតាមអ្វីដែលជាផ្នែករបស់ទ្រង់ ហើយព្រះអង្គក៏រំពឹងចង់ឲ្យលោក អប្រាហាំ និង កូនចៅរបស់គាត់គ្រប់ជំនាន់គោរពលក្ខណ្ឌរបស់ពួកគេដែរ គឺត្រូវធ្វើពិធីកាត់ស្បែក។

នេះគឺជាការពិតណាស់ សម្ព័ន្ធមេត្រីដែលបានចងឡើងជាមួយនឹងលោក អប្រាហាំ និង ក្រុមគ្រួសាររបស់គាត់នេះត្រូវបានបង្គាប់ដល់ កុលសម្ព័ន្ធ និង មនុស្សប្រុសទាំងអស់ជាការបញ្ជាក់ឲ្យឃើញថា ពួកគេគឺមានចំណែកនៅក្នុងសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់ផងដែរ។ តែទោះជាយ៉ាងណាក៏ដោយ ស្ត្រីមិនត្រូវបានរាប់បញ្ចូលក្នុងសម្ព័ន្ធមេត្រីនេះ គឺមានន័យថាមិនបានតម្រូវឲ្យមនុស្សស្រីធ្វើពិធីកាត់ស្បែកនោះទេ ព្រោះថាមនុស្សស្រីទាំងអស់នឹងត្រូវបានរាប់បញ្ចូលតាមរយៈឪពុក ឬ ប្ដីរបស់ពួកគេ បើសិនជាឪពុក ឬ ប្ដីរបស់មនុស្សស្រីណាដែលបានទទួលពិធីកាត់ស្បែករួចហើយ នោះពួកគេក៏នឹងអាចទទួលបានព្រះពរពីព្រះជាម្ចាស់ដូចនឹងបុរសៗដែរ។ សូមរំលឹងឡើងវិញអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលទាក់ទងនឹងលោកស្រី សារ៉ា នៅក្នុងខ ១៥-១៦ គឺដូចគ្នាសុទ្ធសាធទៅនឹងអ្វីដែលទ្រង់មានព្រះបន្ទូលទៅកាន់លោក អប្រាហាំ នៅក្នុងខ ៥-៦។

មកដល់សតវត្សរ៍ទី ២១ នេះ ជាទូទៅទារកប្រុសៗដែលបានកើតមក គឺត្រូវបានកាត់ស្បែករួចជាស្រេចមុនពេលចេញពីមន្ទីរពេទ្យមកម្ល៉េះ! ទោះបីជាយ៉ាងនេះក្ដី ក៏នៅមានគ្រួសារជនជាតិយូដាមួយចំនួន បានយកកូនប្រុសរបស់ពួកគេមកឲ្យគ្រូគង្វាល ធ្វើពិធីកាត់ស្បែកនៅផ្ទះ ឬ នៅព្រះវិហារដែរ។ ទោះបីជាធ្វើពិធីនោះនៅផ្ទះក្ដី នៅព្រះវិហារក្ដី ឬនៅទីណាក្ដីក៏បានដូចគ្នា តែភាគច្រើនគឺគេបានកាត់ស្បែកនៅមន្ទីរពេទ្យមុនពេលគេត្រឡប់មកផ្ទះវិញ។ និយាយជារួមពិធីនេះគឺតម្រូវឲ្យមានការហូរឈាមជាការចាំបាច់ ដ្បិតការបង្ហូរឈាមគឺជាសំដៅដល់ការគ្របបាំងអំពើបាប។ ជាការពិតទៅ ព្រះជាម្ចាស់គ្រាន់ចង់ឲ្យរាស្ត្ររបស់ទ្រង់មានអត្តសញ្ញាណមួយ ដើម្បីទុកធ្វើជាការសម្គាល់ថាជាអ្នកមានចំណែកនៅក្នុងសម្ព័ន្ធមេត្រីរបស់ទ្រង់ប៉ុណ្ណោះ ជាងនេះទៅទៀតនោះ គឺថាពួកគេត្រូវបានគ្របបាំងដោយឈាម យ៉ាងនោះពួកគេនឹងបានប្រាកដថាពិតជាមានចំណែក និង អត្តសញ្ញាណជារាស្ត្ររបស់ទ្រង់ ព្រមទាំងមានទំនាក់ទំនងជាមួយនឹងទ្រង់ដែរ ដូចដែលទ្រង់បានសន្យាថា យើងនឹងធ្វើជាព្រះជាម្ចាស់របស់ពួកគេ (ខ៧) តាមសេចក្ដីសន្យារបស់ទ្រង់ (ខ១៤)។

**ការឆ្លុះបញ្ចាំង:** បើសិនជាយើងមើលតែមួយភ្លែត វាហាក់ដូចជាមិនមែនរឿងមួយដ៏លំបាកសម្រាប់លោក អប្រាហាំ និង លោកស្រី សារ៉ា ព្រមទាំងពូជពង្សជំនាន់ក្រោយរបស់គាត់នោះទេ ប៉ុន្ដែបើយើងពិចារណាឲ្យបានស៊ីជម្រៅជាងនេះបន្ដិច នោះយើងនឹងមានការពេញចិត្តចំពោះបំណងព្រះហឫទ័យនៃព្រះជាម្ចាស់ជាមិនខានឡើយ ជាស្ដែងដូចជាទ្រង់បានប្រកាសថាទ្រង់នឹងធ្វើជាព្រះរបស់ពួកគេ និង អ្នក

ដទៃទៀត។ តទៅនេះសូមលោកអ្នកអាចនូវខគម្ពីរមួយចំនួននេះ ហើយធ្វើការផ្ទុះបញ្ចាំងថាតើព្រះគឺជានរណា ហើយសិក្សាអំពីមនុស្សទាំងនេះជាមួយគ្នា:

1. លោកុប្បត្តិ ១:១ និង ១:២៧
   ក. តើព្រះជាម្ចាស់គឺជានរណា? ______________________________
   ខ. តើមនុស្សគឺជានរណា? ______________________________
2. លោកុប្បត្តិ ១៧:១
   ក. តើព្រះជាម្ចាស់គឺជានរណា? ______________________________
   ខ. តើព្រះជាម្ចាស់ចង់ឲ្យមនុស្សធ្វើអ្វីខ្លះ? ______________________________
3. ទំនុកដម្កើង ៨:១-២ និង ១៣៩:១៤-១៦
   ក. តើព្រះជាម្ចាស់គឺជានរណា? ______________________________
   ខ. តើមនុស្សគឺជានរណា? ______________________________
4. យេរេមា ២:១១,១៣, ១៩ និង ៣៣:៨
   ក. តើព្រះជាម្ចាស់គឺជានរណា? ______________________________
   ខ. តើមនុស្សគឺជានរណា? ______________________________

ធ្វើសេចក្ដីសន្និដ្ឋានសង្ខេបថាតើព្រះជាម្ចាស់គឺជានរណា: ______________________________

______________________________________________________________

ធ្វើសេចក្ដីសន្និដ្ឋានដោយបរិយាយថាតើមនុស្សគឺជានរណា: ______________________________

______________________________________________________________

**សេចក្ដីអធិស្ឋាន:** ឱព្រះអម្ចាស់អើយ! សេចក្ដីស្រលាញ់របស់ព្រះអង្គមានយ៉ាងបរិបូណ៌នៅក្នុងជីវិតទូលបង្គំ ដ្បិតទ្រង់ហើយគឺជាអ្នកដែលបានបង្កើតផ្ទៃមេឃ និង ផែនដី។ ព្រះអង្គគឺជាព្រះដ៏គ្រប់លក្ខណ្ឌ! ជាព្រះអម្ចាស់លើអ្វីៗទាំងអស់! ព្រះនាមទ្រង់ល្បីខ្ទរខ្ទារនៅទូទាំងផែនដី! គឺទ្រង់ហើយជាព្រះអធិកររបស់ទូលបង្គំ និង មនុស្សទាំងអស់នៅលើផែនដីនេះ! ព្រះអង្គមានបំណងព្រះហឫទ័យមិនចង់ឲ្យទូលបង្គំមានកំហុសណាមួយឡើយ ដ្បិតទ្រង់គឺជាព្រះដ៏បរិសុទ្ធ ព្រះអង្គតែងតែគិតគូរអំពីទូលបង្គំ ទ្រង់ជ្រាប់គ្រប់អ្វីៗដែលទូលបង្គំត្រូវការ ហើយទ្រង់ក៏ជ្រាប់គ្រប់ទាំងគំនិត និង ចិត្តទូលបង្គំ ទាំងពាក្យសម្ដី ការប្រព្រឹត្តផងដែរ ទ្រង់បានដឹងគ្រប់ទាំងអំពើបាបដែលទូលបានប្រព្រឹត្ត តែទោះជាយ៉ាងនេះក្ដី ក៏ទ្រង់នៅតែស្រលាញ់ ហើយអត់ទោសឲ្យទូលបង្គំដែរ ហើយបានលាងសម្អាតទូលបង្គំដោយព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទជាព្រះសង្គ្រោះរបស់ទូលបង្គំទៀតផង។ មិនតែប៉ុណ្ណោះ ទ្រង់ថែម

ទាំងយកទូលបង្គំធ្វើជាកូនស្ងួនភ្ងា ធ្វើជារាស្ត្រផ្ទាល់របស់ទ្រង់ទៀតផង គឺមានតែព្រះអង្គមួយប៉ុណ្ណោះ ដែលបានលើទឹកចិត្តទូលបង្គំ សរសើរដម្កើង ហើយ អរព្រះគុណដល់ទ្រង់ជាដរាប។

## ផ្នែកទី ៥

**សេចក្តីណែនាំៈ** មុននឹងបន្តសិក្សាអំពីសាច់រឿងរបស់លោក អប្រាហាំ ទៅមុខទៀតយើងគួរតែបាន ស្តាប់ចិត្តចំពោះអ្វីដែលយើងចង់ដឹងអំពីសាច់រឿងរបស់ អ៊ីស្មាអែន ហើយមែនទេ? ចូរយើងរំលឹងសារ ឡើងវិញខ្លះៗនូវអ្វីដែលយើងបានសិក្សាកន្លងមកបន្តិចសិន គឺថាលោកស្រី សារ៉ាយ បានបញ្ជូនអ្នក បម្រើស្រីរបស់គាត់ ឈ្មោះនាង ហាហ្គាឲ្យទៅរួមដំណេកជាមួយនឹងលោក អាប់រ៉ាម លុះក្រោយមក បន្តិច នាងហាហ្គា ក៏មានផ្ទៃពោះ។ លុះដល់ពេលដែលនាងហាហ្គាបានដឹងខ្លួនថាមានផ្ទៃពោះដូច្នេះក៏ តាំងចាប់មាក់ងាយដល់លោកស្រី សារ៉ាយ (លោកុប្បត្តិ ១៦:៤) ហើយនៅទីបំផុតលោកស្រីសារ៉ាយ ក៏មានប្រតិកម្មតបវិញដោយមានគំនិតអាក្រក់ចំពោះនាង ហាហ្គា រហូតធ្វើនាងត្រូវបង្ខំចិត្តចាកចេញ ពីគ្រួសាររបស់លោក អាប់រ៉ាម (លោកុប្បត្តិ ១៦:៦) តែទេវត្តានៃព្រះជាម្ចាស់បានរកនាងឃើញនៅឯ វាលរហោស្ថានមួយ នៅពេលនោះទេវត្តានៃព្រះបានប្រាប់ឲ្យនាងវិលត្រឡប់ទៅរកចៅហ្វាយស្រីរបស់ នាងវិញ ហើយត្រូវមានការចុះចូលចំពោះគាត់។ ក្នុងខណៈនោះដែរ ទេវត្តានៃព្រះអម្ចាស់បានសន្យាជា មួយនឹងនាងថា ដំណរពូជពង្ស និងកូនចៅជំនាន់ក្រោយរបស់នាងនឹងមានចំនួនជាច្រើន រហូតទាល់គ្មាន នរណារាប់អស់បាន។

សេចក្តីសន្យារបស់ទេវត្តានៃព្រះអម្ចាស់ចំពោះនាង ហាហ្គា មាននៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១៦ ប៉ុន្តែ ចំពោះរឿងរ៉ាវទាក់ទងនឹងកូនប្រុសរបស់នាងក៏នៅតែមិនទាន់បានយល់ច្បាស់ដដែល។ កាលពីដំបូងនាង ត្រូវបានបញ្ជាក់យ៉ាងច្បាស់ថានាងត្រូវមានផ្ទៃពោះ ហើយនឹងបង្កើតបានកូនប្រុសម្នាក់ ត្រូវដាក់ឈ្មោះ ឲ្យកូនប្រុសនោះថា អ៊ីស្មាអែល ដែលមានអត្ថន័យថា "ព្រះជាម្ចាស់ជ្រាបពីទុក្ខវេទនារបស់អ្នក"។ លុះ ក្រោយនោះបន្តិចទេវត្តានៃព្រះអម្ចាស់បានមកប្រាប់ថា អ៊ីស្មាអែល បានទៅជាបុរសសត្វលាព្រៃម្នាក់ ហើយមនុស្សគ្រប់ៗគ្នានឹងប្រឆាំងនឹងគាត់ រីឯគាត់ក៏នឹងប្រឆាំងតបមនុស្សគ្រប់ៗវិញដែរ ជាងនេះទៅ ទៀតនោះគឺគាត់នឹងត្រូវបានរស់នៅក្នុងជីវិតដ៏មានអរិភាពក្នុងចំណោមបងប្អូនប្រុសរបស់គាត់។ រួចមក នៅត្រង់ចុងនៃជំពូក ព្រះគម្ពីរបានប្រាប់យើងឲ្យដឹងថានាង ហាហ្គា បានបង្កើតកូនប្រុសម្នាក់ជូន លោក អាប់រ៉ាម ត្រូវបានដាក់ឈ្មោះឲ្យកូនប្រុសនោះថា អ៊ីស្មាអែល នៅគ្រានោះលោក អាប់រ៉ាម មានអាយុ ៨៦ ឆ្នាំទៅហើយ។

**លំហាត់:**

1. បន្ទាប់ពីនេះទៅទៀត យើងនឹងបានដឹងរឿងរ៉ាវរបស់អ៊ីស្មាអែលថែមទៀតតាមរយៈព្រះគម្ពីរលោកុប្បត្តិជំពូក ១៧។ នៅក្នុងខ ១៨ លោក អាប់រ៉ាម បានទូលអង្វរដល់ព្រះជាម្ចាស់ថា "ឱព្រះអង្គអើយ អ៊ីស្មាអែល គេត្រូវតែបានរស់នៅចំពោះព្រះភ័ក្ររបស់ព្រះអង្គ" ពេលនោះព្រះជាម្ចាស់បានឆ្លើយតបទៅគាត់វិញដោយមានព្រះបន្ទូលថា អ៊ីស្មាអែលនឹងរស់នៅក្រោមព្រះពររបស់គេ តែទោះបីជាយ៉ាងណាក្តី ក៏ អ៊ីស្មាអែល មិនត្រូវបានជាប់នៅក្នុងសម្ព័ន្ធមេត្រីរបស់ព្រះដែលបានចងឡើងជាមួយនឹងលោក អាប់រ៉ាមឡើយ។
2. តើព្រះជាម្ចាស់មានព្រះបន្ទូលអំពី អ៊ីស្មាអែលយ៉ាងដូចម្តេចខ្លះ? (លោកុប្បត្តិ ១៧:២០) សម្រាប់ អ៊ីស្មាអែល យើងបានឮសម្រែករបស់អ្នកហើយ
   ក. យើងបាន ______________________________ គាត់
   ខ. ហើយនឹង ______________________________ គាត់នឹង
   ______________________________ និង
   គ. យើងនឹង ______________________________"។
3. ចាប់តាំងពីថ្ងៃដែលព្រះជាម្ចាស់បានចងសម្ព័ន្ធមេត្រីដ៏នៅអស់កល្បជាមួយនឹងលោក អាប់រ៉ាមតរៀងមក គឺគាត់បានឆ្លើយតបចំពោះព្រះដោយការស្តាប់បង្គាប់យ៉ាងខ្ជាប់ខ្ជួន។ សូមអាននៅក្នុងព្រះគម្ពីរលោកុប្បតិត្ ១៧:២៣-២៧ ហើយកត់ត្រាទុកនៅអ្វីដែលបាននិយាយទាក់ទងទៅនឹង អ៊ីស្មាអែល។
   ក. ខ២៣: តើលោក អប្រាហាំបានធ្វើអ្វីខ្លះ? ______________________________
   ______________________________
   ខ. ខ២៤: គឺអប្រាហាំមាន __________ឆ្នាំហើយ នៅពេលដែលគាត់ធ្វើពិធីកាត់ស្បែក។
   គ. ខ២៥: កូនប្រុសរបស់គាត់ឈ្មោះ អ៊ីស្មាអែលមាន ____________ ឆ្នាំ។
   ឃ. ខ២៦: លោក អប្រាហាំ និង អ៊ីស្មាអែល ពួកគេទាំងពីរ ____________
   ______________________________ ក្នុងពេលតែមួយ
   ង. ខ២៧: តើមាននរណាខ្លះទៀតបានទទួលពិធីកាត់ស្បែកជាមួយពួកគេ? __________
   ______________________________
   ______________________________

សូមកុំមានគំនិតថា អស់អ្នកណាដែលមិនមែនជាកូនប្រុសរបស់លោក អប្រាហាំ មិនត្រូវបានទទួលព្រះពរនោះទេ! គ្រប់មនុស្សប្រុសទាំងអស់ មិនថាជាអ្នកដែលបានកើតនៅក្នុងគ្រួសារ

របស់គាត់ ឬ អ្នកដែលត្រូវបានទិញមកពីសាសន៍ដទៃនោះឡើយ គឺត្រូវតែធ្វើពិធីកាត់ស្បែក ដើម្បីឲ្យមានចំណែកនៅក្នុងសម្ព័ន្ធមេត្រីដ៏នៅអស់កល្បដែលព្រះបានចង់ឡើង។ នេះគឺពិតជាទង្វើនៃព្រះគុណនៃព្រះជាម្ចាស់ និង សេចក្ដីស្រលាញ់ដ៏លើសលប់ពិតប្រាកដមែន!

**សេចក្ដីបង្រៀន:** ចូរយើងសម្លឹងមើលទៅឲ្យឆ្ងាយបន្តិច អំពីព្រះយេស៊ូវដែលយើងធ្លាប់បានរៀនពីមុនមក គឺថាចំពោះអស់អ្នកណាដែលទទួលជឿថា ព្រះលោហិតរបស់ទ្រង់បានហូរនៅលើឈើឆ្កាង គឺជាលោហិតសម្រាប់គ្របបាំងនូវរាល់អំពើបាបរបស់យើង ហើយក៏បាននាំយើងឈ្លោះទៅរកសម្ព័ន្ធមេត្រីទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ព្រះវរបិតាឡើងវិញ។ គំនិតមួយសែនអស្ចារ្យម្ល៉េះណា! សម្រាប់លោកអប្រាហាំ អ៊ីស្មាអែល និង អ្នកផ្សេងៗទៀតនៅក្នុងរង្វង់គ្រួសាររបស់គាត់ទាំងមូល មិនបានធ្វើអ្វីសោះក្នុងការទទួលយកសម្ព័ន្ធមេត្រីដ៏នៅអស់កល្បជានិច្ចនេះ ដ្បិតដោយសារតែសេចក្ដីស្រលាញ់ដ៏ល្អឥតខ្ចោះនៃទ្រង់បានមកឯលោក អប្រាហាំ ហើយបាននាំគាត់ និង មនុស្សដទៃទៀតក្នុងគ្រួសារគាត់ឲ្យបានទទួលយកនូវសម្ព័ន្ធមេត្រីនេះ គឺត្រូវបានតម្រូវឲ្យទ្រង់ធ្វើជាព្រះជាម្ចាស់របស់ពួកគេ ហើយពួកគេទាំងគ្នានោះត្រូវធ្វើជារាស្ត្ររបស់ព្រះអង្គ។ ដូច្នេះ យើងនឹងបានសិក្សាជាមួយគ្នានៅមេរៀនខាងមុខៗទៀត ពេលនោះយើងនឹងបានឃើញថា ព្រះជាម្ចាស់បានយាងមកឯពួកយើងរាល់គ្នា ដោយទទួលពិធីជ្រមុជទឹក និង រស់ក្នុងចំណោមពួកយើងទាំងប្រកាសប្រាប់ថា ទ្រង់គឺជាព្រះជាម្ចាស់របស់យើង ហើយយើងបានត្រឡប់ទៅជាកូនស្ងួនភ្ងារបស់ទ្រង់តាមរយៈព្រះពរនៃទឹក និង កិច្ចការបម្រើ″ ដោយនៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ″។

**សេចក្ដីអធិស្ឋាន:** ឱព្រះអម្ចាស់អើយ! ព្រះអង្គបានចងសម្ព័ន្ធមេត្រីជាមួយ អ៊ីស្មាអែល និង ទូលបង្គំ គឺព្រះអង្គបានធ្វើឲ្យទូលបង្គំបានក្លាយទៅជាសមាជិកក្នុងគ្រួសារមួយយ៉ាងធំរបស់ព្រះអង្គ ហើយបានហៅទូលបង្គំថាជាកូនស្ងួនភ្ងា ដូច្នេះគឺទ្រង់ដែលជាព្រះវរបិតានៃស្ថានសួគ៌របស់ទូលបង្គំ ទ្រង់គឺជាព្រះអម្ចាស់តែមួយគាត់ សម្រាប់ឲ្យទូលបង្គំថ្វាយបង្គំ និង លើកដម្កើង។ សូមអរព្រះគុណទ្រង់សម្រាប់អំពើប្រកបដោយព្រះគុណនៃទ្រង់ក្នុងជីវិតទូលបង្គំ ជាពិសេសធ្វើឲ្យទូលបង្គំបានដឹងយ៉ាងច្បាស់ថាបានទទួលសេចក្ដីសង្គ្រោះដ៏ពេញលេញតាមរយៈកិច្ចការដែលព្រះអង្គបានធ្វើសម្រាប់ទូលបង្គំ។ សូមទ្រង់ជួយឲ្យទូលបង្គំនៅតែនឹកចាំពីព្រះពររបស់ព្រះអង្គមកលើជីវិតទូលបង្គំផង ជាពិសេសនោះគឺព្រះពរនៃការផ្សះផ្សារទំនាក់ទំនងឡើងវិញជាមួយនឹងព្រះអង្គតាមរយៈអង្គព្រះយេស៊ូវ ជាព្រះសង្គ្រោះរបស់កូន។

## ផ្នែកទី ៦

**កិច្ចការ:** នៅមានអំណោះអំណាងមួយទៀតអំពី អ៊ីស្មាអែល នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២១:៨-២១ ហើយនៅទីបំផុត លោក អប្រាហាំ និង លោកស្រី សារ៉ាក៏បង្កើតបានកូនប្រុសមួយ គឺ អ៊ីសាក់។ សូមអាននូវបទគម្ពីរទាំងនេះ។

**លំហាត់:** មានភាពវឹកវរមួយបានកើតឡើងនៅក្នុងរង្វង់គ្រួសាររបស់លោក អប្រាហាំ។ តើភាពវឹកវរនោះបានកើតឡើងនៅពេលណា?

1. នៅក្នុងខ៨: តើយើងបានសិក្សាអំពីអ្វីខ្លះ? អ៊ីសាក់ក៏បានចម្រើនវ័យធំ នៅពេលដែលអ៊ីសាក់បានផ្ដាច់ដោះ លោក អប្រាហាំបាន ______________________ មួយយ៉ាងធំ។
2. នៅក្នុងខ៩: តើលោកស្រី សារ៉ា បានសង្កេតមើលទៅលើអ្វី __________________ __________________________អត្តចរិតរបស់ម្ដាយដែលបានផ្ដល់ឲ្យកូនប្រុស។
3. នៅក្នុងខ១០: តើលោកស្រី សារ៉ា បានទាមទារឲ្យប្ដីរបស់គាត់ធ្វើអ្វី? ____________ ________________________________________________________
4. នៅក្នុងខ១១: លោក អប្រាហាំ មានការពិបាកក្នុងចិត្តយ៉ាងខ្លាំង ក្រោយពីរ អ៊ីស្មាអែល កូនប្រុសរបស់គាត់បាន ___________________________________________។
5. នៅក្នុងខ១២: តើសេចក្ដីណែនាំរបស់ព្រះជាម្ចាស់ចំពោះលោក អប្រាហាំយ៉ាងដូចម្ដេច? _ ________________________________________________________ __________________________ លុះដល់ពេលដែល អ៊ីសាក់ កូនប្រុសរបស់លោក អប្រាហាំ និង លោកស្រី សារ៉ា ត្រូវបានកើតមក ទើបសេចក្ដីសន្យាបានសម្រេចពិតប្រាកដ។
6. នៅក្នុងខ១៣: តើព្រះជាម្ចាស់បានសន្យានឹងលោក អប្រាហាំ យ៉ាងដូចម្ដេចអំពី អ៊ីស្មាអែល? ________________________________________________________ ________________________________________________________

**សេចក្ដីបង្រៀន:** ព្រះជាម្ចាស់មិនបានបំភ្លេច អ៊ីស្មាអែល ចោលនោះឡើយ ឬ ក៏បំភ្លេចសេចក្ដីសន្យារបស់ទ្រង់ជាមួយនឹងនាង ហាហ្គា កាលនាងនៅវាលរហោស្ថាននោះដែរ គឺអស់រយៈពេលជាច្រើនឆ្នាំមុនពេលដែលនាងមានផ្ទៃពោះម្ល៉េះ! ឥឡូវនេះ លោកស្រី សារ៉ាបាន ប្រាប់ដល់លោក អប្រាហាំ កម្ចាត់ នាង ហាហ្គា និង កូនប្រុសរបស់នាងចេញពីគ្រួសាររបស់គាត់ ព្រះជាម្ចាស់ក៏បានណែនាំឲ្យគាត់ធ្វើតាមការស្នើសុំរបស់ប្រពន្ធគាត់ចុះ លុះដល់ពេលព្រឹកនាថ្ងៃបន្ទាប់ លោក អប្រាហាំ បានយកអាហារខ្លះ និង ទឹកទៅឲ្យនាង ហាហ្គារួចក៏ប្រាប់ឲ្យនាង រួមជាមួយនឹងកូនប្រុសគឺ អ៊ីស្មាអែលចាកចេញទៅ។

នៅត្រង់ខ ១៤ គឺត្រូវបានបញ្ចប់នៅចុងខដោយពាក្យថា "នាង ______________________ និង ______________________នៅក្នុង ____________________ នៃ _____________"។

វាជារឿងស្រួលទេ សម្រាប់យើងដោយគ្រាន់អានសាច់រឿងនោះ ប៉ុន្តែ រឿងដែលពិបាកនោះគឺ ឪពុក និង កូនត្រូវបែកគ្នា ពិតជាគួរឲ្យស្រណោះណាស់ ជាពិសេសគឺក្នុងនាមជាឪពុក តែត្រូវបណ្តេញកូនរបស់ខ្លួនឯងឲ្យចាកចេញទៅឆ្ងាយ ដោយគ្មានថ្ងៃនឹងបានឃើញមុខគ្នាទៀតនោះ តើពួកគេនឹងត្រូវទៅជាយ៉ាងណា? ដ្បិតរយ:ពេល ១៣ ឆ្នាំ ដែលឪពុកកូនពួកគេទាំងពីរបានរស់នៅជាមួយគ្នា។ អ៊ីស្មាអែលប្រាកដជាបានផ្តល់ភាពរីករាយដល់ អប្រាហាំជាឪពុកមិនតិចទេ ដែលគេកំពុងស្ថិតក្នុងវ័យដ៏គួរឲ្យស្រលាញ់។ មកដល់ត្រឹមនេះ ទំនាក់ទំនងរបស់ម្តាយ និង កូន ទាំងពីរនាក់ត្រូវបានបញ្ចប់ ដ្បិតពួកគេត្រូវបានបង្ខំឲ្យចាកចេញទៅ ដោយធ្វើដំណើរសំដៅទៅឯវាលរហោស្ថានមួយនៃទីក្រុង បៀរសេបា។ ជាការពិតលោក អប្រាហាំ បានដឹងយ៉ាងច្បាស់ណាស់ថា អាហារ និង ទឹកត្រឹមតែបន្តិចបន្តួចប៉ុណ្ណឹងមិនបានយូរប៉ុន្មានឡើយ ប្រាកដជានឹងត្រូវអស់ជាមិនខាន។

**លំហាត់:** ឥឡូវនេះយើងនឹងតាមដានន្ទូវសាច់រឿងរបស់ម្តាយ និង កូនគេទាំងពីរនាក់នៅក្នុងវាលរហោស្ថានជាបន្តទៅទៀត។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២១:១៥ យើងនឹងសិក្សាអំពីនាង ហាហ្កា នៅពេលដែលនាង អស់ទឹកសម្រាប់ផឹក គឺនាងបានយកកូនប្រុសរបស់នាងទៅដាក់នៅក្រោមគុម្ពបន្លា។

1. នៅក្នុងខ ១៦: តើបន្ទាប់មកទៀតនាងហាហ្កានឹងធ្វើដូចម្តេច? តើនាងមានគំនិតបែបណា?
   ______________________________________________________________
   ______________________________________________________________
2. នៅក្នុងខ ១៧: មានគេបានឮសម្លេងកូនប្រុសរបស់នាងកំពុងយំ "ហើយព្រះជាម្ចាស់ ____ ______________________ ______________________ របស់កូនប្រុសនាង។
   ហាហ្កា! តើនាង ___________________________ កុំខ្លាចអី! ព្រះជាម្ចាស់បាន ___ ______________________________________ នៃ __________________
   ដែលជាកន្លែងគាត់នៅ។
3. នៅក្នុងខ ១៨: តើនាងបានទទួលការណែនាំដូចម្តេច? ______________________
   ______________________________________________________________
4. នៅក្នុងខ ១៩: តើព្រះជាម្ចាស់បានបើកសម្តែចឲ្យនាងហាហ្កា ឃើញយ៉ាងដូចម្តេចនៅពេលដែលបានបើកភ្នែកឡើង? ________________________________________
   ពេលនោះ ថង់ទឹកទទេរបស់នាងក៏បានពេញដោយទឹកវិញ រួចនាងក៏យកទៅឲ្យកូនប្រុសរបស់នាងផឹក។

5. នៅក្នុងខ ២០: តើមានអ្វីកើតឡើងចំពោះអ៊ីស្មាអែល? ព្រះជាម្ចាស់បានគង់នៅជាមួយនឹងក្មេងប្រុសនោះតាំងតែពីដើមមកម្ល៉េះ។
   ក. តើគេបានទៅរស់នៅឯណា? ______________________
   ខ. តើគេនឹងបានក្លាយទៅជាអ្វី? ______________________
   គ. តើវាលរហោស្ថានដែលគេបានរស់នៅមានឈ្មោះអ្វី? ____________
   ឃ. តើស្ត្រីសាសន៍អេស៊ីបម្នាក់នេះរបស់ប្រពន្ធឲ្យកូនប្រុសរបស់នាងនៅឯណា? ______

   ______________________________________________

## ផ្នែកទី ៧

**សេចក្តីបង្រៀន:** សេចក្តីស្រលាញ់ និង ការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ចំពោះអ៊ីស្មាអែលគឺជាសម្ព័ន្ធមេត្រី។ ប្រហែលជាយើងសួរថា "ហេតុអ្វី?" ការពិតអ៊ីស្មាអែល និង ម្តាយរបស់គាត់ត្រូវរងការមើលងាយ និង សើចចំអកពីសំណាក់លោក អប្រាហា និង លោកស្រី សារ៉ាដោយគ្មានក្តីមេត្តា។ ចុះតើហេតុអ្វីបានជា អ៊ីស្មាអែល ត្រូវបានទទួលនូវក្តីស្រលាញ់ និង ការផ្គត់ផ្គង់ពីព្រះជាម្ចាស់សម្រាប់ជីវិតរបស់គេដែរ? នៅក្នុងព្រះគម្ពីរ លោកុប្បត្តិ ២១:១៣ បានប្រាប់យើងអំពីហេតុផលថាហេតុអ្វីបានព្រះជាម្ចាស់នៅតែមានភាពស្មោះត្រង់ជាមួយនឹងគាត់ "ព្រោះថាទ្រង់នឹងធ្វើជា ____________ របស់អ្នក"។ គាត់គឺជាកូនប្រុសម្នាក់របស់លោក អប្រាហាំ ដែលបានទទួលពិធីកាត់ស្បែក និង ត្រូវបានជាប់នៅក្នុងសម្ព័ន្ធមេត្រីដ៏នៅអស់កល្បដែរ។ ហើយ អ៊ីស្មាអែលក៏ទទួលបានសេចក្តីសន្យាពីព្រះជាម្ចាស់ដែរថាតាមរយៈគាត់ នឹងមានជាតិសាសន៍មួយដ៏ធំកើតឡើង នេះគឺជាបន្ទូលសន្យារបស់ព្រះជាម្ចាស់ ជាមួយនឹងគាត់។

ព្រះគុណ និង សេចក្តីស្រលាញ់ដ៏មហិមារបស់ព្រះជាម្ចាស់បានបង្ហូរមកសម្រាប់យើងគ្រប់ៗគ្នា។ ប៉ុន្តែមានមនុស្សជាច្រើននៅលើសកលលោកនេះមិនបានទទួលស្គាល់ថាការទាំងអស់នោះមកពីព្រះជាម្ចាស់ទេ តែតាមការពិតព្រះជាម្ចាស់បានប្រទានសេចក្តីស្រលាញ់របស់ទ្រង់មក គឺសម្រាប់ទាំងមនុស្សល្អ និង មនុស្សទុច្ចរិត ឧបមាដូចជាទឹកភ្លៀង គឺទ្រង់បានប្រទានទឹកភ្លៀងមកសម្រាប់មនុស្សគ្រប់ៗរូប។ ក្តីស្រលាញ់របស់ព្រះអង្គគឺអស្ចារ្យណាស់ស្ទើរតែយើងមិនអាចទទួលយកបាន។ សេចក្តីស្រលាញ់បាន ចាប់ផ្តើមចេញពីព្រះអង្គមក ហើយក៏ចែករំលែកបន្តរហូតមកដល់នឹងពេលសព្វថ្ងៃ។ នៅក្នុងព្រះគម្ពីរ ១ យ៉ូហាន ៤:១៩ បានចែងថា "យើងរាល់គ្នាត្រូវតែមានសេចក្តីស្រលាញ់ ដ្បិតព្រះជាម្ចាស់បានស្រលាញ់យើងជាមុន"។

**ការទន្ទេញចាំមាត់:** នេះគឺជាពេលវេលាមួយទៀតហើយដែលនាំមកជូនលោកអ្នកនៅបទគម្ពីរចងចាំ។ ព្រះគម្ពីរ រ៉ូម ៦:៣-៤ បានរំលឹងឲ្យយើងដឹងថា យើងមានជីវិតថ្មី ព្រោះថាយើងបានទទួល ពិធីបុណ្យជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានសុគត់ជំនួសអំពើបាបរបស់ពួកយើង តែបីថ្ងៃក្រោមមក ទ្រង់បានរស់ពីសុគត់ឡើងវិញ ដូច្នេះយើងម្នាក់ក៏ត្រូវបានកើតជាថ្មីដូចទ្រង់មានព្រះជន្មរស់ឡើងវិញអញ្ចឹងដែរ! ជាការចាប់ផ្តើមលោកអ្នកត្រូវកត់ត្រាទុកនៅក្នុងសៀវភៅរបស់លោកអ្នកជាមុនសិន ហើយចំណាយពេលពេញមួយសប្តាហ៍ដើម្បីទន្ទេញបទគម្ពីរនេះឲ្យបានចាំស្ទាត់ រួចសឹមឆ្លើយទៅនឹងសំនួរដូចតទៅនេះ:

1. តើមានកត្តាអ្វីខ្លះដែលបានធ្វើឲ្យលោកអ្នកបានដឹងថាជីវិតលោកអ្នកត្រូវបានរួចពីអំពើបាប និង បានទទួលចំណែកក្នុងសម្ព័ន្ធមេត្រីដ៏នៅអស់កល្បនៃជីវិតថ្មីរបស់លោកអ្នក ក្រោយពីបានរួចចេញផុតពីអំពើបាប? ______________________________

______________________________

______________________________

2. តើលោកអ្នកធ្វើការឆ្លុះបញ្ចាំងយ៉ាងដូចម្តេចចំពោះរឿងរ៉ាវលោក អប្រាហាំ និង អ៊ីស្មាអែល ដែលពួកគេទាំងពីរមិនបានសាងគុណសម្បត្តិអ្វីសោះ ផ្ទុយទៅវិញពួកគេបានទទួលព្រះពរពីព្រះជាម្ចាស់ ហើយទ្រង់ថែមទាំងប្រកាសប្រាប់ថា ទ្រង់នឹងធ្វើជាព្រះរបស់ពួកគេ ហើយពួកគេត្រូវធ្វើជាប្រជារាស្ត្រផ្ទាល់របស់ទ្រង់?______________________________

______________________________

______________________________

នៅក្នុងសៀវភៅកត់ត្រារបស់លោកអ្នកគឺមានកាតខគម្ពីរចងចាំ រ៉ូម ៦:៣-៤! ចូរសរសេរនូវកិច្ចការផ្ទាល់ខ្លួនរបសលោកអ្នកទុក។ លោកអ្នកធ្លាប់សិក្សានូវខគម្ពីរទាំងនេះរួចម្តងទៅហើយ ដូច្នេះ ចូរលោកអ្នកធ្វើការបញ្ជាក់យ៉ាងណាដែលថាខ្លួនមានសេរីភាពពីអំពើបាប ហើយរួចផុតពីភាពអាម៉ាស់ និង ការជាប់ទោស ឈានមកដល់ការទទួលនូវជីវិតថ្មីក្នុងសម្ព័ន្ធមេត្រីដ៏នៅអស់កល្បជានិច្ច។

**សេចក្តីអធិស្ឋាន:** ឱព្រះអម្ចាស់អើយ! សេចក្តីស្រលាញ់ដ៏ពេញបរិបូរណ៍របស់ទ្រង់បានបង្ហូរមកយើងខ្ញុំទាំងអស់គ្នា។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ! ទូលបង្គំបានឃើញក្តីស្រលាញ់មួយនេះចេះតែថ្មីឡើងៗជារៀងរាល់ថ្ងៃ មកកូនស្ងួនភ្ងារបស់ព្រះអង្គ និង អស់អ្នកដែលនៅជុំវិញទូលបង្គំផងដែរ។ សូមអរព្រះគុណទ្រង់ ដែលបានជួយឲ្យទូលបង្គំជឿជាក់ថាគ្រប់ព្រះគុណ

របស់ទ្រង់ទាំងអស់សម្រាប់សេចក្តីត្រូវការក្នុងជីវិតទូលបង្គំបឹងបាននៅជាមួយទ្រង់ជារៀង
រហូតតទៅ _______________________________________________

## ផ្នែកទី ៨

**រំលឹកសារឡើងវិញ:** ចូរយើងចំណាយពេលខ្លះដើម្បីរំលឹកមេរៀនសារឡើងវិញ! យើងទាំងអស់គ្នាត្រូវណែនាំឲ្យបានស្គាល់មនុស្ស និង ទីកន្លែងជាច្រើនរួមហើយ។ ដូច្នេះ ខាងក្រោមនេះគឺជាតារាងមួយដែលជួយឲ្យលោកអ្នក កាន់តែមានភាពងាយស្រួលក្នុងការចងចាំ! តារាងជួរទី ១ គឺជាឈ្មោះទីកន្លែង តារាងជួរទី ២ លោកអ្នកត្រូវបំពេញឈ្មោះមនុស្សឲ្យបានត្រឹមត្រូវទៅតាមទីតាំងនោះ ហើយតារាងជួរ លោកអ្នកត្រូវសរសេររៀបរាប់នូវអ្វីៗដែលបានសិក្សារទាក់ជាមួយមនុស្ស និង ទីកន្លែងដូចបានផ្តល់ឲ្យស្រាប់។

| ឈ្មោះទីកន្លែង/ឈ្មោះមនុស្ស | | អ្វីដែលខ្ញុំបានសិក្សា |
|---|---|---|
| ហារ៉ាន<br>(លោកុប្បត្តិ ១២:៤) | | |
| អាប់រ៉ាម<br>(លោកុប្បត្តិ ១១:២៧, ៣១) | | |
| សារ៉ាយ<br>(លោកុប្បត្តិ ១២:៥) | | |
| អ៊ើរនៃទីក្រុងកាដ<br>(លោកុប្បត្តិ ១១:៣១) | | |
| កាណាន/សាសន៍កាណាន<br>(លោកុប្បត្តិ ១០:៦, ១៥-១៩) | | |
| លោក ឡុត<br>(លោកុប្បត្តិ ១២:៥) | | |
| នាង ហាហ្គា<br>(លោកុប្បត្តិ ១៦:១) | | |
| អ៊ីស្មាអែល<br>(លោកុប្បត្តិ ១២:៥) | | |
| អប្រាហាំ និង សារ៉ា<br>(លោកុប្បត្តិ ១៧:៥, ១៥-១៦) | | |
| ហេប្រុន<br>(លោកុប្បត្តិ ១៣:១៨) | | |

# មេរៀនទី ៣

# តើមានអ្វីខ្លះដែលលំបាកព្រះជាម្ចាស់ធ្វើមិនកើត?

## លោកុប្បត្តិ ១៨ - ភ្ញៀវពិសេសទាំងបីនាក់

---

## មាតិកាសំខាន់ៗក្នុងមេរៀនទី ៣

**ទិដ្ឋភាពទូទៅៈ លោកុប្បត្តិ ១៨**

**សេចក្តីណែនាំ**

**មេរៀនទី៣: លោកុប្បត្តិ ១៨**


- ការធ្វើគារវកិច្ចរបស់លោក អប្រាហាំ ............................
- លោកស្រី សារ៉ាផ្ទុះសំណើច........................................
- ការអនុវត្តន៍: គារវកិច្ច ...............................................

# សេចក្ដីណែនាំ

ជាការពិតណាស់ ពួកតយើងទាំងអស់គ្នាអាចគិតអំពីរឿងរ៉ាវមួយចំនួន ដែលមានការលំបាកចំពោះយើង។ ឬអាននិយាយបានម្យ៉ាងថា មានរឿងរ៉ាវខ្លះៗដែលយើងមិនធ្វើបាន ព្រោះថាមនុស្សទាំងអស់សុទ្ធសឹងតែមានដែនកំណាង់។ នៅក្នុងមេរៀននេះ លោក អប្រាហាំបានប្រឈមមុខជាមួយនឹងសំនួរថា "តើមានអ្វីខ្លះដែលមានការលំបាកសម្រាប់ព្រះជាម្ចាស់?" ជាការជាក់ស្ដែងគឺគ្មានការអ្វីមួយដែលលំបាកចំពោះព្រះជាម្ចាស់ទាល់តែសោះ យ៉ាងនេះក៏ព្រោះតែ ទ្រង់គឺជាព្រះអទិករដែលបានបង្កើតផ្ទៃមេឃ និង ផែនដី។

នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក ១៨ យើងត្រូវបានបង្ខំឲ្យពិចារណាអំពីស្ថានភាពរបស់លោកអប្រាហាំ និង លោកស្រីសារ៉ាដែលពួកគេត្រូវប្រឈមមុខ។ ម្យ៉ាងទៀតពួកគេទាំងពីរនាក់មានវ័យកាន់តែចាស់ណាស់ទៅហើយ ជាពិសេសនោះគឺលោកស្រី សារ៉ា គាត់បានឈានដល់វ័យមិនអាចមានផ្ទៃពោះបានទៀតផង។ លោកស្រី សារ៉ា បានផ្ទុះសំណើចចំពោះការចោទសួរដោយគ្មានសេចក្ដីជំនឿថា "តើខ្ញុំនឹងអាចមានកូនដូចម្ដេចបានទៅ បើខ្ញុំកាន់តែចាស់ណាសទៅហើយនោះ?" ហើយព្រះជាម្ចាស់ទ្រង់មានព្រះបន្ទូលថា "តើមានអ្វីដែលលំបាករហូតយើងធ្វើមិនបាន?"។

ព្រះជាម្ចាស់នៅតែមានភាពស្មោះត្រង់ ហើយខ្ជាបខ្ជួនក្នុងសេចក្ដីសន្យារបស់ទ្រង់ដដែល គឺលោក អប្រាហាំ និង លោកស្រីសារ៉ាថាពួកគេនឹងបង្កើតបានកូនប្រុសម្នាក់។ "លោក អប្រាហាំ គាត់មានចិត្តជឿលើព្រះជាម្ចាស់ទាំងស្រុង ដូច្នេះហើយទើបបានជាព្រះអង្គបានរាប់គាត់ថាគឺជាមនុស្សសុចរិតម្នាក់។" អ្វីៗគ្រប់យ៉ាងស្ថិតនៅក្នុងស្ថានភាពមួយ ដែលមិនគួរឲ្យជឿទាល់តែសោះ ប៉ុន្តែលោក អប្រាហាំនៅតែជឿជាក់លើព្រះដដែល។ អ្វីៗដែលគាត់ បានជឿលើព្រះជាម្ចាស់មានដូចជា គាត់ជឿថាព្រះនឹងគោរពតាមសេចក្ដីសន្យារបស់ទ្រង់ គាត់ជឿលើព្រះបន្ទូលទ្រង់គាត់នឹងមានកូនប្រុសមួយ ព្រះអង្គបានប្រទានក្ដីសង្ឃឹមដល់គាត់ ជាងនេះទៅទៀតនោះ គឺលោក អប្រាហាំ នៅតែជាថាព្រះជាម្ចាស់មិនដែលគាត់ឡើយ (ហេព្រើរ ៦:១៨)។

ជាការពិតណាស់ថា គ្មានកិច្ចការណាមួយដែលលំបាកសម្រាប់ព្រះជាម្ចាស់នោះឡើយ! ប្រសិនបើព្រះជាម្ចាស់បានលេចមកឯផ្ទះរបស់លោកអ្នកនៅថ្ងៃនេះ តើលោកអ្នកនឹងស្វាគមន៍ ហើយយាងទ្រង់ចូលខាងក្នុងផ្ទះដែរឬទេ? អ្វីៗដែលមាននៅក្នុងជីវិតរបស់លោក ហើយគិតថាមិនអាចទៅរួចបានទេ នោះទ្រង់ប្រាកដជានឹងមានព្រះបន្ទូលថា វាអាចទៅរួចបាន។ វាគឺជាការអត់ទោសចំពោះរឿងរ៉ាវខ្លះៗពីអតីតកាល ឬ ជាការស្ដារឡើងវិញចំពោះសេចក្ដីស្រលាញ់ដែលបានស្លាប់បាត់ទៅពីពេលមុន។ នេះប្រហែលជាអ្វីៗដែលមិនអាចទៅរួចក្នុងជីវិតរបស់លោកអ្នកនឹងត្រូវបានធួរស្បើយពីការបំផ្លាញសេចក្ដីស្រលាញ់

ជាមិនខាន។ ចូរលោកអ្នកធ្វើការសម្រេចចិត្តថាតើមានអ្វីខ្លះដែលមិនមែនជាការលំបាកសម្រាប់ព្រះជាម្ចាស់?

ប្រហែលមិនមែនមានតែមួយនោះទេ ដែលតម្រូវឲ្យលោកអ្នកសញ្ជឹងគិត ថាអ្វីខ្លះដែលគ្មានការលំបាកសម្រាប់ព្រះជាម្ចាស់។ គឺមានតែអំពើបាបពីអតីតកាលរបស់យើងតែប៉ុណ្ណោះដែលជាការពិបាកបំភ្លេចចោល តែព្រះជាម្ចាស់ទ្រង់មិនបាននៅចាំទៀតឡើយ (យេរេមា ៣១:៣៤)។ ចូរស្វែងរកឲ្យឃើញនូវសេចក្តីស្រលាញ់ដ៏អស់សង្ឃឹម នោះទ្រង់នឹងប្រទានវិញនូវសេចក្តីស្រលាលពីដ៏នៅអស់កល្ប (យេរាមា ៣១:៣)។ សុវត្ថិភាពនៃទំនាក់ទំនងមួយនឹងត្រូវបានការពារយ៉ាងតឹងរឹងពី ភាពឯកោ ការដែលមានអារម្មណ៍ថាត្រូវបានគេបោះបង់ចោល ដោយព្រះអង្គប្រទានសេចក្តីសន្យាថា ទ្រង់នឹងមិនដែលទុកអ្នកចោល ឬបោះបង់អ្នកចោលម្តងណាឡើយ (ហេព្រើរ ១៣:៥)។ វាមិនមែនមានតែប៉ុណ្ណឹងនោះឡើយ គឺជាសេចក្តីសន្យារបស់ទ្រង់។ ព្រះជាម្ចាស់មិនដែលកុហក់ម្តងណាឡើយ! ហើយព្រះបន្ទូលទ្រង់នោះទៀតសោត គឺជាសេចក្តីពិត តាមរយៈសេចក្តីពិតនោះឯង ដែលនឹងបញ្ជាក់ថាទ្រង់គឺជានរណា។

តើវាការលំបាកសម្រាប់ព្រះជាម្ចាស់ដែរទេ ក្នុងដែលទ្រង់ស្រលាញ់ពួកយើងទាំងអស់គ្នាជាអ្នកបានបែកចេញពីទ្រង់ ហើយបានជ្រើសរើសដំណើរជីវិតតាមបែបលោកីយ៍ (អេភេសូរ ២:១-១០)? តើវាជាការលំបាកសម្រាប់ព្រះជាម្ចាស់ដែលត្រូវមកស្រលាញ់យើង គឺជាមនុស្សបានបែកចេញពីទ្រង់ មិនតែប៉ុណ្ណោះសោតថែមទាំងតាំងខ្លួនធ្វើជាសត្រូវនឹងទ្រង់ផងនោះ? តើវាជាការលំបាកដែរឬទេ ដែលត្រូវមកស្រលាញ់យើង យើងធ្វើឲ្យយើងបានរស់នៅជាមួយទ្រង់ជារៀងរហូតអស់កល្បនោះ? តើវាជាការលំបាកសម្រាប់យើងក្នុងការទទួលអំណោយដោយឥតគិតថ្លៃជាជីវិតអស់កល្បជានិច្ចដែលមាននៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទ? តើវាជាការលំបាកដែរឬទេសម្រាប់យើង ក្នុងទទួលជឿថាទ្រង់គឺជាអ្នកបង្កើតយើងឲ្យមានជីវិតជាថ្មីក្នុងអង្គព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យយើងបានធ្វើកិច្ចការល្អៗ? ចូរអរព្រះគុណដល់ព្រះអង្គដែលទ្រង់បានមានព្រះបន្ទូលថា "តែទ្រង់មានព្រះបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកំឡាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្តីកំសោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឲ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ"។ (២ កូរិនថូស ១២:៩)។

## ផ្នែកទី ១

**សេចក្ដីបង្រៀន:** យើងបាននឹងទទួលបានចំណេះដឹងថ្មីជាច្រើន នៅពេលណាយើងបានស្ដាប់នូវរឿងរ៉ាវរបស់ពួកគេ។ តាមធម្មតានៅពេលណាដែលយើងចែកចាយនូវបទពិសោធន៍ស្រដៀងគ្នា ឬ យើងចំណាយពេលវេលាស្ដាប់ការចែកចាយរបស់អ្នកណាម្នាក់ នោះយើងនឹងកាន់តែបានស្វែងយល់ពីអ្នកនោះតាមរយៈការរៀបរាប់របស់គេជាប្រាដក ដល់ពេលនោះក៏ចាប់ស្គាល់កាន់តែច្បាស់ ទីបំផុតអាចក្លាយទៅជាមិត្តដ៏ជិតស្និទជាមួយគ្នាក៏ថាបានដែរ។ នៅក្នុងមេរៀននេះ យើងនឹងសិក្សាសាច់រឿង ៤ ផ្សេងៗពីគ្នា ដែលទាក់ទងទៅនឹងលោក អប្រាហាំ និង ក្រុមគ្រួសាររបស់គាត់។ សាច់រឿងទាំងនេះ នឹងត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក ១៨-២២។ ក្នុងខណៈពេលដែលយើងបានអានរឿងទាំងនេះរួច យើងនឹងសួរនូវសំណួរបីដូចខាងក្រោម:

1. តើអ្វីទៅដែលជា**<u>អង្គហេតុសំខាន់</u>**ក្នុងរឿងនេះ? ឧទាហរណ៍: តើតួអង្គសំខាន់នៅ ក្នុងរឿងនេះគឺជានរណា? តើសាច់រឿងនេះបានកើតឡើងនៅឯណា? តើមានអ្វីខ្លះដែលពិតជាបានកើតឡើងនៅក្នុងរឿងនេះ?
2. តាមរយៈរឿងនេះ តើមាន**<u>សេចក្ដីពិត</u>**បែបណាខ្លះអំពីព្រះជាម្ចាស់ និង អំពីមនុស្សដែលយើងគប្បីត្រូវសិក្សា?
3. តាមរយៈរឿងនេះ តើមានអ្វីខ្លះដែលយើងត្រូវយកទៅ**<u>អនុវត្តតាម</u>**សម្រាប់ការរស់នៅប្រចាំថ្ងៃ?

ជាការបន្ថែម អ្នកត្រូវបានលើកទឹកចិត្តឲ្យចំណាយពេលអាចព្រះគម្ពីរនៅចន្លោះសាច់រឿងនិមួយៗ។ ចូរចាំថានៅក្នុងការសិក្សានេះ មិនបានរាប់បញ្ចូលការកត់ត្រា ឬ ការកត់ចម្លងពីព្រះគម្ពីរឡើយ ប៉ុន្តែយ៉ាងហោចណាស់ក៏មានការផ្ដល់ជូននូវខយោងនៅខាងក្រោមនៃទំព័រព្រះគម្ពីររបស់លោកអ្នក។ ដំណើរផ្សងព្រេងរុករករបស់យើងនឹងត្រូវចេញដំណើរបន្តទៅមុខទៀតក្នុងពេលនេះហើយ។ នៅក្នុងសាច់រឿងដំបូងគេនេះយើងនឹងបានសិក្សាអំពីភ្ញៀវពិសេសបីនាក់ ដែលបានមកសួរសុខទុក្ខលោក អប្រាហាំ និងភរិយារបស់គាត់ ការមកសួរសុខទុក្ខនឹងអាចមានការផ្លាស់ប្ដូរឆាកជីវិតរបស់ពួកគេជារៀងរហូត។

**កិច្ចការ:** ចូរលោកអ្នកអាចព្រះគម្ពីរលោកុប្បត្តិ ១៨:១-១៥

**លំហាត់:** ការស្វែងរកឲ្យឃើញនូវអង្គហេតុក្នុងសាច់រឿងនេះ....

1. លោកុប្បត្តិ ១៨:១ ខ្ញុំឃើញថាអង្គហេតុនៃសាច់រឿងកាន់តែច្បាស់បន្តិចហើយ តើនរណាដែលបានលេចមកឯលោក អប្រាហាំ? ________________________________
2. តើពេលនោះលោក អប្រាហាំកំពុងនៅឯណា ហើយគាត់ធ្វើអ្វី? ________________

________________________________________________

3. តើនៅថ្ងៃនោះភ្ញៀវបានមកនៅពេលណា? ______________________________

4. លោក អប្រាហាំ បានក្រឡេកឃើញ (ខ២) តើនរណាបានកំពុងឈរនៅជិតគាត់? _____

5. តើគាត់បានធ្វើអ្វីខ្លះនៅពេលដែលគាត់បានឃើញពួកគេ? ____________________

______________________________________________________________

**សំនួរ:** អ្នកដែលមិនជួយធ្វើអ្វីបាន យ៉ាងហោចណាស់ក៏ជាចោទជាសំនួរបានដែរ ដូចជា!

- តើបុរសទាំងនោះគឺជានរណា?
- តើលោក អប្រាហាំ បានស្គាល់ពួកគេដែរទេ?
- ក្នុងខ២ តើគាត់បានធ្វើទៅតាមទម្លាប់របស់គាត់ដែរទេ?
- តើគាត់បានធ្វើដូច្នោះចំពោះគ្រប់គ្នាដែលបានមកសួរសុខទុក្ខគាត់ដែរឬទេ?
- តើអ្នកអាចនឹងមានសំនួរបែបណាទៀត? ____________________________
- តើអ្នកមានសំនួរអ្វីផ្សេងទៀតដែរទេ? ______________________________

**សំងាត់បន្ថ:** អង្គហេតុសាច់បន្ថែម...

1. តើលោក អប្រាហាំ បានជូនទៅភ្ញៀវ ក្នុងខ៣? ___________________________
2. ការទទួលដោយភាពកក់ក្ដៅបានបន្តនៅក្នុងខ៤: ___________________________
3. ការទទួលរាក់ទាក់ដោយការបម្រើ (ខ៥)! _______________________________

## ការឆ្លុះបញ្ចាំង:

- បដិសណ្ឋារកិច្ច ឬ ការទទួលស្វាគមន៍ដោយភាពរាក់ទាក់គឺជាការរំពឹងចង់បានរបស់អ្នកធ្វើដំណើរឆ្លងកាត់ ពីទឹកដី ភូមិដ្ឋានមួយទៅកន្លែងមួយទៀត។ តើបានសង្កេតឃើញថាលោក អប្រាហាំ មានអកប្បកិរិយាដូចម្ដេចក្នុងការទទួលភ្ញៀវរបស់គាត់? _______

  ______________________________________________________________

- លោក អប្រាហាំ បានបន្ទាប់ខ្លួននៅចំពោះភ្ញៀវរបស់គាត់។ គាត់បានដឹងពីតម្រូវការខាងរូបកាយរបស់ពួកគេ ដូច្នេះ គាត់បានជូនទឹកដើម្បីលាងជើងដែលនឿយហត់ពីការធ្វើដំណើរផ្លូវឆ្ងាយ ហើយគាត់បានរៀបចំអាហារឲ្យពួកគេបរិភោមុនបន្តដំណើរទៅមុខទៀត នេះគឺជាបដិសណ្ឋារកិច្ចដ៏ស្រស់ស្រាយសម្រាប់អ្នកដទៃ។ គំនិតរបស់អ្នកវិញ: _

  ______________________________________________________________

  ______________________________________________________________

  ______________________________________________________________

## ផ្នែកទី ២

**លំហាត់បន្ថែម:** អង្គហេតុនៃសាច់រឿងនៅតែបន្ត...

1. ចូរធ្វើការកត់សម្គាល់នូវអ្វីដែលលោក អប្រាហាំ ធ្វើជាបន្តទៀត! តើគាត់បានប្រាប់ឲ្យលោកស្រីសារ៉ាធ្វើអ្វីខ្លះ? ________________
2. គាត់បានជ្រើសរើសយកកូនគោឈ្មោលមួយមក រួចតើគាត់ឲ្យអ្នកបម្រើធ្វើអ្វី? ________________

________________

3. បន្ទាប់មកទៀត តើយកអ្វីទៅជូនដល់ភ្ញៀវរបស់គាត់ទុកជាការបម្រើជាមួយនឹងអាហារ? ________________

________________

4. លោក អប្រាហាំបានរៀបចំម្ហូបអាហារដាក់ខាងមុខភ្ញៀវរួចរាល់ហើយ ក្នុងពេលដែលភ្ញៀវកំពុងតែបរិភោគ តើគាត់បានធ្វើអ្វី? ________________

________________

គាត់បានត្រៀមខ្លួនរួចជាស្រេចក្នុងការបម្រើពួកគេ ព្រោះគាត់ចង់បានដឹងច្បាស់ថាអ្វីដែលពួកគេត្រូវការមានសព្វគ្រប់ហើយឬនៅ។ គាត់បានផ្តល់បដិសណ្ឋារកិច្ចដ៏ឧស្សាហ៍ចំពោះភ្ញៀវគ្រប់ៗគ្នា គឺគាត់បានខ្នះខ្នែងក្នុងការផ្តល់ជូននូវអ្វីដែលល្អៗ ស្រស់ៗដល់ពួកគេ។

5. ការសន្ទនាបានចាប់ផ្តើមឡើងនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១៨:៨....
   ក. តើពួកគេបានសួរអ្វី? ________________
   ខ. តើលោក អប្រាហាំ បានឆ្លើយតបដូចម្តេច? ________________
   គ. តើមានសេចក្តីសន្យាដូចម្តេចនៅក្នុងខ១០? ________________

________________

6. ពួកគេបានរង់ចាំតាមសេចក្តីសន្យាជាច្រើនឆ្នាំបានកន្លងផុតទៅ រហូតដល់ពួកគេទាំងពីរនាក់បានឈានដល់វ័យចាស់មិនអាចមានកូនបាន។ ពេលវេលាចេះតែកន្លងផុតទៅជាបន្តបន្ទាប់ មួយរយៈពេលយូរក្រោយមកទៀត ព្រះជាម្ចាស់ក៏បានលេចមកឯគាត់ម្តងទៀត ហើយមានបន្ទូលប្រាប់គាត់ ត្រូវរង់ចាំដល់ឆ្នាំក្រោយទើប លោកស្រីសារ៉ាអាចមានផ្ទៃពោះ ហើយនឹងបង្កើតកូនប្រុសម្នាក់បាន។ តើលោកស្រី សារ៉ាបានសន្ទនាអំពីរឿងនេះនៅឯណា? (ខ១០) ________________

________________

7. នៅក្នុងខបន្តបន្ទាប់ទៅនេះនឹងរំលឹកយើងថាសេចក្តីសន្យានេះនឹងទៅជាយ៉ាងណា។ តើនៅក្នុងខ ១១ បានប្រាប់អ្វីខ្លះដល់យើង? លោក អប្រាហាំ និង លោស្រីសារ៉ា គឺជា ________________
   ________________ លោកស្រី សារ៉ា គឺជា ________________

8. តើលោកស្រី សារ៉ា បានឆ្លើយតបចំពោះសេចក្តីសន្យារបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច? ____

______________________________________________

9. នៅពេលបានឮបុរសទាំងនោះនិយាយថានាងនឹងបង្កើតបានកូនប្រុសម្នាក់ នោះគាត់បានគិតដូចម្តេច? "បន្ទាប់ពីខ្ញុំ ______________________________

______________________________________________"

10. ខណៈនោះព្រះជាម្ចាស់បានស្នើឲ្យលោក អប្រាហាំ "ហេតុអ្វីបានជា __________

______________________________________________?"

11. លោកស្រីសារ៉ា លែងមានជំនឿថាសេចក្តីសន្យានេះថានឹងកើតទៀតហើយ។ តើព្រះជាម្ចាស់បានឆ្លើយតបចំពោះការផ្ទុះសំណើចរបស់នាងដូចម្តេច (១៤) ______________

______________________________________________

12. ខណៈនោះព្រះជាម្ចាស់បានមានព្រះបន្ទូលជាថ្មីម្តងទៀតថា: "យើងនឹង __________

______________________________________________"

13. មិនតែប៉ុណ្ណោះសោត លោកស្រី សារ៉ារឹតតែធ្វើមានបញ្ហាកាន់ធំដោយគាត់ ________

____________________________ (១៥) រួចក្រោយមកគាត់បានបដិសេធន៏ចោលនូវការប្រព្រឹត្តរបស់គាត់ដោយបាននិយាយថា "ខ្ញុំមិនបាន ______________"

14. ប៉ុន្តែព្រះជាម្ចាស់ទ្រង់បានជួយរំលឹងឲ្យគាត់នឹកឃើញឡើងវិញដោយមានព្រះបន្ទូលថា "________________________________________ គឺមានទ្រង់មួយអង្គប៉ុណ្ណោះដែលបានដឹងច្បាស់ថានាងបានធ្វើអ្វី។ នាង "អស់សំណើចនឹងខ្លួនឯង" គឺមានតែទ្រង់ទេដែលស្តាប់ឮសម្រែកទុក្ខសោកក្នុងដួងចិត្តរបស់នាង ហើយនាំនាងឲ្យជឿលើព្រះបន្ទូលសន្យារបស់ទ្រង់ជាមួយនឹងនាង និង ប្តីរបស់នាង។ឮ

## ផ្នែកទី ២

**តើយើងបានរៀនអ្វីខ្លះអំពីព្រះជាម្ចាស់:** នៅខាងដើមនៃមេរៀននេះ យើងបានប្រាប់ម្តងរួចមកថា នៅពេលណាយើងសិក្សាសាច់រឿងណាមួយ នោះយើងក៏នឹងបានឆ្លុះបញ្ចាំងអំពីព្រះជាម្ចាស់ដែរ គឺបានលាតត្រដាងនូវសេចក្តីពិតអំពីទ្រង់តាមរយៈសាច់រឿងនោះតែម្តង។ ដូច្នេះ នឹងមានសំនួរមួយ សួរថា "តើយើងបានរៀនអ្វីខ្លះអំពីព្រះជាម្ចាស់តាមរយៈសាច់រឿងលោក អប្រាហាំ និង ភ្ញៀវពិសេសទាំងបីនាក់"? បើតាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញខាងព្រះគម្ពីរបានឲ្យយើងដឹង បុរសជាភ្ញៀវទាំងបីនាក់នោះ មានពីរនាក់គឺជាទេវត្តានៃព្រះអម្ចាស់ ហើយម្នាក់ទៀតគឺជាព្រះជាម្ចាស់ផ្ទាល់ដែលទ្រង់យក

សណ្ឋានជាមនុស្ស ដែលមនុស្សលោកអាចមើលឃើញ អាចបរិភោគអាហារ អាចប្រាស្រ័យទាក់ទង និង សន្ទនាជាមួយនឹងមនុស្សបាន (លោក អប្រាហាំ និង សារ៉ា)។

តើការជួបប្រកបគ្នានេះបានប្រាប់អ្វីខ្លះដល់យើងអំពីព្រះជាម្ចាស់? ចូរសរសេរពីគំនិតឆ្លុះបញ្ចាំងរបស់អ្នក

________________________________________________________

________________________________________________________

________________________________________________________

នៅលើកចង់ក្រោយនេះ ព្រះជាម្ចាស់បានមកឯលោក អប្រាហាំ ក្នុងសណ្ឋានមានសាច់មានឈាម (មានរូបរាងកាយដែលអាចមើលឃើញ) ហើយបានបញ្ជាក់ប្រាប់ពួកគេទាំងពីរនាក់ថា នឹងមានកូនប្រុស១។ នៅពេលដែលទ្រង់មានព្រះបន្ទូលប្រាប់ដូច្នោះ ពួកគេបែរជាផ្ទុះសំណើចទាំងក្តីមិនជឿទៅវិញ វាពិតជាមិនអាចកើតឡើងបានទេ! ហើយពេលទ្រង់បញ្ជាក់បន្ថែមអំពីរឿងនេះ នឹងក៏គ្របបាំងសេចក្តីភ័យខ្លាចដោយលាក់បាំងក្នុងភាពបោកបញ្ឆោត។ ទោះបីជាទ្រង់ចាប់បានការប្រព្រឹត្តរបស់នាងក៏ដោយ ក៏នាងមិនបានហាមឃាត់ព្រះជាម្ចាស់ ហើយ ក៏មិនបានធ្វើឲ្យទ្រង់ដកសេចក្តីសន្យារបស់ទ្រង់ពីនាងវិញដែរ។ ចំពោះសេចក្តីជំនឿរបស់លោក អប្រាហាំ និង ភាពគ្មានជំនឿរបស់លោកស្រី សារ៉ាយ៉ាងណាក៏ដោយ តែទ្រង់នៅតែស្មោះត្រង់ចំពោះសេចក្តីសន្យារបស់ទ្រង់ដដែល គឺទ្រង់បានធ្វើទៅតាមអ្វីៗដែលទ្រង់បានមានព្រះបន្ទូលរួចកាលពីពេលមុន។

**ការអនុវត្តន៍ផ្ទាល់ខ្លួន:** មុននឹងធ្វើបញ្ចប់ការសិក្សារបស់យើងនៅក្នុងសាច់រឿងនេះ យើងត្រូវរំលឹកឡើងវិញ ហើយឆ្លុះបញ្ចាំងលើការអនុវត្តន៍ស្តីពីការផ្សារភ្ជាប់ទំនាក់ទំនងរវាងព្រះបន្ទូលទៅនឹងជីវិតរបស់យើង។ យើងចង់រកមធ្យោបាយយ៉ាងដើម្បីធ្វើឲ្យសាច់រឿងនិមួយៗកុំវាគ្រាន់តែជាព្រឹត្តិការណ៍។

1. យើងបានឃើញថាលោក អប្រាហាំ បង្ហាញនូវទឹកចិត្តសប្បុរសយ៉ាងទូលាយចំពោះភ្ញៀវរបស់គាត់។ ការធ្វើបដិសណ្ឋារកិច្ចដ៏ស្និទ្ធស្នាលរបស់គាត់គឺជាគំរូយ៉ាងវិសេសវិសាលមួយ។ តើលោកអ្នកមាននៅនឹកចាំពីការសប្បាយណាមួយដែលមានភាពលេចធ្លោជាងគេនៅក្នុងផ្ទះរបស់លោកអ្នកដូចជាមាននរណាម្នាក់ដែលជាមនុស្សសំខាន់ (VIP) ដែរឬទេ? អ្នកនោះអាចជាចៅហ្វាយរបស់លោកអ្នក គ្រូបង្រៀន អ្នកអប់រំនានា ឬ នរណាម្នាក់ដែលមានមុខងារធំជាដើម។ អាចជាមិត្តសម្លាញ់របស់លោកអ្នកណាមួយដែលនៅឆ្ងាយ ហើយខានមិនបានជួបគ្នារយៈពេលជាយូរ។ ការបង្ហាញនូវបដិសណ្ឋារកិច្ចចំពោះអស់អ្នកណាដែលលោកអ្នកគិតថាជាមនុស្សសំខាន់ នោះវាគឺជាភាពចាំបាច់ ហើយមានសារៈសំខាន់ដ៏មានតម្លៃមួយ។

ឥឡូវនេះចូរចំណាយពេលវេលាខ្លះដើម្បីនឹកគិតដល់ស្ថានភាពមួយ ដែលតម្រូវឲ្យលោកអ្នកបង្ហាញនូវបដិសណ្ឋារកិច្ចចំពោះនរណាម្នាក់ចម្លែក ឬ ជាមនុស្សដែលលោកអ្នកមិនទាន់បានស្គាល់ច្បាស់នៅឡើយ។ តើលោកអ្នកនឹកឃើញគំនិតដូចម្ដេច? តើមនុស្សនៅក្នុងគំនិតរបស់លោកអ្នកគឺជានរណា? តើលោកអ្នកនឹងបង្ហាញបដិសណ្ឋារកិច្ចចំពោះអ្នកនោះយ៉ាងដូចម្ដេច? តើលោកអ្នកនឹងត្រូវធ្វើអ្វីប្លែកពីធម្មតាដែរឬទេ? ____________________

____________________

____________________

2. លោកអ្នកគួរគប្បីត្រូវជ្រើសរើសធ្វើយ៉ាងណា ឲ្យមានភាពសប្បាយរីករាយដល់អ្នកចម្លែកនោះនៅក្នុងពន្លឺមួយដូចបានចែកទុកក្នុងព្រះគម្ពីរ ហេព្រើរ ១៣:២ ដ្បិតនៅក្នុងខគម្ពីរនេះបានលើកទឹកចិត្តលោកអ្នកឲ្យចេះផ្តល់បរិយាកាសរីករាយដល់អ្នកដែលចម្លែក។ តើអ្នកចម្លែកដែលលោកអ្នកបានគិតទុកនោះគឺជានរណា? ____________________

____________________

3. ក្នុងពេលដែលលោកអ្នកកំពុងអានសាច់រឿងនេះសារឡើងវិញ សូមធ្វើការឆ្លុះបញ្ចាំងអំពីព្រះជាម្ចាស់ដែលទ្រង់តែងតែមានភាពស្មោះត្រង់ចំពោះព្រះបន្ទូលរបស់ទ្រង់ជានិច្ច។ ព្រះអង្គតែងតែឆ្លើយតបចំពោះយើងដោយសេចក្ដីស្រលាញ់យ៉ាងលើសលប់ ទោះបីជានៅពេលដែលយើងមានការសង្ស័យក្តី គ្មានជំនឿក្តី អស់សំណើចក្តី ប៉ុន្តែការប្រព្រឹត្តរបស់ទ្រង់មកលើយើងគឺបានប្រកបដោយសេចក្ដីសប្បុរស និង សេចក្ដីស្រលាញ់ជានិច្ច ទោះជាយើងខ្វះសេចក្ដីជំនឿយ៉ាងណាក៏ដោយ។ តើមានអ្វីខ្លះដែលលោកអ្នកបានរៀនពីទ្រង់ គឺសំដៅទៅលើរឿងរ៉ាវមួយចំនួនលោកអ្នកគិតថាវាមិនអាចធ្វើបាន ហើយឆ្លើយតបទៅព្រះអង្គដោយគ្មានជំនឿ ហើយនឹកអស់សំណើចក្នុងចិត្ត? ____________________

____________________

**សេចក្តីអធិស្ឋាន:** ឱព្រះអម្ចាស់អើយ! គឺពិតជាទ្រង់នេះហើយដែលដួងចិត្តទូលបង្គំត្រូវការ យ៉ាងអន្ទះអន្ទែង។ លោក អប្រាហាំបានបន្ទាប់ខ្លួនទទួលរាក់ទាក់ភ្ញៀវរបស់គាត់ ហើយបើកទ្វារផ្ទះស្វាគមន៍ពួកគេដោយសេចក្ដីស្រលាញ់។ ទូលបង្គំដឹងថាព្រះអង្គបានស្រលាញ់ ហើយបង្ហាញក្តីស្រលាញ់នោះដល់ទូលបង្គំ មិនមែនដោយសារទូលបង្គំបានធ្វើកិច្ចការ ឬមិនធ្វើនោះទេ តែព្រះអង្គនៅតែចាក់បង្ហូរសេចក្ដីស្រលាញ់នេះមកលើទូលបង្គំដែរ។ ខណៈពេលដែលទូលបង្គំកំពុងសិក្សាអំពីព្រះអង្គ សូមទ្រង់ប្រទានសេចក្ដីជំនឿដល់ទូលបង្គំឲ្យបានកាន់តែរឹងមាំជាងមុខ។

ក្នុងកាលដែលទូលបង្គំនៅមានជីវិតនៅឡើយ សូមទ្រង់ប្រទានសេចក្ដីជំនឿមកទូលបង្គំ ដើម្បីឲ្យមានការជឿជាក់ថា "គ្មានកិច្ចការណាមួយដែល លំបាកសម្រាប់ព្រះអង្គនោះឡើយ"។ ____________

_____________________________________________________________________

_____________________________________________________________________

_____________________________________________________________________

_____________________________________________________________________

_____________________________________________________________________

# មេរៀនទី ៤

# សារៈប្រយោជន៍សម្រាប់អ្នកនាំង ១០

## លោកុប្បត្តិ ១៨:១៦-៣៣ - លោក អប្រាហាំ និង ការទូលអង្វរ

---

## មាតិកាសំខាន់ៗក្នុងមេរៀនទី ៤

### ទិដ្ឋភាពទូទៅ៖

### សេចក្ដីណែនាំ

### មេរៀនទី ៤: លោកុប្បត្តិ ១៨:១៦-៣៣


- ផែនការណ៍របស់ព្រះជាម្ចាស់ ......................................
- សេចក្ដីស្នើរសុំរបស់លោក អប្រាហាំ.............................
- ព្រះជាម្ចាស់គឺជាចៅក្រមដ៏សុចរិត .................................
- និមយន័យ: ការទូលអង្វរ..........................................
- ការអនុវត្តន៏: គារវកិច្ច ...............................................

# សេចក្តីណែនាំ

ថ្វីដ្បិតតែមេរៀនទី ៤ នេះវាខ្លីក៏ពិតមែន ប៉ុន្តែក្នុងការបង្រៀនជាក់ស្តែងនៅក្នុងមេរៀននេះ នឹងមានការលើកទឹកចិត្តឲ្យយើងបាននាំមនុស្ស និង ស្ថានភាពមកដាក់នៅចំពោះព្រះជាម្ចាស់ដោយការអធិស្ឋាន។ សេចក្តីអធិស្ឋាន គឺមានន័យថាវាស្ពានរបស់ព្រះជាម្ចាស់ប្រើសម្រាប់សរសើរដម្កើងដល់ទ្រង់ អរព្រះគុណដល់ទ្រង់ ក៏ដូចជានាំមកជាមួយនូវការបីបាច់ថែរក្សាការពារមកចំពោះព្រះអង្គដែរ។ តាមរយៈសេចក្តីអធិស្ឋាននេះទៀតសោតក៏បានផ្តល់ឱកាសដ៏ល្អមួយក្នុងការទូលថ្វាយព្រះជាម្ចាស់អំពីបញ្ហា និង សេចក្តីត្រូវការរបស់អ្នកដទៃទៀតផង។ សកម្មភាព ឬ ការប្រព្រឹត្តបែបដូច្នេះ គឺត្រូវបានធ្វើជំនួសអ្នកដទៃ ទង្វើបែបនេះត្រូវបានមនុស្សទូទៅហៅថា សេចក្តីអធិស្ឋានទូលអង្វរ។

ក្មួយប្រុសរបស់លោក អប្រាហាំ បានទៅរស់នៅឯទីក្រុងសុដុម គឺស្ថិតនៅតំបន់ប៉ែកខាងត្បូងនៃទឹកដីកាណាន។ អំពើអាក្រក់របស់អ្នកក្រុងសុដុមបានចម្រើនឡើងយ៉ាងខ្លាំង ហើយអំពើបាបរបស់ពួកគេក៏ធ្ងន់ធ្ងរខ្លាំងណាស់ដែរ ដូច្នេះហើយទើបព្រះជាម្ចាស់គិតថាត្រូវបំផ្លាញទីក្រុងនោះចោល។ ព្រះជាម្ចាស់ក៏បានប្រាប់លោក អប្រាហាំ ពីផែនការណ៍នេះ ដោយបង្គាប់ប្រាប់អំពីកិច្ចការដែលគាត់ត្រូវទៅធ្វើ! ទោះជាយ៉ាងនេះក្តី ក៏លោក អប្រាហាំ មិនបានទៅប្រកាស់ប្រាប់បណ្តារជនអំពីផែនការណ៍របស់ព្រះជាម្ចាស់ដោយងាយៗដែរ តែគាត់បែរជាទូលអង្វរទៅព្រះជាម្ចាស់ជំនួសអ្នកសុចរិតទាំងប៉ុន្មានដែលនៅក្រុងនោះទៅវិញ។ លោក អប្រាហាំ បានចាប់ផ្តើមចចារជាមួយនឹងព្រះដោយសួរទៅទ្រង់ថា "ហេតុអ្វីបានជា ព្រះអង្គត្រូវបំផ្លាញដោយទាំងអ្នកសុចរិតយ៉ាងដូច្នេះ?" ប្រសិនបើនៅក្នុងក្រុងនោះមានមនុស្សសុចរិតចំនួន ៥០ នាក់ ៤៥... ៤០..." រហូតដក់សំណូមពរចុងក្រោយ គាត់ទូលសូមដល់ព្រះអង្គថា "ចុះបើមានតែ ១០ នាក់..." បន្ទាប់មកព្រះជាម្ចាស់បានសន្យានឹងគាត់ថា ទ្រង់នឹងមិនបំផ្លាញអ្នកទាំង ១០ នាក់ឡើយក្នុងការដែលទ្រង់បំផ្លាញទីក្រុងសុដុម។ នៅពេលនោះលោក អប្រាហាំ បានដឹងជាក់ថាជាម្ចាស់នឹងជំនុំជំរះមនុស្ស និង អ្វីៗទាំងអស់នៅលើផែនដីនេះ ហើយទ្រង់នឹងជំនុំជំរះដោយសេចក្តីយុត្តធម៌បំផុត។

អ្នកដែលត្រូវបានព្រះជាម្ចាស់បណ្តាលឲ្យសរសេរព្រះគម្ពីរហេព្រើរបានប្រាប់យើងឲ្យដឹងថា យើងទាំងគ្នាក៏ជាអ្នកទូលអង្វរផងដែរ។ នៅក្នុងព្រះគម្ពីរ ហេព្រើរ ៧:២៥ ដែលយើងបានសិក្សាបានប្រាប់ឲ្យយើងដឹងថា (ព្រះយេស៊ូវ) អាចសង្គ្រោះមនុស្សបានយ៉ាងពេញបរិបូរណ៍ចំពោះអស់អ្នកណាដែលមកតាមទ្រង់ ដ្បិតព្រះអង្គតែងទូលអង្វរសម្រាប់ពួកគេទាំងអស់គ្នា។ ដោយសារព្រះអង្គបានដាក់ព្រះជន្មទ្រង់ផ្ទាល់ដើម្បីបង់ថ្លៃលោះជំនួសអំពើបានរបស់យើងតែម្តងជាការស្រេច តែទ្រង់នៅតែចាំទូលអង្វរនៅចំពោះព្រះវរបិតាជំនួសយើងគ្រប់ពេលវេលា។ យើងគ្មានអ្វីដែលត្រូវខ្លាចទៀតឡើយ! ដ្បិតយើងមានអ្នកទូលអង្វរដែលមិនចេះរអ៊ូរទាំ មិនស្តីបន្ទោសដ៏ល្អឥតខ្ចោះរង់ចាំស្តាប់យើងជានិច្ច ដោយសារតែ

មានទ្រង់បានធ្វើជំនួសយើងដូច្នេះហើយទើប យើងមិនត្រូវការធ្វើដោយខ្លួនឯងទៀតនោះឡើយ។ ឥឡូវនេះទ្រង់កំពុងតែទូលអង្វរសុំឲ្យព្រះវរបិតាបានដកសេចក្ដីក្រោធ និង ការជំនុំជំរះដែលបម្រុងទុកសម្រាប់អំពើបាបរបស់ពួកយើងទាំងអស់គ្នា។

ប៉ុន្តែនៅមានផ្នែកមួយបន្ថែមទៀងដែលត្រូវប្រត្តិបត្តិក្នុងការទូលអង្វរ គឺយើងត្រូវក្លាយទៅជាសមាជិកនៃគ្រួសារជំនឿនៃព្រះជាមុនសិន ទើបយើងអាចទទួលអភ័យឯកសិទ្ធិ និង ការទទួលខុសត្រូវក្នុងការទូលអង្វរជំនួសឲ្យក្រុមគ្រួសារ មិត្តភ័ក្រ ទៅតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ គឺត្រូវមានចិត្តប្រណីសណ្ដោសជានិច្ច ដាច់ខាតមិនត្រូវទទួលនូវផលអាក្រក់ណាមួយដែលពួកគេត្រូវទទួលនោះឡើយ។ គឺជាឱកាសមួយសម្រាប់យើងទៅ "ឈរនៅចន្លោះរវាង" មនុស្សហើយនឹងព្រះជាម្ចាស់ដើម្បីទូលអង្វរទៅព្រះអង្គជំនួសអ្នកដទៃ។ យើងគ្រប់គ្នាត្រូវបានត្រាស់ហៅឲ្យមកដើម្បីអធិស្ឋានសម្រាប់ពួកគេ ហើយនឹងអធិស្ឋានជាមួយពួកគេដែរ។ ក្នុងខណៈពេលដែលព្រះវរបិតាបានប្រទានអង្គព្រះយេស៊ូវឲ្យធ្វើជាអ្នកទូលអង្វរនៅចំពោះព្រះភ័ក្រទ្រង់ ដូច្នេះ ព្រះអង្គលើកទឹកចិត្តឲ្យយើងគ្រប់គ្នាធ្វើជាអ្នកទូលអង្វរនៅចំពោះព្រះភ័ក្រព្រះយេស៊ូវដូច្នេះដែរ ដោយយកមកជាមួយនូវសេចក្ដីសំណូម ការលន់តួអង្វរ និង រាល់ទាំងសំណើរទាំងឡាយគឺមានទាំងរបស់អ្នកជឿ និង របស់អ្នកដែលមិនជឿ។ រាល់សេចក្ដីសំណូមទាំងប៉ុន្មានត្រូវបានឆ្លើយតបឬយ៉ាងណាគឺអាស្រ័យទៅលើក្ដីអាណិតមេត្តា និង សេចក្ដីសប្បុរសរបស់ទ្រង់។

ចូរអានអំពីស្ថានភាពរបស់លោក អប្រាហាំ ជាពិសេសក្នុងខណៈដែលគាត់បានស្នើរសុំព្រះជាម្ចាស់កុំឲ្យបំផ្លាញមនុស្សសុចរិតទៅជាមួយនឹងមនុស្សអាក្រក់ឡើយ។ នៅពេលណាយើងសិក្សាដល់មេរៀនទី៥ នោះយើងនឹងបានដឹងអំពីលទ្ធផលនៃសេចក្ដីអធិស្ឋានរបស់គាត់ជាមិនខាន។

## ផ្នែកទី ១

**សេចក្ដីណែនាំៈ** ចូលមកដល់ព្រះគម្ពីរលោកុប្បត្តិជំពូក ១៨ នេះយើងនៅតែបន្ដរាប់មើលថាតើមានព្រឹត្តិការណ៍អ្វីបានកើតឡើង។ ជាបន្ដទៅទៀតនេះ គឺនៅក្រោយពេលភ្ញៀវពិសេសទាំងបីនាក់របស់គាត់រៀបនឹងលាគាត់ចេញដំណើរបន្ដទៅមុខទៀត ក៏នឹងមានរឿងពីរដែលត្រូវកើតឡើង គឺមួយជារឿងល្អហើយរឿងមួយទៀតគឺជារឿងអាក្រក់! តោះយើងស្ដាប់រឿងមុនទៅមើល៎ គឺថាព្រះជាម្ចាស់បានបញ្ជាក់ប្រាប់លោក អប្រាហាំ និង ភរិយារបស់គាត់ថាគឺនៅពេលវេលានេះ នៅឆ្នាំក្រោយលោកស្រី សារ៉ា នឹងបង្កើតបានកូនប្រុសមួយ! អបអរសាទរ! លុះក្រោយពីនោះបន្ដិចព្រះជាម្ចាស់បានប្រាប់រឿងអាក្រក់ដល់លោក អប្រាហាំដែរ គឺជារឿងដែលទាក់ទងជាមួយនឹងសាច់ញាត្តិយ៉ាងជិតស្និទ្ធរបស់គាត់។ ត្រូវឲ្យឯងប្រុងប្រៀបខ្លួន!

ក្នុងខណៈពេលដែលយើងកំពុងសិក្សាជាមួយគ្នានេះ យើងត្រូវនឹកចាំនូវចំណុចសំខាន់ទាំងបី កាលណាយើងអានសាច់រឿងនិមួយៗ ១). ស្វែងរកឲ្យឃើញនូវអង្គហេតុ (ឫសគល់) នៃសាច់រឿង ២). ត្រូវធ្វើការស្រាវជ្រាវអំពីសេចក្តីពិតរបស់ព្រះជាម្ចាស់ និង សេចក្តីរបស់មនុស្ស ៣). ត្រូវរកឲ្យឃើញថាតើមានអ្វីខ្លះជាប់ពាក់ព័ន្ធទៅនឹងការអនុវត្តន៍ ដែលបានផ្សារភ្ជាប់រវាងព្រឹត្តិការណ៍ប្រវត្តិសាស្រ្ត ទៅនឹងការរស់ប្រចាំថ្ងៃរបស់យើង។

**កិច្ចការៈ** ចូរអានព្រះគម្ពីរលោកុប្បត្តិ ១៨:១៦-៣៣

**សេចក្តីបង្រៀនៈ** ដោយសារការធ្វើបដិសណ្ឋារកិច្ចរបស់លោក អប្រាហាំ ចំពោះភ្ញៀវរបស់គាត់បានផ្តល់នូវបរិយាកាសមួយយ៉ាងប្រសើរ ដូច្នេះហើយទើបភ្ញៀវទាំងបីនាក់នោះបានជំរាបគាត់នូវដំណឹងដ៏ល្អអំពីសេចក្តីសន្យាសម្រាប់ពូជពង្សដំណរកូនចៅជំនាន់ក្រោយរបស់គាត់។ នៅពេលពួកគេបានឮដំណឹងល្អអំពីចាប់កំណើតកូន ប្រហែលជាពួកគេបាននឹកគិតពីរយៈពេលដែលត្រូវសម្រាល ស្រមើស្រមៃពីមុខមាត់កូនយ៉ាងណា។ ចូរលោកអ្នកបិទភ្នែកស្រៃទៅមើល៎ ប្រាកដជាបានឃើញលោកស្រីសារ៉ា កំពុងតែរវល់មមាញឹកជាមួយនឹងការមើលបីបាច់ថែរក្សាកូនមិនខាន គឺគាត់ត្រូវគិតគូរទៅដល់ការរៀបចំប្រដាប់ប្រដាប្រើសប្រាស់សម្រាប់កូន ឬអាចថាគាត់ត្រូវទិញសម្ភារៈប្រើប្រាស់ទុកជាមុន ដូចជាខោទឹកនោម កន្សែងតូច/ធំ ទឹកដោះគោ បំពង់ទឹកក្តៅទឹកត្រជាក់ និងរបស់របរផ្សេងៗទៀតដែលត្រូវការប្រើចាំបាច់។ និយាយការពិតទៅ ស្ថិតក្នុងការស្រមើស្រមៃបែបនេះ វាហាក់ដូចជាធ្វើឲ្យមានការធុញទ្រាន់ ប៉ុន្តែធ្វើដូច្នេះគឺវាអាចជួយយើងឲ្យយកស្ថានភាពក្នុងផ្ទៃរឿងនេះមកពាក់ព័ន្ធនឹងយើងដែរ។ នៅជាច្រើនខែខាងមុខនេះ គឺត្រូវមានកិច្ចការសំខាន់ខ្លះៗទៀតក្នុងការរៀបចំផែនការដើម្បីរង់ចាំពេលវេលានសសេចក្តីសន្យានឹងមកដល់។

ភ្ញៀវពិសេសទាំងបីនាក់ក៏បានបន្តដើរទៅមុខទៀត តែមុននឹងពួកគេទៅគឺពួកគេបានបន្សល់ទុកនូវ រាជសារសម្រាប់លោក អប្រាហាំ រួចពួកគេទៅបាត់ ព្រោះពួកគេនៅមានកិច្ចការផ្សេងៗទៀតដែលត្រូវតែធ្វើឲ្យបានសម្រេច។ នៅក្នុងខ ១៦ បាននិយាយថា "ពួកគេក្រោយរៀងនឹងចាកចេញទៅពួកគេក៏ងាកសំដៅទៅ ______________________"។ នេះគឺជាការសំខាន់ចាំបាច់ក្នុងការសិក្សាអំពីផែនទី ដើម្បីឲ្យបានស្គាល់តំបន់ និង ទីតាំងនៅជិតៗនោះ។ ចូរយើងមើលផែនទីទី១ដែលនៅទំព័រខាងក្រោយនៃព្រះគម្ពីររបស់លោកអ្នក ហើយរកមើលឲ្យឃើញពីទីតាំងសមុទ្រស្លាប់។ នៅប៉ែកខាងលិចប្រហែលជាមួយភាគបីនៃចំងាយផ្លូវតាមបណ្តោយសមុទ្រស្លាប់ភាគខាងត្បូង នោះលោកអ្នកនឹងឃើញតំបន់ ហេប្រុន ជាក់ជាមិនខាន ហើយដើមម៉ៃសាក់មួយដ៏ធំរបស់ ម៉ាមរេ ក៏បានកត់ត្រាទុកនៅក្នុងខនោះ ដែរ (លោកុប្បត្តិ ១៣:១៨) នៅត្រង់កន្លែងនោះហើយ ដែលជាន្លែងលោក អប្រាហាំ រស់

នៅ ហើយភ្ញៀវពិសេសទាំងបីនាក់ក៏មកជួបគាត់នៅត្រង់កន្លែងនោះដែរ។ នៅក្នុង ខ១៦ បានប្រាប់យើងថាភ្ញៀវទាំងបីនោះបានក្រឡេកសំដៅទៅឯក្រុងសុដុម ទោះបីជានៅក្នុងព្រះគម្ពីរមិនបានបញ្ជាក់ប្រាប់យើងឲ្យច្បាស់ពីទីតាំងនៃក្រុងសុដុម ក៏ពិតមែន ប៉ុន្តែបើការស្រាវជ្រាវរបស់បណ្ឌិតខាងព្រះគម្ពីរបានមានប្រសាសន៍ថា ក្រុសសុដុមគឺនៅភាគខាងត្បូងនៃតំបន់ហេប្រុស ដ្បិតភ្ញៀទាំងបីនោះបានក្រឡេងមើលសំដៅទៅទីនោះ ឬ ប្រហែលនៅមិនឆ្ងាយពីតំបន់ ហេប្រុន នោះឡើយ។ តាមរយៈបទគម្ពីរបានប្រាប់យើងថាលោក អប្រាហាំ បានជូនដំណើរភ្ញៀវទាំងបីនាក់នោះ ដោយបានដើរទៅជាមួយពួកគេមួយសន្ទុះក្នុងកាលដែលពួកគេបន្តដំណើរសំដៅទៅកាន់ក្រុងសុដុម។ សូមបញ្ជាក់ឡើងវិញថាភ្ញៀវទាំងបីបានទទួលការស្វាគមន៍ និង បដិសណ្ឋារកិច្ចយ៉ាងកក់ក្ដៅទៅតាមវប្បធម៌នៅសម័យនោះ។

**លំហាត់:** នៅក្នុងខ ១៧ ព្រះជាម្ចាស់បានអនុញ្ញាតិឲ្យយើងយល់ពីផ្នត់គំនិតរបស់ទ្រង់ផ្ទាល់ តទៅនេះចូរយើងស្ដាប់នូវអ្វីដែលទ្រង់មានព្រះបន្ទូល...

1. “តើយើងនឹង ______________________________________________?”។
2. ក្នុងខ ១៨ “អប្រាហាំ នឹងបានទៅជា __________________ និង ____________ ____________________ នៃប្រជាជាតិមួយដ៏ធំ ព្រមទាំង ________________ _____ នឹងបានទៅជា __________________________________________” ។
3. ក្នុងខ ១៩ “សម្រាប់យើង ________________________ ដល់គេ ហើយនឹងធ្វើឲ្យគេបានទៅជា ________________________________________________
__________________________________________________________
__________________________________________________________
__________________________________________________________”។
4. ក្នុងខ ២០ ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅកាន់លោក អប្រាហាំ អំពីក្រុងសុដុម និង កូម៉ូរ៉ា។ តើទ្រង់មានព្រះបន្ទូលដូចម្ដេចខ្លះ? ___________________________________
__________________________________________________________
__________________________________________________________
__________________________________________________________

## ផ្នែកទី ២

## សំនួរៈ

1. តើមានការវែកញែកដូចម្ដេចរវាងលោក អប្រាហាំ នៅក្នុងលោកុប្បត្តិ ១៨:១៨,១៩ និង ក្រុងសុដុម និង កូម៉ូរ៉ា នៅក្នុងខ ២០, ២១? ______________________________

   ______________________________

   ______________________________

2. ព្រះជាម្ចាស់បានជ្រើសរើសលោក អប្រាហាំ បានប្រទានពរដល់គាត់ តាមរយៈគាត់ព្រះអង្គនឹងសម្តេចតាមបំណងព្រះហឫទ័យដ៏សុចរិតរបស់ទ្រង់មិនខាន។ ព្រះអង្គបានប្រទានទឹកដីឲ្យគាត់ បានប្រទានពរឲ្យគាត់មានកូនចៅជាច្រើន ហើយមានទ្រព្យសម្បត្តិយ៉ាងបរិបូរណ៍ជាងនរណា១ទាំងអស់។ ជាងនេះទៅទៀតនោះ ព្រះជាម្ចាស់បានចងសម្ព័ន្ធមេត្រីជាមួយនឹងគាត់ ក៏ដូចជាកូនចៅជំនាន់ក្រោយ១របស់គាត់ដែរ (លោកុប្បត្តិ ១៧:៧)។ ដោយយោងទៅតាមព្រះគម្ពីរលោកុប្បត្តិ ១៨:១៧-២១ តើព្រះជាម្ចាស់បានឆ្លើយតមនឹងសំនួរផ្ទាល់របស់ទ្រង់យ៉ាងដូចម្ដេច? ______________________________

   ______________________________

3. បើសិនលោកអ្នកគឺជាលោក អប្រាហាំ តើផ្នត់គំនិតរបស់ព្រះជាម្ចាស់បែបនេះមានន័យដូចម្ដេចចំពោះលោកអ្នក? ______________________________

   ______________________________

**លំហាត់បន្ថែ:** បុរសពីនាក់បានវិលត្រឡប់ទៅវិញ ហើយបន្តដំណើរទៅកាន់ក្រុងសុដុម។

1. ក្នុងខ២២ តើមានអ្វីខ្លះដែលយើងបានរៀនអំពីលោក អប្រាហាំ? "លោក អប្រាហាំ ____

   ______________________________

2. ក្នុងខ២៣-២៥ បានបង្ហាញអំពីទឹកចិត្តរឹងប៉ឹងរបស់លោក អប្រាហាំ ក្នុងករណីដែលគាត់ នៅចំពោះព្រះភ័ក្រព្រះជាម្ចាស់ ដំបូងឡើយគាត់បានទូលសូមព្រះអង្គចំនួន ៣ ចំណុចៈ

   ក. ______________________________?

   ខ. ______________________________?

   គ. ______________________________?

លោក អប្រាហាំ បានដឹងថាព្រះជាម្ចាស់នឹងត្រូវ "កាត់ទោសរាល់អ្វីៗមានជីវិតនៅលើផែនដី" នេះ (ខ២៥) គឺប្រាកដជាដោយទាំងមនុស្សសុចរិតមិនខានឡើយ ហើយគាត់ក៏បានដឹងដែរថា ព្រះជាម្ចាស់ សុចរិត ហើយជាចៅក្រមដ៏យុត្តិធម៌ ដូច្នេះគាត់បានមានប្រសាសន៍បន្តទៀត

ក. ____________________________________________

____________________________________________

ខ. ____________________________________________

____________________________________________

3. តើហេតុអ្វីបានលោក អប្រាហាំ មានចិត្តខ្វល់ខ្វាយនឹងក្រុងសុដុម? សូមរំលឹងសារឡើងវិញ ក្នុង ព្រះគម្ពីរលោកុប្បត្តិ ១៣:១០-១៣ ____________________
4. ក្នុងខ២៦ ខណៈដែលព្រះជាម្ចាស់គឺជាចៅក្រមដ៏សុចរិតដូចដែលលោក អប្រាហាំបាននិយាយ! តើព្រះអង្គមានព្រះបន្ទូលយ៉ាងដូចម្ដេច? ____________________

____________________________________________

នៅក្នុងខ២៧ យើងឃើញថា លោក អប្រាហាំ គាត់មានចិត្តភ័យខ្លាច ហើយសង្វេកចំពោះក្រុង សុដុមខ្លាំងណាស់ តែក្នុងពេលជាមួយគ្នាគាត់នៅតែខ្វល់ខ្វាយចំពោះក្មួយប្រុសរបស់គាត់ដដែល គឺលោក ឡុត។ ចូរយើងសង្កេតមើលពីការបន្ទាបខ្លួនរបស់គាត់ពេលចូលទៅឯព្រះជាម្ចាស់ គាត់ បានទូលព្រះជាម្ចាស់ថា "មើល ឥឡូវទូលបង្គំបាន ____________________

____________________________________________

5. នៅក្នុងខ២៨ តើលោក អប្រាហាំ បានទូកសូមព្រះជាម្ចាស់ដូចម្ដេច?

ក. ____________________________________________

ខ. ____________________________________________

6. ពេលនោះព្រះជាម្ចាស់មានព្រះបន្ទូលតបទៅគាត់វិញថា "បើអញ ____________________

____________________________________________"។

7. នៅក្នុងខ២៩ ការសន្ទនាក៏ចេះតែបន្តទៀច រួចព្រះជាម្ចាស់បានសន្យាថានឹងមិនបំផ្លាញក្រុង សុដុន នោះឡើយបើសិនណាលោកអប្រាហាំ រកឃើញថាមាន ____________នាក់។
8. ក្នុងខ៣០ ចំពោះអ្នកណាដែលបន្ទាប់ខ្លួន នោះគេនឹងចាត់ខ្លួនឯងដូចជាធូលីដី ហើយនៅទូល សូមពីព្រះជាម្ចាស់យ៉ាងអង់អាចដដែល ដើម្បីធ្វើយ៉ាងឲ្យព្រះជាម្ចាស់បានដកសេចក្ដីកំហឹង របស់ទ្រង់ចេញពីគាត់វិញ "ចុះបើមានត្រឹមតែ ____________________?"
9. ក្នុងខ៣១លោក អប្រាហាំបានទូលសូម "ទូលបង្គំរកបានត្រឹមតែ ____________ ប៉ុណ្ណោះ?"

10. ក្នុង៣២ បន្ទាប់មកទៀតលោក អប្រាហាំ បានទូលសួមជាថ្មីម្តងទៀតត្រឹមចំនួន ______ ______________ នាក់។ រួចហើយព្រះជាម្ចាស់ក៏ឆ្លើយទៅវិញ ____________ ______________________________________

ការសន្ទនាក៏ត្រូវបានបញ្ចប់! លោក អប្រាហាំក៏វិលត្រឡប់ទៅផ្ទះរបស់គាត់វិញ។

## ផ្នែកទី ៣

**មានអ្វីខ្លះដែលយើងបានរៀនអំពីព្រះជាម្ចាស់:** យើងបានបញ្ចប់ការប្រមូលអង្គហេតុនៃកាសន្ទនារវាងលោក អប្រាហាំ ជាមួយនឹងព្រះជាម្ចាស់ស្តីអំពីការសង្គ្រោះ និង ការបំផ្លាញទីក្រុងសុដុម រួចមកហើយ។ ដូច្នេះ យើងអាចចោទជាសំនួរដូចតទៅ: តាមរយៈសាច់រឿងនេះតើហើយបានរៀនអ្វីខ្លះអំពីព្រះជាម្ចាស់? លោក អប្រាហាំ ប្រាប់នូវរឿងរ៉ាងខ្លះអំពីព្រះជាម្ចាស់ថាទ្រង់គឺជានរណា ចូរអានសារឡើងវិញក្នុងព្រះគម្ពីរលោកុប្បត្តិ ១៨:២៥។ គាត់បានបញ្ជាក់សំដៅថាព្រះជាម្ចាស់ ទ្រង់គឺជាចៅក្រមដែលអ្វីៗគ្រប់យ៉ាងគឺសុទ្ធត្រឹមត្រូវទាំងអស់ នៅក្នុងព្រះអង្គគឺមានទាំងភាពយុត្តិធម៌ និង ភាពសុចរិតមានតែព្រះអង្គតែមួយគាត់ដែលអាចសម្រេចថានរណាខ្លះមានទោស ហើយនរណាខ្លះគ្មានទោស មានតែប៉ុណ្ណោះដែលអាចធ្វើអ្វីបានគ្រប់បែបយ៉ាង។ ពួកយើងម្នាក់ៗសុទ្ធតែជាមនុស្សមានបាប ហើយខ្វះមិនដល់សិរីនៃទ្រង់ (រ៉ូម ៣:២៤) ការដៅសញ្ញាសំគាល់ពីភាពសុចរិតបរិសុទ្ធគឺជាតម្រូវការរបស់ទ្រង់។ លោក អប្រាហាំ ទទួលស្គាល់ថាព្រះជាម្ចាស់គឺចៅក្រមដ៏យុត្តិធម៌ ហើយមានតែទ្រង់ប៉ុណ្ណោះដែលអាចដាក់សេចក្តីក្រោធដល់អស់អ្នកណាដែលសមនឹងទទួល ឬ ប្រទានព្រះគុណដល់មនុស្ស (ព្រះជាម្ចាស់បានប្រទាននូវអ្វីៗដែលយើងគិតថាមិនសក្តិសមនឹងបានទទួល)។ លោក អប្រាហាំ ទទួលស្គាល់ថាព្រះជាម្ចាស់មានសេចក្តីសុចរិត ហើយគាត់ជឿថាមានតែព្រះអង្គមួយប៉ុណ្ណោះដែលមានសមត្ថភាពអាចធ្វើអ្វីៗដែលត្រឹមត្រូវ ដ្បិតសេចក្តីសុចរិត និង ភាពយុត្តិធម៌គឺជាផ្នែកមួយនៃលក្ខណៈរបស់ទ្រង់ (គឺជាខ្សែលោហិត DNA) ទ្រង់មិនដែលច្រានចោល ឬប្រកែកនឹងអង្គទ្រង់ផ្ទាល់ម្តងណាឡើយ។

## ការឆ្លុះបញ្ចាំង:

1. ចូរពិចារណាអំពីពេលវេលាមួយ លោកអ្នកដែលជាអ្នកត្រូវការសម្រេចចិត្តបញ្ចប់ទំនាក់ទំនងពីមនុស្សម្នាក់ទៀត ព្រោះលោកអ្នកបានរកឃើញថាម្នាក់នោះមានចិត្តមិនស្មោះត្រង់ជាមួយនឹងលោកអ្នក ហើយថែមទាំងបាននិយាយបង្កាច់បង្ខូចឈ្មោះ និង ធ្វើឲ្យលោកអ្នកមានការឈឺចាប់ដោយរូបភាព ឬ ប្រការណាមួយទៀតផង: ______________________ ______________________________________។

   បើតាមយុត្តិធម៌ គឺលោកអ្នកមានសិទ្ធិយ៉ាងពេញលេញក្នុងការបញ្ចប់ទំនាក់ទំនងជាមួយអ្នក

នោះ ឬ ក៏អាចដាក់ពាក្យបណ្ដឹងអ្នកនោះឡើងតុលាការក៏បានដែរ។ ទោះបីជាយ៉ាងណាក៏ដោយ អាចថានឹងមានជនទីបីចូលខ្លួនមកធ្វើជាដំណាងរបស់ម្នាក់នោះ មកអង្វរលោកអ្នកជំនួស។ តាមភាពជាក់ស្ដែង អ្នកតំណាងដែលមកជួបលោកអ្នក គាត់បានដឹង និង ទទួលស្គាល់យ៉ាងច្បាស់ថាលោកអ្នកពិតជាមានសិទ្ធិយ៉ាងគ្រប់គ្រាន់ក្នុងការបញ្ចប់ទំនាក់ទំនង ឬ ប្ដឹងទៅតុលាការដើម្បីដាក់ទោសម្នាក់នោះ ប៉ុន្តែគាត់នឹងអង្វរករលោកអ្នក ដោយមិនបានបដិសេធន៍នូវអ្វីដែលជាការពិតនោះឡើយ គាត់នៅតែព្យាយាមអង្វរសូមឲ្យលោកអ្នកបានអត់ទោសដល់ម្នាក់នោះ ហើយព្រមទទួលថានោះពិតជាកំហុសរបស់គេពិតមែនដោយផ្អែកតាមភាពយុត្តិធម៌។

2. យើងគ្រប់សុទ្ធបានដឹងថាយុត្តិធម៌គឺជាសេចក្ដីត្រូវការជាចាំបាច់ដែលមិនអាចខ្វះបាន ឧទាហរណ៍នៅពេលណាដែលបានប្រព្រឹត្តអំពើរំលងច្បាប់ដោយប្រការណាមួយ ហើយយើងនឹងដឹងថាវាពិតជាចាំយ៉ាងណា នៅពេលណាមួយដែលកើតមានភាពច្របូកច្របល់រញ៉េរញ៉ៃ។ យើងបានប្រព្រឹត្តខុសក្នុងករណីរំលោភលើសេចក្ដីទុកចិត្តលើភាគីម្ខាងទៀត ឬ ធ្វើបាបនរណាម្នាក់ឲ្យមានការឈឺចាប់។ យ៉ាងណាមិញ យើងម្នាក់ៗប្រហែលជាធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍ក្នុងបញ្ហាទាំងនេះ បើទោះបីបញ្ហាទាំងអស់នោះគឺជាទង្វើរបស់យើងក្ដី របស់មិត្តភ័ក្ររបស់យើងក្ដី ក្នុងភាពជាប្ដីប្រពន្ធក្ដី ឬ វាគឺជាទង្វើរបស់ក្រុមការងារក្ដី ក៏យើងត្រូវតែទទួលខុសត្រូវ និង រកសំណោះស្រាយប្រកបដោយទង្វើនៃសេចក្ដីស្រលាញ់ជានិច្ច។ បើយើងបានប្រព្រឹត្តកិច្ចការខ្លះៗប្រកបដោយភាពអត្មានិយម និងដោយគ្មានភាពយុត្តិធម៌ នោះគឺបានន័យថាយើងមិនបានទទួលខុសត្រូវ ឬ ដោះស្រាយដោយសេចក្ដីស្រលាញ់ និង ការអត់ទោសនោះឡើយ។

**ការអនុវត្តន៍:** ក្នុងពេលដែលលោកអ្នកពិចារណាអំពីទំនាក់ទំនងនានាក្នុងជីវិតរស់នៅប្រចាំថ្ងៃ...

- ចូរនឹកគិតរកមើល កាលពីពេលដែលលោកអ្នកគឺអ្នកមានសិទ្ធិយ៉ាងគ្រប់គ្រាន់ក្នុងការអនុវត្តទៅតាមភាពយុត្តិធម៌ ចំពោះនរណាម្នាក់ តែយ៉ាងណាក៏អ្នកនៅតែបានបំភ្លេចចោលដោយមានសេចក្ដីស្រលាញ់ និង ការអត់ទោស។
- ចូរចងចាំថាតើនរណាខ្លះដែលមានការពាក់ព័ន្ធក្នុងបញ្ហានោះ
- ពិនិត្យពិច្ច័យអំពីទង្វើរបស់ខ្លួនឯង បន្ទាប់សឹមពិនិត្យទៅលើទង្វើរបស់ភាគីម្ខាងទៀត។
- ចូរធ្វើការឆ្លុះបញ្ចាំងថាតើបញ្ហានោះត្រូវបញ្ចប់យ៉ាងដូចម្ដេច។ ជាការពិតលោកអ្នកមានសិទ្ធិក្នុងការដាក់ទោសលើគេមែន ប៉ុន្តែបែរជាត្រឡប់ជ្រើសរើសការអត់ទោសជំនួសវិញ។ តើលោកអ្នកបាននិយាយ ឬ ធ្វើអ្វីម្យ៉ាងខុសពីធម្មតាដែរឬទេ?

**សេចក្តីអធិស្ឋានៈ** ឱព្រះអម្ចាស់អើយ! សូមអរព្រះគុណដល់ព្រះអង្គដែលជាព្រះដ៏យុត្តិធម៌។ ព្រះអង្គបានគ្រប់គ្រប់ផែនដីនេះប្រកបដោយភាពយុត្តិធម៌ ទូលបង្គំបាននឹកចាំអំពីភាពយុត្តិធម៌របស់ព្រះអង្គដែលបានប្រកាសប្រាប់ទូលបង្គំដែលជាមនុស្សមានទោស ប៉ុន្តែព្រះអង្គបែរជាប្រព្រឹត្តនឹងទូលបង្គំប្រកបដោយសេចក្តីមេត្តាករុណាក៏ព្រោះតែសេចក្តីស្រលាញ់ និង ការអត់ទោសរបស់ទ្រង់ដែរ។ សូមអរព្រះគុណសម្រាប់ការអត់ទោសដល់ទូលបង្គំ និង ប្រទានឲ្យទូលបង្គំមានឱកាសថ្វាយទ្រង់ពីក្តីស្រលាញ់ និង ការអត់ទោសដល់អ្នកដទៃទៀតៈ ______________________________

______________________________

______________________________

## ផ្នែកទី ៤

**សេចក្តីបង្រៀនៈ** នៅក្នុងសាច់រឿងរបស់លោក អប្រាហាំ មានរបៀបយ៉ាងពិសេសក្នុងការទូលសូមអង្វរព្រះជាម្ចាស់ជំនួយបណ្តារជននៅក្រុងសុដុម ជាពិសេសគឺទូលអង្វរសម្រាប់លោក ឡុត ត្រូវជាក្មួយប្រុសរបស់គាត់។ លោក អប្រាហាំ បានធ្វើជាអ្នកទូលអង្វរជំនួសឲ្យអ្នកដទៃ និយាយឲ្យចំគឺប្រជាជនក្នុងទីក្រុងសុដុម លោក ឡុត (ក្មួយប្រុសរបស់គាត់) និង ក្រុមគ្រួសាររបស់គាត់ផ្ទាល់តែម្តង។

**និយមន័យៈ** ពាក្យថា **ទូលអង្វរ** គឺជាទង្វើមួយដែលត្រូវប្រព្រឹត្តឡើងនៅចំពោះព្រះភ័ក្ររបស់ព្រះជាម្ចាស់ ធ្វើការទូលសូមជំនួសឲ្យអ្នកដៃ អង្វរយ៉ាងទទូចដល់ព្រះជាម្ចាស់សម្រាប់សេចក្តីផ្សេងៗរបស់អ្នកដទៃ។ នៅក្នុងព្រះគម្ពីរ ១ ធីម៉ូថេ ២:១ ត្រូវលើកទឹកចិត្តយើងគ្រប់ៗគ្នាឲ្យធ្វើជាអ្នកទូលអង្វរនៅចំពោះព្រះភ័ក្រព្រះជាម្ចាស់សម្រាប់អ្នកដទៃ។

**ការអនុវត្តន៍ៈ** នៅក្នុងមេរៀននេះយើងមានការអនុវត្តន៍មួយ ដែលបានលើកទឹកចិត្តយើងម្នាក់ៗឲ្យធ្វើជាអ្នកទូលអង្វរដល់ព្រះជាម្ចាស់ជំនួសអ្នកដទៃ តួយ៉ាងដូចជា មិត្តភ័ក្រដែលកំពុងមានជម្ងឺ អស់អ្នកដែលកំពុងជួបនឹងការលំបាកក្នុងជីវិត អ្នកដែលត្រូវបានបាត់បង់ការងារ ឬ មានការខាតក្នុងមុខជំនួញ ឬ អស់អ្នកណាស់ ចំពោះអស់អ្នកដែលមានកូនចៅមិនស្តាប់បង្គាប់បានរត់ចេញពីផ្ទះជាដើម ទាំងអស់នេះគឺជាឧទាហរណ៍ខ្លះៗ សម្រាប់យើងទូលអង្វរដល់ព្រះជាម្ចាស់ក្នុងនាម និង តួនាទីជាអ្នកទូលអង្វរ។

1. តើនរណាដែលជាមនុស្សសំខាន់ក្នុងជីវិតខ្ញុំសម្រាប់ឲ្យខ្ញុំធ្វើការទូលអង្វរ? __________
2. តើម្នាក់មានសំណូមពរ ឬ សេចក្តីត្រូវការអ្វីសម្រាប់ឲ្យអ្នកធ្វើការទូលអង្វរដល់ព្រះជាម្ចាស់?

______________________________

______________________________

3. តើខ្ញុំត្រូវទូលសូមព្រះជាម្ចាស់យ៉ាងដូចម្ដេចចំពោះសំណូមពរ ឬ សេចក្ដីត្រូវការរបស់គេនោះ?

______________________________

______________________________

**ចូលឱ្យកាន់តែស៊ីជម្រៅថែមទៀត៖** នៅក្នុងព្រះគម្ពីររ៉ូម ៨:២៦-២៧ យើងអាចរកឃើញនូវការកំសាន្តចិត្តយ៉ាងអស្ចារ្យមួយដែលព្រះវិញ្ញាណបរិសុទ្ធគឺជាអ្នកទូលអង្វរជំនួសយើងម្នាក់ៗ។ អង្គព្រះវិញ្ញាណទ្រង់ជ្រាបទាំងតម្រូវការរបស់រយើងផង ហើយក៏បានយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ផងដែរ។ ក្នុងខណៈពេលដែលយើងមិនដឹងថាគួរត្រូវអធិស្ឋានអំពីអ្វី ដូច្នេះព្រះវិញ្ញាណបរិសុទ្ធគឺជាអ្នកអធិស្ឋានទូលអង្វរជំនួសយើង។ ចូរកត់ត្រាទុកក្នុងសៀវភៅរបស់លោកអ្នកនូវគំនិតខ្លះៗ ចំពោះការកំសាន្តលោកអ្នក ដែលធ្វើចេះស្ដាប់តាមការណែនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងខណៈពេលដែលទ្រង់គឺជាអ្នកទូលអង្វររបស់យើង។

## ការទន្ទេញចាំមាត់៖

យើងត្រូវតែមាននៅចំពោះមុខស្រាប់អំពីអ្វីដែលធ្វើឲ្យនឹកឃើញយ៉ាងខ្ជាប់ខ្ជួន តាមព្រះវិញ្ញាណបរិសុទ្ធរំលឹងឲ្យយើងដឹង តាមរយៈការនេះគឺបានផ្ដល់ឲ្យយើងនូវការកំសាន្តចិត្ត និង ការធានាអះអាង។ ចូរចំណាយពេលខ្លះដើម្បីកត់ត្រានូវបទគម្ពីរពីរខក្នុងព្រះគម្ពីរ (រ៉ូម ៨:២៦-២៧) ទុកក្នុងសៀវភៅរបស់លោកអ្នក រួចចូរទន្ទេញឲ្យបានចាំស្ទាត់។ បើដូច្នេះ ចូរយើងទាញយកបទគម្ពីរនេះ ហើយបំបែកទៅជាព្រយោគ ឬ ទៅជាឃ្លា។

1. តើនៅក្នុងខ២៦បានប្រាប់យ៉ាងដូចម្ដេចខ្លះ?

   ក. ខគម្ពីរបានប្រាប់លោកអ្នកថាព្រះវិញ្ញាណបរិសុទ្ធជាអ្នកជំនួយនៅពេលណា?______

   ______________________________

   ខ.តើជានិច្ចកាលយើងតែងតែដឹងថាគួរត្រូវអធិស្ឋានអំពីអ្វីមែនទេ? __________

   ______________________________

   គ. នៅពេលដែលយើងវង្វេង តើយើងត្រូវការជំនួយពីព្រះវិញ្ញាណបរិសុទ្ធយ៉ាងដូចម្ដេច? _

   ______________________________

2. តើនៅក្នុងខ២៧បានប្រាប់យ៉ាងដូចម្ដេចខ្លះ? ហេតុអ្វីបានយើងមិនដែលមានការភ័យខ្លាច?

   ______________________________

   ______________________________

   ______________________________

## ផ្នែកទី ៥

## ការអនុវត្តន៍ផ្ទាល់ខ្លួន:

1. តើមានអ្វីខ្លះដែលធ្វើឲ្យលោកអ្នកមិនសប្បាយចិត្ត ឬ ធុញទ្រាន់? តើមានអ្វីខ្លះនៅក្នុងគំនិតរបស់លោកអ្នកដែលធ្វើមានអារម្មណ៍ថាស្ថានភាពនោះវាមិនអាចទៅរួច ឬ ធ្វើមិនបាន? ____________________________________________

2. តើមានការកំសាន្តចិត្តបែបណាក្នុងការ ដែលលោកអ្នកបានស្គាល់យ៉ាងស្និទ្ធស្នាលជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះ ហើយលោកអ្នកមានអារម្មណ៍ដូចម្តេចដែលមានព្រះវិញ្ញាណរបស់ព្រះបានស្គាល់អ្នក ជាងអ្នកស្គាល់ខ្លួនឯង? ____________________________________________

3. តើមានអ្វីប្លែកដែលធ្វើឲ្យលោកអ្នកដឹងថាព្រះវិញ្ញាណបរិសុទ្ធបានទូលអង្វរជំនួស នៅពេលលោកអ្នកត្រូវចូលទៅមនុស្សពិបាកៗ កិច្ចការតឹងតែង និង ឧបសគ្គនានាក្នុងជីវិត? ____________________________________________

4. តើលោកអ្នកនឹងត្រូវប្រុងប្រៀបរៀបចំយ៉ាងដូចម្តេច បើលោកអ្នកដឹងថានឹងមានការលំបាកត្រូវកើតឡើងចំពោះជីវិតរបស់លោកអ្នកនៅពេលបន្តិចទៀតខាងមុខនេះ។ ____________________________________________
____________________________________________

**សេចក្តីបង្រៀន:** ការចូលទៅចំពោះព្រះភ័ក្រព្រះជាម្ចាស់គឺជាអភ័យឯកសិទ្ធមួយ។ លោកអប្រាហាំគាត់បានទូលអង្វរព្រះជាម្ចាស់ដោយទឹកចិត្តក្លាហាន ដ្បិតគាត់ដឹងថាគាត់មិនមែនជាអ្វីនោះទេ គឺគ្រាន់តែជាធូលីដីប៉ុណ្ណោះ ប៉ុន្តែគាត់នៅតែមានចិត្តសូមសេចក្តីអាណិតមេត្តាពីព្រះជាម្ចាស់ដដែល។ អំពើអាក្រក់របស់បណ្តារជននៅក្នុងទីក្រុង សុដុម និង កុម៉ូរ៉ា កាន់តែចម្រើនឡើងយ៉ាងខ្លាំង ដោយសារអំពើទាំងអស់ហើយ ទើបធ្វើឲ្យព្រះជាម្ចាស់មានសេចក្តីក្រោធដល់ពួកគេ តែលោក អប្រាហាំនៅតែជឿជាក់ថាអាចនឹងផ្លាស់ប្តូរព្រះហរឫទ័យព្រះជាម្ចាស់បាន។ ទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះជាម្ចាស់គឺមានភាពស្និទ្ធស្នាលជាទីបំផុត គាត់មានទំនាក់ទំនងជាមួយនឹងអ្នកដែលអាចនឹងបំផ្លាញគាត់បាន ហើយគាត់ក៏ជាអ្នកដែលតែងតែឆ្លើយតមពេលដែលគាត់ស្រែកអំពាវនាវរកដែរ។

**សេចក្តីអធិស្ឋាន:** លោក អប្រាហាំ បានបន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់ដោយចិត្តអង់អាច នេះសរបញ្ជាក់ឲ្យឃើញថាគាត់មានចិត្តអង់អាច ហើយក៏មានការបន្ទាប់ខ្លួនដែរ ក្នុងពេលដែលគាត់នាំយកនូវសេចក្តីសំណូមអធិស្ឋានមកទូលថ្វាយដល់ព្រះជាម្ចាស់ ដោយគាត់បានប្រើពាក្យសរសើរដម្កើង និង

អរព្រះគុណ ទូលសូម និងអ្វីៗដែលគាត់នឹកបារម្ភក្នុងចិត្តគ្រប់បែបយ៉ាង: ____________________

____________________________________________________________

____________________________________________________________

ចូរនឹកក្នុងចិត្តអំពីនរណាម្នាក់ ឬ ស្ថានភាពណាមួយ ដែលលោកអ្នកត្រូវធ្វើជាអ្នកទូលអង្វរសម្រាប់ម្នាក់នោះ ឬ ស្ថានភាពនោះ រួចចូរទូលអង្វរទៅព្រះកាន់ព្រះជាម្ចាស់ថា: នៅថ្ងៃនេះ ____________

____________________________________________________________

ទូលបង្គំអធិស្ឋានសម្រាប់ ____________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

# មេរៀនទី ៥

# សម្រែកដ៏លាន់រំពង

## លោកុប្បត្តិ ១៩ - ការបំផ្លាញទីក្រុងសូដុម និង កូម៉ូរ៉ា

---

## មាតិកាសំខាន់ៗក្នុងមេរៀនទី ៥

### ទិដ្ឋភាពទូទៅលោកុប្បត្តិជំពូក ១៩

### សេចក្តីណែនាំ

### មេរៀនទី ៥: លោកុប្បត្តិ ១៩


- ទេវត្តានៃព្រះជាម្ចាស់មកដល់ទីក្រុងសុដុម.......................
- ភ្ញៀវដែលមិនបានអញ្ជើញ.. ......................................
- សក្ខភាពបន្ទាប់......................................................
- ព្រះជាម្ចាស់ ស្មោះត្រង់ យុត្តិធម៌ ហើយអាណិតមេត្តា..........
- ចូលឲ្យកាន់តែជ្រៅ: រ៉ូម ១:១៨-៣២ ...........................

# សេចក្តីណែនាំ

នៅក្នុងមេរៀននេះយើងនឹងបានឃើញច្បាស់នូវសេចក្តីក្រោធរបស់ព្រះជាម្ចាស់ ដែលទ្រង់បានជះមកមកមនុស្សទាំងគឺអស់អ្នកដែលក្នុងចិត្តគេគ្មានព្រះ និង អស់ទាំងមនុស្សអាក្រក់នៅទីក្រុងសុដុម និង ទីក្រុងកូម៉ូរ៉ា។ នេះគឺជារឿងមួយគួរឲ្យចង់តាមដាន ព្រោះវាបានបើកដម្តែងឲ្យឃើញយ៉ាងច្បាស់នូវភាពយុត្តិធម៌របស់ព្រះជាម្ចាស់ និង ភាពបរិសុទ្ធដែលជាតម្រូវការរបស់ទ្រង់។ ចំពោះបណ្តារជននៅទីក្រុងនោះបានប្រព្រឹត្តការអាក្រក់ ដែលព្រះជាម្ចាស់មិនអាចអត់ឱនឲ្យបាន។ ទេវត្តានៃព្រះជាម្ចាស់បានដោះស្រាយចំពោះបញ្ហានេះបានយ៉ាងអស្ចារ្យ ពួកគេបានជំរុញលោក ឡុត "ប្រញាប់ឡើង! ឬមួយអ្នកចង់ស្លាប់នៅទីនេះដែរ"? លោក ឡុតនៅតែស្ទាក់ស្ទើរ នោះទេវត្តាក៏ចាប់ទាញដៃពួកគេ ហើយភៀសខ្លួនចេញទៅកន្លែងមានសុត្ថិភាពខាងក្រៅក្រុង។ លោក ឡុត និង ប្រពន្ធ ព្រមទាំងកូនស្រីទាំងពីររបស់គាត់បានទទួលសេចក្តីសង្គ្រោះដោយមេត្តាករុណាពីព្រះជាម្ចាស់។ ការជំនុំជំរះត្រូវបានចំពោះទីក្រុងសុដុម និង កូម៉ូរ៉ា ប៉ុន្តែ ទ្រង់មានការអត់ធ្មត់ និង ក្តីសប្បុរសចំពោះគ្រួសាររបស់លោក ឡុតវិញ។

នៅក្នុងមេរៀនមុនៗ បានបើកសម្តែងឲ្យបានឃើញអំពីព្រះគុណនៃព្រះជាម្ចាស់ចំពោះលោក អប្រាហាំ ដូចជាព្រះបានសន្យានឹងគាត់ បានឆ្លើយតបចំពោះសេចក្តីទូលអង្វរសម្រាប់លោក ឡុតជាក្មួយគាត់។ នៅក្នុងមេរៀនទី ៥ នេះវិញ យើងបានឃើញអំពីភាពយុត្តិធម៌របស់ព្រះជាម្ចាស់ តាមរយៈការបំផ្លាញទីក្រុងដោយសារតែមានពេញដោយអំពើអាក្រក់ និង សម្រែកយ៉ាងកងរំពងបានឮដល់ព្រះកាណ៌ទ្រង់។ ប៉ុន្តែ យើងក៏បានឃើញអំពីសេចក្តីមេត្តាករុណារបស់ទ្រង់ចំពោះក្រុមគ្រួសាររបស់លោក ឡុតផងដែរ។ ទ្រង់មានសេចក្តីស្រលាញ់ដល់អស់អ្នកណាដែលលោក អប្រាហាំ ស្រលាញ់ ហើយទ្រង់បានគោរពតាមអ្វីដែលទ្រង់បានសន្យានឹងគាត់គ្រប់យ៉ាង។

## ផ្នែកទី ១

**សេចក្តីណែនាំ:** នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូល ១៩ នេះ គឺជាមេរៀនមួយហាក់ដូចជាមានការរំខាន ព្រោះវាគឺជាដើមចមនៃការឈ្លោះទាស់ទែងរបស់មនុស្សចំនួន តែយ៉ាងណាក្តី យើងនៅចងចាំបានថាគោលបំណងក្នុងការសិក្សារបស់យើងមិនដើម្បីជជែកតវ៉ាគ្នា ឬដើម្បីជំទាស់ខ្វែងគំនិតគ្នានោះឡើយ ផ្ទុយមកវិញ គឺដើម្បីបង្កើនចំណេះដឹងនូវអ្វីដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរបរិសុទ្ធ ក៏ដូចជាការស្វែងយល់នូវអ្វីដែលព្រះជាម្ចាស់ចង់មានព្រះបន្ទូលមកកាន់យើងម្នាក់ៗ។

**កិច្ចការ:** ចូរអានព្រះគម្ពីរលោកុប្បត្តិជំពូក ១៩:១-២៩

**លំហាត់:** កាលពីចុងជំពូក ១៨ យើងបានប្រាប់យើងដឹងថា ក្រោយពីបញ្ចប់ការសន្ទនា ព្រះជាម្ចាស់ក៏ចាកចេញទៅ ហើយលោក អប្រាហាំ ក៏វិលត្រឡប់មកផ្ទះរបស់គាត់វិញ។ ទោះបីជាយ៉ាងណាក៏ដោយ យើងមិនដឹងថាព្រះជាម្ចាស់ទ្រង់បានយាងទៅណាដែរ តែអ្វីដែលយើងដឹងពីព្រះគម្ពីរលោកុប្បត្តិ ២៩:១ ថាមានទេវត្តាពីរអង្គបានមកដល់ទីក្រុងសុដុម។

1. ដោយយោងទៅតាមខ១ តើក្នុងថ្ងៃនោះនៅពេលណា? ____________________
2. តើទេវត្តាទាំងពីរនាំអាស្រ័យជាមួយអ្នកណា? ____________________
3. តើគាត់នៅឯណា? ____________________
4. នៅពេលដែលលោក ឡុតបានឃើញពួកគេទាំងពីររំពេចនោះ តើគាត់មានប្រតិកម្មដូចម្ដេច?

____________________

____________________

បើតាមធម្មតានៅច្រកទ្វារក្រុង គេប្រាកដជាធ្លាប់ឃើញ ឬ ធ្លាប់ស្គាល់មនុស្សណាដែលតែងតែចេញចូលជាមិនខាន។ នៅក្នុងលោកុប្បត្តិ ១៨:១ បានប្រាប់យើងឲ្យដឹងថាលោក អប្រាហាំកំពុងអង្គុយនៅត្រង់ច្រកទ្វារទីក្រុងនោះតែម្ដង។

5. ការធ្វើបដិសណ្ឋារកិច្ចរបស់លោក ឡុត ចំពោះភ្ញៀវទាំងពីរគឺប្រហាក់ប្រហែលគ្នានឹងលោកអប្រហាំដូចដែលយើងបានសិក្សារួចកន្លងមកដែរ។ តើលោក ឡុតបានជូនអ្វីទៅបុរសទាំងពីរនាក់នោះ? (ក្នុងខ២) ____________________

____________________

____________________

____________________

**សំនួរ:**

1. តើលោកអ្នកគិតថាលោក ឡុតស្គាល់ភ្ញៀវទាំងពីរនាក់នោះដែរទេ? ហេតុអ្វី? ________

____________________

____________________

2. គាត់ក៏ប្រញាប់ប្រញាល់ស្វាគមន៍ និង ធ្វើបដិសណ្ឋារកិច្ចចំពោះពួកគេ។ តើលោកអ្នកគិតថាលោក ឡុត ហាក់ដូចជាមានចិត្តច្រណែនជ្រុលដោយការទទួចចង់ស្នាក់នៅក្នុងផ្ទះរបស់គាត់ដែរទេ? ហេតុអ្វី? ____________________

____________________

តើក្នុងខ ៣ បានប្រាប់អ្វីខ្លះដល់យើង? ______________________________

______________________________________________________

3. ចូររក្សាគំនិតរបស់លោកអ្នកនៅក្នុងការសន្ទនារបស់លោក អប្រាហាំ ជាមួយនឹងព្រះជាម្ចាស់កាលពីជំពូកមុនដែលយើងបានសិក្សារួច។ តើលោកអ្នកចង់ឲ្យកូនៗរបស់លោកអញ្ចនកបានចម្រើនវ័យធំឡើងក្នុងស្ថានភាពដូចទីក្រុងសុដុម និង កូម៉ូរ៉ាដែរឬទេ? ហេតុអ្វី? ______

______________________________________________________

______________________________________________________

ជួនកាលវាមិនមែនជារឿងត្រឹមត្រូវនោះឡើយ! ចូរលោកអ្នកប្រុងប្រៀបស្មារតីជានិច្ច ក្នុងដែលលោកអ្នកកំពុងសិក្សាជាមួយគ្នានេះ។

## ផ្នែកទី ២

## លំហាត់:

1. តើបុរសទាំងពីរនោះឆ្លើយតបដូចម្តេចនៅពេលដែលលោក ឡុតបានអញ្ជើញពួកគេចូលទៅក្នុងផ្ទះរបស់គាត់? ______________________________________

______________________________________________________

2. នៅក្នុងខ ៣ តើយើងដឹងថាលោក ឡុតមានអារម្មណ៍មិនច្របូកច្របល់ដោយគំនិតដូចម្តេច?

______________________________________________________

______________________________________________________

3. ជាថ្មីម្តងទៀតលោក ឡុតបានបង្ហាញនូវបដិសណ្ឋារកិច្ចចំពោះទេវត្តា តើគាត់បានប្រុងប្រៀបអ្វីខ្លះសម្រាប់ទេវត្តានោះ? ______________________________
4. សំនួរនេះបានផ្តល់សមត្ថកម្មសម្រាប់យើងថាលោក ឡុតប្រាប់ទទួលភ្ញៀវដោយធ្វើនំប៉័ងឥត ______________ ។ ភ្ញៀវម្នាក់មានអារម្មណ៍ថាលោក ឡុត ហាក់ដូចជាមានអ្វីត្រូវធ្វើយ៉ាងបន្ទាន់ ព្រោះថាគាត់ចេះតែដើរចុះដើរឡើងនៅក្នុងផ្ទះរបស់គាត់នោះ។ ការធ្វើនំប៉័ងឥតដំបែមិនត្រូវការពេលវេលាច្រើនក្នុងការចំអិនដូចជានំប៉័ងមានមេដំបែនោះទេ។ ចូរប្រៀបធៀបអាហារដែលលោក អប្រាហាំបានរៀបចំសម្រាប់ទទួលភ្ញៀវនៅក្នុងលោកុប្បត្តិ ១៨:៦ ទៅនឹងម្ហូបអាហារដូចមានរៀបរាប់នៅក្នុងខទាំងនេះ ______________________

______________________________________________________

5. នៅក្នុងខ ៤ ពួកគេចូលដេក តើនរណាបានមកផ្ទះរបស់លោក ឡុត? ______________

______________________________________________________________

______________________________________________________________

6. តើពួកគេមកផ្ទះរបស់លោក ឡុតដើម្បីអ្វី? ______________________________
នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១៣:១៣ យើងបានបញ្ជាក់ប្រាប់យើងថាបុរសៗនៅក្នុងទីក្រុងសុដុម ពួកគេគឺជា "______________________________________________

______________________________________________________________"

នៅក្នុងជំពូល ១៩ នេះបានធ្វើឲ្យយើងបានដឹងអំពីអំពើបាបយ៉ាងធ្ងន់ធ្ងរ និង ការអាក្រក់ជាអ្វី។

## សំនួរឆ្លុះបញ្ចាំង:

1. នៅក្នុងវគ្គមួយដែលជាសកម្មភាពរបស់បុរសទាំងបីនាក់នោះ គឺជាការទទួលយកនៅវប្បធម៌នៃទីក្រុងសុដុម ហើយជាការជាក់ស្តែងក្រុងកូម៉ូរ៉ាក៏មិនខុសគ្នាដែរ។ ចូររៀបរាប់អំពីលក្ខណរបស់បុរសទាំងបីនាក់ថានោះគឺជាអំពើបាបរបស់ពួកគេ រួចតើមានអ្វីដែលថ្មីដែរឬទេ? តើមានអ្វីខ្លះដែលបានបង្កប់អត្ថន័យដល់សង្គមគ្រួសារ និង សង្គមវប្បធម៌? __________________

______________________________________________________________

2. បើសិនលោកអ្នកគឺជាលោក ឡុងនៅក្នុងសាច់រឿងនាខណៈនោះ តើលោកអ្នកគួរធ្វើដូចម្តេច? ពួកគេទាំងអស់នោះគឺសុទ្ធតែជាភ្ញៀវ! ពួកគេបានមកផ្ទះរបស់លោកអ្នក ហើយត្រូវគេងមួយយប់ ចំណែកនៅខាងក្រៅផ្ទះវិញ មានមនុស្សប្រុសជាច្រើនចោមរោមជុំវិញផ្ទះដោយមានបំណងចង់យកភ្ញៀវរបស់លោកអ្នកចេញទៅប្រព្រឹត្តអំពើអាក្រក់របស់ពួកគេ។ តើលោកអ្នកនឹងត្រូវឆ្លើយតបទៅពួកគេវិញយ៉ាងដូចម្តេច? ______________________________

______________________________________________________________

## សំហាត់:

1. លោក ឡុតបានចេញទៅក្រៅផ្ទះដើម្បីជួបជាមួយពួកគេ! នៅក្នុងខ ៦ បានបើកសម្តែងឲ្យយើងបានដឹងនូវរឿងពីរយ៉ាងដែលគាត់បានប្រព្រឹត្ត និង ថ្លែងចេញដែលជាកត្តានាំយើងចោទជាសំនួរអំពីកប្បកិរិយា និង សកម្មភាពរបស់គាត់។ លោក ឡុតបានចេញមកឯពួកគេនៅខាងផ្ទះរួចគាត់ក៏ "______________________________________________" ។
2. បើសិនជាទង្វើដូច្នេះមកលើលោកអ្នកវិញ តើលោកអ្នកយល់ឃើញដូចម្តេច? _________

______________________________________________________________

3. តើគាត់បានដោះស្រាយជាមួយពួកគេដោយរបៀបណា? ____________________

____________________________________________________________

4. នៅក្នុង ៧ តើលោក ឡុតបានស្នើរសុំពួកគេទាំងអស់នោះយើងយកអ្វីជំនួសភ្ញៀវរបស់គាត់?

____________________________________________________________

## សំនួរឆ្លុះបញ្ជាំង:

1. លោក ឡុត និង ក្រុមគ្រួសារបានសម្រេចចិត្តទៅរស់នៅក្នុងទីក្រុងសុដុម និង កូម៉ូរ៉ា បន្ទាប់ពីគាត់និង ពូរបស់គាត់ (អប្រហាំ) បានចែកហ្វូងសត្វ និង ទ្រព្យសម្បត្តិផ្សេងៗ ពីព្រោះនៅតំបន់នោះគឺជាទឹកដីដែលមានស្មៅច្រើនសម្រាប់សត្វរបស់គាត់។ ជាក់ស្តែងនៅក្នុងខ ៦ និង ខ៧ យើងដឹងលោក ឡុត គាត់មានស្គាល់មិត្តភ័ក្រមួយចំនួនដែលបានរស់នៅទីក្រុងនោះទៀតផង។ បន្តិចក្រោយមកទៀតនេះ យើងឃើញថាគាត់បានសន្និដ្ឋានយ៉ាងច្បាស់បានថាពួកគេទាំងនោះគឺសុទ្ធតែជាមនុស្សអាក្រក់ ដោយគាត់បានបិទទ្វារផ្ទះទាំងមិនបែរខ្នង ដើម្បីចេញទៅខាងក្រៅផ្ទះនឹងសន្ទនា ចរចាជាមួយនឹងពួកមនុស្សអាក្រក់ទាំងនោះ គាត់ធ្វើដូច្នេះ ព្រោះតែគាត់មិនចង់ឲ្យភ្ញៀវរបស់គាត់ឮការសន្ទនាគ្នានោះ។ បើតាមផ្នត់គំនិត និង ការសង្កេត តើលោកអ្នកយល់ឃើញថាចរិតលក្ខណៈ និង អាកប្បកិរិយារបស់លោក ឡុតយ៉ាងដូចម្តេចដែរ? _______

____________________________________________________________

2. តើនេះគឺឪពុកបែបណាដែលសុខចិត្តប្រគល់កូនក្រមុំបរិសុទ្ធពីរនាក់ទៅប្រុសៗជាច្រើន ទាំងពោលឡើងថា "ឲ្យអ្នករាល់គ្នាប្រព្រឹត្តនឹងវាតាមតែចិត្តចុះ"? ជាធម្មតាឪពុកគ្រប់រូបគឺជាអ្នកដែលតែងតែការពារកូនស្រីរបស់ខ្លួន តែលោក ឡុតគាត់បែរជាសុខចិត្តការពារភ្ញៀវនៅក្នុងដោយសុខចិត្តប្រគល់កូនស្រីក្រមុំទាំងពីរនាក់ឲ្យទៅប្រុសៗជាច្រើននាក់ប្រព្រឹត្តតាមតែចិត្តគេទៅវិញ។ នៅជំនាន់នោះយើងគួរផ្តោតគំនិតពិចារណាអំពីវប្បធម៌របស់ពួកគេ គឺនៅសម័យនោះម្ចាស់ត្រូវតែចេញមុខការពារភ្ញៀវណាដែលបានមកដល់ផ្ទះរបស់ខ្លួនគឺជារឿងសំខាន់។ មកដល់ចំណុចនេះ តើលោកអ្នកមានអ្វីដែលផុសចេញពីគំនិតរបស់លោកអ្នកទាក់ទងទៅនឹង ចរិតលក្ខណៈ និង អាប្បកិរិយារបស់លោក ឡុត? ____________________

____________________________________________________________

____________________________________________________________

## ផ្នែកទី ៣

**លំហាត់:** បន្ទាប់តទៅនេះ គឺជាសកម្មភាពរំលោភបំពានរបស់ពួកប្រុសៗនៅខាងក្រៅផ្ទះរបស់លោកឡុត។ ចូរពិនិត្យដោយយកចិត្តទុកដាក់ឲ្យមែនទែនអំពីយុត្តិសាស្ត្រ និង ល្បិចកល្បរបស់ពួកគេ។

1. នៅក្នុងខ ៩ ពួកគេបាននិយាយ "ចូរជៀសចេញ!" ហើយពួកគេបន្តទៀតថាអាមួយនេះ [ឡុត] វាបាន ________________ ឥឡូវចង់តាំងខ្លួនធ្វើជា ______ ________________។ អើ! បើដូច្នេះយើងនឹង __________ ________________ នៅក្នុងខ ៩ ដដែលក៏បានប្រាប់ថាពួកគេបានប្រជៀតលើឡុតជាខ្លាំងទាំង ________________
2. តើពួកគេបានប្រើវិធិសាស្ត្រដូចម្តេចខ្លះដើម្បីបានចីទៅក្នុងផ្ទះ? ________________ ________________ ពួកគេបានចោទប្រកាន់ ទាំងនិយាយបញ្ចិតបញ្ចៀត "ឲ្យអាក្រក់ជាពីរនាក់នោះទៀតផងៗ។ កាលពីដំបូងឡើយ ពួកគេបានទទួលលោក ឡុត និង ក្រុមគ្រួសារដោយមិនប្រកាន់ថាពួកគាត់គឺជាសាសន៍ផ្សេងឡើយ ប៉ុន្តែនៅពេលនេះពួកគេបានឃើញថាគាត់មិនបានធ្វើទៅតាមវប្បធម៌របស់ពួកគេឡើយ គឺគាត់មិនព្រមធ្វើតាមអ្វីដែលពួកគេចង់បាន។ លោក ឡុតបានប្រាប់ថាការប្រគល់ភ្ញៀវទាំងពីរបស់គាត់ទៅពួកគេគឺជារឿងមួយមិនត្រឹមត្រូវទាល់តែសោះ។ តើពួកគេបានចាត់ទុកគាត់គឺជាមនុស្សបានដៃខ្នងដៃ និយាយក្រឡិចក្រឡុចដែរឬទេ? ________________

   ________________
3. ពេលនេះបុរសដែលនៅក្នុងលោក ឡុត បានមកចេញមុខម្តង (ខ ១០,១១) តើពួកគេធ្វើអ្វី?

   ក. ________________ទៅក្រៅ។

   ខ. ហើយ________________លោក ឡុត ________________ និង

   គ. ________________ទ្វារ។

   ឃ. ខណៈនោះពួកគេ ________________
4. នៅក្នុងខ ១២ តើពួកគេបានប្រាប់លោក ឡុត ធ្វើអ្វី? ________________

   ________________
5. តើពួកគេណែនាំឲ្យលោក ឡុតធ្វើដូចម្តេច? ________________
6. តើពួកគេប្រាប់លោក ឡុតថាពួកគេនឹងត្រូវធ្វើអ្វី? ________________
7. ហេតុអ្វីបានជាពួកគេត្រូវបំផ្លាញវាដូច្នេះ (ខ១៣)? ________________

8. នៅពេលលោក ឡុត ចេញទៅរកអនាគត់កូនប្រសារប្រុសរបស់គាត់ លុះពេលបានជួបគាត់ប្រាប់ពួកគេយ៉ាងដូចម្ដេច? ____________________

____________________

9. តើពួកគេឆ្លើយតបវិញដូចម្ដេចដែរ? ____________________

10. ថ្ងៃចាប់ផ្ដើមលិច ហើយ ទេវត្ដាក៏ប្រញាប់ប្រញាល់យ៉ាងបន្ទាន់ (ខ១៥) តើពួកគេបានណែនាំលោក ឡុតយ៉ាងដូចម្ដេចខ្លះ? ____________________

____________________

11. តើលោក ឡុត ឆ្លើយតបយ៉ាងណា? ____________________

12. តើនៅទីបំផុតវេត្ដាបានធ្វើដូចម្ដេចចំពោះលោក ឡុត និង គ្រួសារ ដើម្បីគាត់ធ្វើតាម? __

____________________

13. ពួកទេវត្ដាបាននាំលោក ឡុត ចេញផុតពីទីក្រុងនោះ ហើយថែមទាំងបានបង្ហាញទិសដៅយ៉ាងច្បាស់។ តើទេវត្ដាបានប្រាប់គាត់យ៉ាងដូចម្ដេច?

ក. ____________________

ខ. ____________________

គ. ____________________

ឃ. ____________________

14. នៅក្នុងខ ១៨-២២ បានប្រាប់យើងឲ្យបានដឹងអំពីមូលហេតុអ្វីដែលលោក ឡុត អំពាវនាវឲ្យទេវត្ដាជួយនាំគាត់ទៅទីកន្លែងដែលមានសុវត្ថិភាព នៅក្នុងក្រុងតូចមួយនៃ __________ ។ នៅត្រង់វគ្គមួយទៀតបានឲ្យយើងដឹងថាគាត់មានវ័យកាន់តែចាស់ណាស់ទៅហើយ ម្យ៉ាងសុខភាពក៏មិនសូវល្អ ដូច្នេះគាត់មិនអាចធ្វើដំណើរឡើងតាមភ្នំឲ្យទាន់មុនពេលមហន្ដរាយមកដល់បានឡើយ។ បើដូច្នេះ តើទេវត្ដាបានសន្យានឹងគាត់យ៉ាងដូចម្ដេច? ____________________

____________________

15. នៅក្នុងខ២៣ ព្រះអាទិត្យបានលិចបាត់ទៅ លោក ឡុតបានមកដល់ទីក្រុង សូអារដោយសុវត្ថិភាព ខណៈនោះមហន្ដរាយដ៏រន្ធត់ក៏បានមកដល់ដែរ។ តើរំពេចនោះគំនិតរបស់លោកអ្នកអាចថានឹងមានប្រតិ្តកម្មយ៉ាងដូចម្ដេច? ____________________

____________________

16. នៅក្នុងខ២៤ ការជំនុំជំរះ និង សេចក្តីក្រោធត្រូវបានបង្ហូរមកលើបណ្តាជននៅក្នុងក្រុងសុដុម និង ក្រុងកូម៉្ញរ៉ា។ តើគ្រាប់ភ្លៀងដែលធ្លាក់មកគឺជាអ្វី? ________________________
គួរកត់សម្គាល់ដោយប្រុងប្រយ័ត្នទូវចំពោះអ្វីដែលព្រះជាម្ចាស់ទ្រង់មានព្រះបន្ទូល នោះវាពិតជានឹងកើតមានយ៉ាងដូច្នោះជាមិនខានឡើយ។
17. ព្រះជាម្ចាស់បានទំលាក់សេចក្តីក្រោធរបស់ទ្រង់មក ក៏បានបំផ្លាញទីក្រុងនោះខ្ទិចខ្ទីគ្មានសល់អ្វីឡើយ ត្រូវបានបំផ្លាញអស់ទាំងមនុស្ស សត្វ រុក្ខជាតិនានា។ តើព្រះជាម្ចាស់ទ្រង់បានគោរពតាមសេចក្តីសន្យារបស់ទ្រង់យ៉ាងដូចម្តេច (លោកុប្បត្តិ ១៨:២២)? ________________

________________________________________________________________

18. ចូលមកដល់ខ២៦ តើទេវត្តានៃព្រះជាម្ចាស់បានណែនាំយ៉ាងដូចម្តេចតាមរយៈខ១៧? __

________________________________________________________________

តើមានអ្វីកើតឡើងចំពោះប្រពន្ធរបស់លោក ឡុត? ________________________

________________________________________________________________

19. នៅក្នុងខ២៧-២៨ យើងបានរកឃើញថាលោក អប្រាហាំ ស្ថិតនៅទីកន្លែងមួយកំពុងចរចាជាមួយនឹងព្រះជាម្ចាស់សម្រាប់អ្នកសុចរិត។ តើគាត់បានឃើញអ្វីក្នុងវេលាដែលគាត់បានក្រឡេកមើលសំដៅទៅឯក្រុងសុដុម និង កូម៉្ញរ៉ា? ________________________

________________________________________________________________

20. ចូរសង្ខេបខ២ តាមវិធីងាយៗសមញ្ញៗ
ក. ព្រះជាម្ចាស់________________________________ទីក្រុងនានាក្នុងតំបន់នោះ។
ខ. ព្រះជាម្ចាស់ ____________________________________ លោក អប្រាហាំ។
គ. ព្រះជាម្ចាស់ __________________________លោក ឡុត _____________ នៃគ្រោះមហន្តរាយដែលត្រូវបានទម្លាក់មកលើទីក្រុងនានាក្នុងកន្លែងដែលលោក ឡុតរស់នៅ។

## ផ្នែកទី ៤

**តើយើងបានរៀនអ្វីខ្លះអំពីព្រះជាម្ចាស់**? នៅក្នុងខ ១៦ គឺបញ្ចប់ទៅដោយពាក្យមួយយ៉ាងសំខាន់ "ព្រះអម្ចាស់ ____________________________________________" ពាក្យថាមេត្តាប្រណី គឺមានអត្ថន័យយ៉ាងជ្រាលជ្រៅសម្រាប់យើងទាំងអស់គ្នា។ ដូចដែលយើងបានចងចាំរួមមកថាភាពមេត្តាករុណា គឺមានន័យថាយើងមិននឹងត្រូវបានទទួលយកអ្វីៗដែលយើងសមនឹងទទួលទេ។ លោក ឡុតបានធ្វើឲ្យមានភាពជំពាក់ជំពិនទៅនឹងវប្បធម៌ក្នុងទឹកដីដែលគាត់ និង គ្រួសារបានទៅរស់នៅ។ យើងដឹងថាទោះបីជាយ៉ាងក៏ដោយ ក៏គាត់ និង គ្រួសារមិនបានបានប្រព្រឹត្តអំពើអាក្រក់ដូចជាពួក

អ្នករស់នៅក្នុងតំបន់នោះដែរ។ ពួកគេទាំងអស់នោះ មានត្រចៀកបែរជាថ្លង់ មានភ្នែកបែរជាងងឹត មើលអ្វីមិនឃើញ ដោយសារតែពួកគេបានងប់ងុកទៅនឹងអំពើកាមគុណ ដោយពួកគេបានប្រព្រឹត្តអំពើដ៏អាក្រក់នេះនៅក្នុងសហគមន៏ដែលពួកគេរស់នៅ។ គាត់បានទទួលស្គាល់ថា ការប្រព្រឹត្តអំពើទាំងនេះ មិនមែនសម្រាប់ខ្លួនគាត់ទេ ប៉ុន្តែសម្រាប់អ្នកដទៃវិញ។ ពេលនោះព្រះជាម្ចាស់បានចេញមកធ្វើអន្តរាគមដោយសេចក្តីអណិតមេត្តាដល់លោក ឡុត និងគ្រួសាររបស់គាត់ផងដែរ។ តែលោក ឡុតខ្លួនឯងចូលពាក់ព័ន្ធក្នុងរឿងនោះរួចស្រេចទៅហើយ រហូតទីបំផុតគាត់បានត្រឡប់ទៅជាអ្នកមានទោស នៅក្នុងដំណើរជីវិតនេះទៀតផង។ល សម្រាប់អំណះអំណាងទៅថ្ងៃខាងមុខ ចូរលោកអ្នកអានព្រះគម្ពីរ រ៉ូម ១:៣២, ២:១៦ ហើយចូលឲ្យបានកាន់ស៊ីជម្រៅនៅត្រង់ផ្នែកទី ៥។

យើងឃើញថាព្រះជាម្ចាស់ទ្រង់បានដាក់ទោសពួកគេយ៉ាងសក្តិសម ដោយការបង្ហូរសេចក្តីក្រោធមកមនុស្សអាក្រក់ ហើយយើងក៏បានឃើញអំពីព្រះគុណ និង សេចក្តីស្រលាញ់ដ៏លើសលប់ផងដែរ។ ព្រះគុណទ្រង់បានបង្ហូរមកដល់អស់អ្នកដែលមានទំនាក់ទំនងដោយសេចក្តីស្រលាញ់ជាមួយនឹងទ្រង់ ទ្រង់តែងតែនៅចងចាំមិនភ្លេចអ្វីបានសន្យាទាំងប៉ុន្មានរបស់ទ្រង់ជានិច្ច។ ជាងនេះទៅទៀតយើងបានឃើញពីសេចក្តីមេត្តាករុណារបស់ទ្រង់ក្នុងការជួយរំដោះមនុស្សលោកឲ្យបានរួចផុតពីទុក្ខទោសដែលពួកគេសក្តិសមនឹងទទួលទៀតផង។

## សំនួរអនុវត្តៈ

1. ព្រះជាម្ចាស់មានពេញទៅដោយសេចក្តីមេត្តាករុណា! តើលោកអ្នកធ្លាប់បានទទួលសេចក្តីមេត្តាករុណារបស់ទ្រង់នៅពេលណា? ____________________
2. ជានិច្ចកាលព្រះជាម្ចាស់បាននាំយកនូវសេចក្តីមេត្តាករុណារបស់ទ្រង់មកតាមរយៈអ្នកដទៃ។ តើលោកអ្នកធ្លាប់បទពិសោធន៍យ៉ាងដូចម្តេចដែរ? ចូរនឹកពិចារណាអំពីពេលវេលាណាមួយដែលលោកអ្នកមានឱកាសនាំយកសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់សម្រាប់នរណាម្នាក់ ដោយបានដកចេញនូវអ្វីដែលអ្នកសមនឹងទទួល ឬ ជួយឲ្យអ្នកនោះបានគេចចេញផុតពីទោសដែលគេនឹងត្រូវទទួល។ ____________________

   ____________________
3. តើលោកអ្នកមានគំនិត ឬ មានអារម្មណ៍យ៉ាងដូចម្តេចក្នុងកាលដែលលោកអ្នកត្រូវរំលឹក ឡើងវិញអំពីស្ថានភាពទាំងនេះ? ____________________

   ____________________

## ផ្នែកទី ៥

**ចូលឱ្យកាន់តែជ្រៅ:** នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១៩:៣០-៣៨ យើងអាចសាច់រឿងរបស់លោក ឡុតជាបន្តទៀត នោះនឹងបានដឹងថាតើមានរឿងអ្វីខ្លះកើតឡើងរវាងលោក ឡុង និង កូនស្រីទាំងពីររបស់គាត់។ ក្នុងសាច់រឿងនេះមិនបានបរិយាយអំពីជីវិតរបស់លោក ឡុត ទេ ដោយសារបន្ទាប់ពីកូនស្រីទាំងពីររបស់គាត់បង្អកស្រាឲ្យគាត់ស្រវឹង ក្រោយមកទៀតកូនស្រីទាំងពីររបស់គាត់ក៏មានផ្ទៃពោះ។ ហើយដំណរពូជពង្សក្រោយៗមកទៀតពួកគេក៏បានបង្កើតបានកូនម្នាក់មួយ ដែលក្លាយទៅជាឪពុកនៃសាសន៍ម៉ូអាប់ និង សាសន៍អាំម៉ូន។ កុលសម្ព័ន្ធទាំងពីរនេះ បានក៏ជាប់មានចំណែកនៅក្នុងរាស្ត្ររបស់ព្រះជាម្ចាស់ ជាច្រើនឆ្នាំក្រោយមក ពេលដែលប្រជារាស្ត្រ អ៊ីស្រាអែលធ្វើដំណើរទៅកាន់ទឹកដីសន្យា។

នៅក្នុងព្រះគម្ពីរមួយផ្សេងទៀតបានសង្កត់ធ្ងន់អំពើអាក្រក់នៃព្រះគម្ពីរលោកុប្បត្តិ ១៩ នេះយើងអាចរកឃើញនៅក្នុងរ៉ូម ១:១៨ បន្តរហូតដល់រ៉ូម ២:១៧។ នៅក្នុងផ្នែកហាក់ដូចជាមិនមានភាពវិជ្ជមាន មិនគួរឲ្យអស់សំណើច ហើយក៏គួរឲ្យរំភើបចិត្តដែរ តែវាគឺជាចំណេះដឹងមួយយ៉ាងពិសេស គឺបាននិយាយអំពីមនុស្សជំនាន់លោក អប្រាហាំ លោក ឡុត សតវត្សន៍ទីមួយរបស់មនុស្សក្នុងជំនាន់សាវក ប៉ូល និង និយាយមនុស្សក្នុងសតវត្សន៍ទី ២១ នេះផងដែរ។ រឿងរ៉ាវនៃក្រុងទាំងពី សុដុម និង កូម៉ូរ៉ា ក្នុងលោកុប្បត្តិជំពូក ១៩ និង ការរៀបរាប់នៅក្នុងព្រះគម្ពីរ រ៉ូមជំពូក ១ និង ជំពូក ២ គឺបានសង្កត់ធ្ងន់លើបញ្ហាអំពើបាននៃភេទសម្ព័ន្ធ។ មិនមែនតែភាពវិលជុំនៃអំពើបាបនៃបញ្ហាភេទសម្ព័ន្ធដ៏ហួសល្បត់ដែលបានលើបង្ហាញនៅក្នុងព្រះគម្ពីររ៉ូមនោះទេ តែគឺគ្រប់ប្រភេទនៃអំពើបាបទាំងអស់។ ចូរធ្វើការកំណត់អត្តសញ្ញាណនៃវដ្ត (ភាពវិលជុំ) ពីរីករាលដាលនៃភាពព្រងើយកណ្តើយ ការអត់ធ្មត់អធ្យាស្រ័យ និង ការតស៊ូមតិចុងក្រោយ ឬ ផ្នែកខាងសីលធម៌ផ្សេងៗទៀត? ______________________

______________________________________________________________

______________________________________________________________

ប្រើបទគម្ពីរ លោកុប្បត្តិ ជំពូក ១៩ និង ព្រះគម្ពីរ រ៉ូម ១-២ ដើម្បីឆ្លុះបញ្ចាំងឲ្យលោកអ្នកបានឃើញអំពីការជំនុំជំរះ និង សេចក្តីមេត្តាករុណា ទាំងនៅក្នុងសម័យកាលនៃព្រះគម្ពីរ និង ក្នុងសម័យបច្ចុប្បន្ន។ តើលោកអ្នកជឿថាព្រះបន្ទូលទ្រង់គឺជាសេចក្តីពិតនៅក្នុងជីវិតរបស់លោកអ្នកដែរឬទេ? ______

______________________________________________________________

______________________________________________________________

**សេចក្តីអធិស្ឋានៈ** ឱព្រះអម្ចាស់អើយ! ព្រះអង្គបានបង្ហាញសេចក្តីស្រលាញ់របស់ទ្រង់ ដូចជាបានជួយរំដោះលោក ឡុត និង គ្រួសាររបស់គាត់ឲ្យបានរួចផុតពីគ្រោះកាចដែលដាក់ទៅលើក្រុងសុដុម និងកូម៉ូរ៉ា។ មានពេលខ្លះទូលបង្គំរកឃើញថា ទូលបង្គំមានចិត្តមិនច្បាស់លាស់ក្នុងការប្រព្រឹត្តអាក្រក់ និងមានចិត្តរឹងរូសមិនស្រលាញ់ព្រះអង្គ ដូចដែលទ្រង់បានបង្ហាញសេចក្តីស្រលាញ់ឲ្យទូលបង្គំឃើញតាមរយៈការជួយរំដោះទូលបង្គំដោយព្រះហស្តទ្រង់។ សូមជួយទូលបង្គំឲ្យបានរួចផុតពីអ្វីដែលប៉ងលេបត្របាក់ទូលបង្គំ! សូមអរព្រះគុណសម្រាប់សេចក្តីមេត្តាករុណារបស់ទ្រង់! សូមអរព្រះគុណសម្រាប់ព្រះបន្ទូលដ៏មានសេចក្តីពិតរបស់ទ្រង់! សូមអរព្រះគុណសម្រាប់អភ័យឯកសិទ្ធដែលទ្រង់បានប្រទានមកទូលបង្គំក្នុងសេចក្តីអធិស្ឋានដែលអ្នកដទៃគ្មាន! សូមទ្រង់មានសេចក្តីមេត្តាករុណាចំពោះពួកគេទាំងអស់គ្នាផង ជាពិសេសសម្រាប់ ______________________________

______________________________

______________________________

______________________________

# មេរៀនទី ៦

# តើកូនចៀមនៅឯណា?

## លោកុប្បត្តិ ២១-២២ - យញ្ញបូជា

---

### មាតិកាសំខាន់ៗក្នុងមេរៀនទី ៦

**ទិដ្ឋភាពទូទៅលោកុប្បត្តិ**

**សេចក្ដីណែនាំ**

**មេរៀនទី ៦: លោកុប្បត្តិ ២១-២២**

- កំណើតរបស់ អ៊ីសាក់ ..............................................
- ព្រះជាម្ចាស់សាកល្បងលោក អប្រាហាំ.. ........................
- និយមន័យ: កោតខ្លាច ..............................................
- ព្រះយេស៊ូវ, ដង្វាយ ...............................................
- លោក អប្រាហាំ និង ការថ្វាយអ៊ីសាក់ជាយញ្ញបូជា.............
- ដោយសារសេចក្ដីជំនឿ លោក អប្រាហាំ........................

**មេរៀនសារឡើងវិញ**

# សេចក្ដីណែនាំ

សំណើចគឺជាការបង្ហាញនូវអារម្មណ៍មួយដែលព្រះជាម្ចាស់បានប្រទានមកមនុស្សគ្រប់គ្នា។ យើងសើច អំពីរឿងរ៉ាវផ្សេងៗគ្នា ហើយតាមរបៀបផ្សេងៗពីគ្នាដែរ យើងសើចនៅពេលណាដែលស្ដាប់រឿង កំប្លែង មានអំណរ មានការភ្ញាក់ផ្អើល មានស្នេហា អបអរសាទរ ដំណឹងល្អពីរឿងអ្វីមួយ។ សំណើចធ្វើ ឲ្យយើងមានអារម្មណ៍ល្អ ហើយនាំឲ្យសុខភាពល្អដល់រាង្គកាយទៀតផង។

មានពេលយំ និងពេលសើច មានពេលសំរាប់សោយសោក និងពេលសំរាប់លោតកញ្ឆេង។ (សាស្ដា ៣:៤)។ ឯព្រះដែលគង់នៅស្ថានសួគ៌ ទ្រង់នឹងសើច ព្រះអម្ចាស់ទ្រង់នឹងចំអកឲ្យគេ (ទំនុកដម្កើត ២:៤)។ តែព្រះអម្ចាស់ទ្រង់នឹងសើចនឹងគេ ដ្បិតទ្រង់ជ្រាបថា ថ្ងៃកំណត់របស់គេកាន់តែជិតដល់ (ទំនុក ដម្កើង ៣៧:១៣)

វាគឺជារឿងមួយដ៏គួរឲ្យចាប់អារម្មណ៍ បើយើងធ្វើការសង្កេតតាមដាននៅក្នុងរឿងរបស់ អ៊ីសាក់។ នៅ ក្នុងព្រះគម្ពីរលោកុប្បត្តិ ១៧ មានរឿងគួរឲ្យអស់សំណើចដល់ទៅពីរដង គឺនៅពេលដែលព្រះជាម្ចាស់ បានប្រាប់ដល់លោក អប្រាហាំ ថាលោកស្រី សារ៉ា នឹងបានទៅជាម្ដាយនៃជាតិសាសន៍មួយដ៏ធំ ពេល នោះលោក អប្រាហាំបានក្រាប់ចុះមុនដល់ដី ហើយអស់សំណើចនឹងខ្លួនគាត់។ ព្រះជាម្ចាស់មានព្រះ បន្ទូលថា លោកស្រីសារ៉ា នឹងបង្កើតបានកូនប្រុសម្នាក់ ហើយត្រូវដាក់ឈ្មោះឲ្យកូនប្រុសនោះថា អ៊ីសាក់ ដែលន័យថា គាត់សើច។ នៅក្នុងលោកុប្បត្តិជំពូក ១៨ យើងបានដឹងថាលោកស្រី សារ៉ា គាត់ បានអស់សំណើចនឹងខ្លួនឯង នៅពេលដែលភ្ញៀវទាំងបីនាក់បាននិយាយគាត់នឹងបង្កើតបានកូនប្រុសម្នាក់ គាត់បានគិតក្នុងចិត្តថា "អញចាស់ប៉ុណ្ណេះទៅហើយ តើនឹងនៅមានដំរេកទៀតដែរឬអី? ណាមួយ លោកម្ចាស់ប្ដីអញក៏ចាស់ណាស់ដែរ"។ បន្ទាប់ពីលោកស្រី សារ៉ា បង្កើតបានកូនប្រុសម្នាក់ ឪពុកបាន ដាក់ លោកស្រី សារ៉ា បាននិយាយថា "ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំបានសើច ដូច្នេះអស់អ្នកដែលបានដឹងឮ អំពីរឿងនេះ នឹងបានសើចជាមួយនឹងខ្ញុំដែរ។

យើងសារភាពថា យើងអស់សំណើចនៅពេលណាជួបនឹងរឿងរ៉ាវដែលគិតថាមិនអាចទៅរួច ទោះបីជា រឿងនោះមកពីព្រះជាម្ចាស់ក៏ដោយ។ យើងសើចចំពោះរឿងដែលមិនគួរឲ្យជឿ គឺចេញពីផ្នត់គំនិត របស់មនុស្សដែលកើតមានឡើងចំពោះប្ដីប្រពន្ធពីរនាក់ ប្ដីមានអាយុជិត ១០០ ឆ្នាំ ហើយប្រពន្ធវិញ មានអាយុជិត ៩០ ឆ្នាំ។ លោក អប្រាហាំ និង លោកស្រី សារ៉ា គាត់ទាំងពីរនាក់សើចពីព្រោះគិតថា រឿងនេះពិតជាមិនអាចទៅរួចឡើយ។ ទោះបីជាយើងមានពេលខ្លះអស់សំណើចនឹងរឿងដែលយើងមិន អាចជួយបាន ឬ គិតថាជារឿងល្ងីល្ងើ ដូចជាស្ត្រីគ្មានកូនហើយគាត់ចង់ក្លាយជាម្ដាយគេ បុរសដែល

គ្មានកូនហើយគាត់ចង់ ក្លាយទៅជាឪពុករបស់គេ កូនស្រីចង់បានបុរសដែលស្រលាញ់ព្រះជាម្ចាស់មកធ្វើជាប្តី កូនប្រុសចង់បាន នារីដែលស្រលាញ់ព្រះជាម្ចាស់មកធ្វើជាប្រពន្ធជាដើម។

តែទៅបីជាយើងគិតថាវាមិនអាចទៅរួចយ៉ាងណាក៏ដោយ តែនៅទីបំផុតអ្វីដែលព្រះជាម្ចាស់ទ្រង់បានសន្យាបានក្លាយទៅជាការពិត គឺអ៊ីសាក់បានកើតមកពិតប្រាកដមែន ជាការពិតគឺជាសំណើចលាយលំនឹងទឹកភ្នែកនៃសេចក្តីអំណរ។ តួយ៉ាងឈ្មោះថា អ៊ីសាក់ គឺជាការបញ្ជាក់អំពីសំណើចដែលបានមកពីព្រះជាម្ចាស់សម្រាប់គ្រួសារមួយនេះ យើងក៏ត្រូវបានអញ្ជើញឲ្យចូលរួមសើចអរសប្បាយជាមួយនឹងពួកគេផងដែរ ព្រោះថាអស់ជាច្រើនឆ្នាំកន្លងទៅនេះ មនុស្សគ្រប់គ្នាបានសើចចំអកឲ្យគាត់ថាជាស្ត្រីអារ។ ចូរលោកអ្នកពិចារណាអំពីសំណើរក្នុងជីវិតរបស់លោកអ្នក អំពីរឿងភ្ញាក់ផ្អើលដែលព្រះជាម្ចាស់បានប្រទានឲ្យ គឺជារឿងមិនស្មានដល់ គឺជារឿងដែលមិនគួរឲ្យជឿ គឺជារឿងដែលលោកអ្នកគិតថាវាមិនអាចទៅរួច ឬ មិនអាចធ្វើបាន។ ចូរសម្លឹងមើលមនុស្សនៅជុំវិញលោកអ្នក ជាមួយនឹងការអបអរសាទរ ក្នុងរឿងធ្វើធ្លាប់បានធ្វើឲ្យលោកអ្នកអស់សំណើចពីមុន ហើយបានក្លាយទៅជាការពិត។ ចូរចងចាំថា ព្រះជាម្ចាស់ទ្រង់ក៏អស់សំណើចដូចគ្នាដែរ។

## ផ្នែកទី ១

**សេចក្តីណែនាំ:** ឥឡូវនេះ យើងបន្តសាច់រឿងរបស់លោក អប្រាហាំ និង លោកស្រី សារ៉ាតទៅទៀត។ សេចក្តីសន្យារបស់ព្រះជាម្ចាស់មិនមែនសម្រាប់តែគាត់ទាំងពីរនាក់ និង កូនចៅជំណាន់ក្រោយរបស់គាត់ក្នុងអំឡុងពេលគាត់ត្រូវបង្កើត អ៊ីសាក់ប៉ុណ្ណោះទេ គឺត្រូវបានបន្តរហូតដល់លោកុប្បត្តិជំពូក ២១។ នៅក្នុងមេរៀងនេះ យើងនឹងផ្តោតសំខាន់ទៅលើ ព្រះគម្ពីរលោកុប្បត្តិ ២១:១-១៧ និង លោកុប្បត្តិ ២២:១-១៩ ដូច្នេះ ចូរលោកអ្នកអានសាច់រឿងទាំងពីរនោះ បន្ទាប់សួរសំនួរក្នុងខណៈពេលដែលលោកអ្នកកំពុងអាន ឧទាហរណ៍ តើតួរអង្គក្នុងរឿងនោះគឺជានរណា? តើពួកគេបានធ្វើអ្វីខ្លះ? គឺជានរណា? អំពីអ្វី? នៅទីណា? នៅពេលណា? ហេតុអ្វី?។ សំនួរទាំងនេះនឹងជួយឲ្យសាច់រឿងកាន់តែមានភាពរស់រវើក។

**លំហាត់:** យើងបានរង់ចាំអស់រយៈពេលដ៏យូរជាមួយនឹងលោក អប្រាហាំ និង លោកស្រីសារ៉ា ដើម្បីបានឮពាក្យដូចមាននៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២១:១-២។ ព្រះជាម្ចាស់ទ្រង់បានធ្វើសេចក្តីសន្យារបស់ទ្រង់បានសម្រេចចប់សព្វគ្រប់ជាមួយនឹងលោកស្រីសារ៉ា។

1. តើព្រះជាម្ចាស់ពិតជាបានធ្វើអ្វីទៅតាមសេចក្តីសន្យារបស់ទ្រង់ដែរឬទេបើយោងតាមខ២?

   ______________________________________________

2. តើលោក អប្រាហាំបានដាក់ឈ្មោះកូនរបស់នោះឈ្មោះអ្វី? (ខ៣) ______________

3. លោក អប្រាហាំ បានស្តាប់បង្គាប់តាមព្រះជាម្ចាស់ដែលបានបង្គាប់ថា អស់អ្នកណាដែលរស់នៅមានចំណែកក្នុងសម្ព័ន្ធមេត្រីដែលបានចងឡើងជាមួយគាត់។ តើព្រះជាម្ចាស់បានបង្គាប់ឲ្យលោក អប្រាហាំធ្វើអ្វីបើតាមលោកុប្បត្តិ ១៧:១២? ______________________

   ______________________________________________

   ពិធីកាត់ស្បែកមិនមែនជាគំនិតយល់ឃើញរបស់អស់អ្នកដែលរស់នៅក្នុងរង្វង់ក្រុមគ្រួសាររបស់លោក អប្រាហាំនោះទេ។ ដូច្នេះ នៅពេលដែល អ៊ីសាក់ កើតបានអាយុ ៨ ថ្ងៃគាត់បាន ______________________________________ (ខ៤)

4. ព្រះជាម្ចាស់សព្វហឫទ័យចង់ឲ្យគ្រប់ៗគ្នាបានប្រាកដថាលោក អប្រាហាំ គាត់គឺជាមនុស្សចាស់ម្នាក់។ ដូចជាអ្វីដែលលោកស្រីសារ៉ា បានលើកឡើងនៅក្នុង លោកុប្បត្តិ ១៨:១២ ថា ___ ______________ ហើយលោក អប្រាហាំ ______________________ ។

   ម្យ៉ាងវិញទៀតនៅក្នុងផ្នត់គំនិតរបស់មនុស្សលោកគិតថា សេចក្តីសន្យារបស់ព្រះជាម្ចាស់គឺ មិនអាចទៅរួចបានឡើយ។ នៅក្នុងលោកុប្បត្តិ ២១:៥ បានប្រាប់ឲ្យយើងដឹងថាលោក អប្រាហាំគាត់ _______ ឆ្នាំនៅពេលដែលអ៊ីសាក់បានកើតមក ហើយលោកស្រីសារ៉ា _______ឆ្នាំ។

5. ឈ្មោះថា អ៊ីសាក់ មានន័យថា ______________________ ។ តើនៅក្នុងខយោងនៃព្រះគម្ពីរបស់លោកអ្នកអ៊ីសាក់មានន័យដូចម្ដេច? ចូរពិចារណាមើលសំណើចក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ដែលពួកគេទន្ទឹងរង់ចាំការសម្រេចតាមសេចក្ដីសន្យា:
   ក. លោកុប្បត្តិ ១៧:១៧ នរណាសើច? ______________ តើគាត់បាននិយាយអ្វីខ្លះ?
   ______________________________________________________
   ខ. លោកុប្បត្តិ ១៨:១២ នរណាសើច? ______________ តើគាត់បាននិយាយអ្វីខ្លះ?
   ______________________________________________________
   គ. លោកុប្បត្តិ ២១:៦ នរណាសើច? ________________ តើគាត់បាននិយាយអ្វីខ្លះ?
   ______________________________________________________
6. មានពីរចំណុចដែលមើលទៅគួរឲ្យចាប់អារម្មណ៍:
   ក. តើសំណើចមានពីរប្រភេទអ្វីខ្លះ? នៅក្នុងលោកុប្បត្តិជំពូក ១៧ និង ជំពូក ១៨ គឺជាអំពីសំណើចដោយគ្មានសេចក្ដីជំនឿ ដែលយើងអាចដឹងនូវអារម្មណ៍អស់សង្ឃឹមរបស់ពួកគេ។
   គ. នៅក្នុងលោកុប្បត្តិ ២១:៦ សំណើចមួយទៀតគឺជាការរៀបចំឡើងក្នុងការអបអរសាទរ និង ការអរគុណ ក្នុងកាលដែលសេចក្ដីសន្យាបានសម្រេច។
7. តើមានអ្វីដែលបណ្ដាលឲ្យពួកគេសើចទាំងគ្មានសេចក្ដីជំនឿដូច្នេះ? ____________
   ______________________________________________________
8. តើពួកគេផ្ដោតទៅលើអ្វីខណៈពេលដែលពួកគេអបអរសាទរសេចក្ដីសន្យាបានសម្រេច? _
   ______________________________________________________
9. កាលដើមដំបូលពួកគេមើលមកខ្លួនឯង សម័យយើងសព្វថ្ងៃនេះយើងមើលទៅ "ពេលវេលា" ដែលបានកន្លងផុតទៅ។ ពួកគេទាំងពីរមានវ័យកាន់តែចាស់ ហួសវ័យនឹងមានកូនទៅហើយ នៅពេលដែលពួកគេអស់សំណើច ក្នុងកាលដែលអបអរសាទរ ពួកគេសម្លឹងមើលទៅឯព្រះជាម្ចាស់ ទោះបីជាយ៉ាងណាក្ដីព្រះជាម្ចាស់បានសម្រេចតាមសេចក្ដីសន្យា ក្នុងគ្រាដែលពួកគេអស់សង្ឃឹមទៅហើយ។ ចូររំលឹកឡើងវិញ លោកុប្បត្តិ ១៨:១៤ ________________
   ______________________________________________________

**ការអនុវត្តន៍ផ្ទាល់ខ្លួន:** ជាទូទៅតាមនិន្នាការក្នុងគំនិតរបស់មនុស្ស ដំបូងតែងតែសម្លឹងមើលទៅលើសមត្ថភាព និង ភាពខ្លាំងរបស់ខ្លួន។ យើងរៀបចំគំរោងការអ្វីមួយទៅតាមគំនិត និង សមត្ថភាពផ្ទាល់នៅភាគច្រើនតែងតែត្រូវបរាជ័យ រួចក្រោយមកទើបស្វះស្វែងរកជំនួយ ឬ ការណែនាំពីព្រះជាម្ចាស់។ ជួនកាលជំនួយទាំងនោះគឺមកតាមរយៈអ្នកដទៃ!

តើនៅពេលណាដែលលោកអ្នកធ្លាប់ជួបប្រទះនឹងបញ្ហាណាមួយដែលមិនអាចធ្វើទៅរួច ឬ រឿងរ៉ាវអ្វីមួយដែលហួសពីសមត្ថភាពរបស់ខ្លួន? តើផ្នត់គំនិតវាចេញមកពីភាពទន់ខ្សោយរបស់អ្នកមែនទេ? តើលោកអ្នកឆ្លើយតបវិញយ៉ាងដូចម្ដេច? តើលោកអ្នកអស់សំណើចឬទេ? តើលោកធ្លាប់សួកាន់ខ្លួនថា "តើខ្ញុំគឺជានរណា ហាក់ដូចជាលេងសើចពេកហើយខ្ញុំមិនអាចធ្វើបានឡើយឬទេ? ជាញឹកញាប់សំនួរទាំងនេះវាបានចោទឡើង ក៏ព្រោះតែយើងសម្លឹងមើលមកខ្លួនយើងផ្ទាល់។ ជាញឹកញាប់អ្នកដទៃបានមើលឃើញអំពីសក្ដានុពលដែលលោកអ្នកមានគឺដើម្បីកំណត់អត្តសញ្ញាណ។ តើមានសាច់រឿងដែលបានចោទជាសំនួរឡើង ហើយធ្វើលោកអ្នកអស់សំណើចដោយគ្មានសេចក្ដីជំនឿ ហើយប្រែទៅជាសំណើចនៃការអបអរសាទេ និង សរសើរដម្កើងដល់ព្រះជាម្ចាស់។ ចូរសរសេរនូវការយល់ឃើញរបស់លោកអ្នក ________________________________________________

________________________________________________

## ផ្នែកទី ២

**សេចក្ដីបង្រៀន:** នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក ២២ មានរឿងមួយដែលហាក់ដូចជាមិនគួរឲ្យជឿទាល់តែសោះ។ តែហេតុអ្វីព្រះជាម្ចាស់នៅតែធ្វើកិច្ចការនោះ? ហេតុអ្វីត្រូវការសាកល្បងលោកអប្រាហាំ? តើមិនមែនយូរសម្រាប់គាត់ទេឬអីក្នុងការរង់ចាំទំរាំតែបានកូនប្រុសម្នាក់នេះ? ព្រះអម្ចាស់បើសិនជាព្រះអង្គពិតជាស្រលាញ់មនុស្សដែលព្រះអង្គបង្កើតមកមែន ហេតុអ្វីទ្រង់ត្រូវការសាកល្បងពួកគេធ្វើអ្វី? ចូរយើងតាមដានរឿងនេះទាំងអស់គ្នា! ដូច្នេះចូរអានបទគម្ពីរលោកុប្បត្តិ ២២:១-១៩ ឡើងវិញនោះយើងនឹងបានដឹងសាច់រឿងនេះមិនខាន។

**លំហាត់:** រយៈពេលក្រោយមក ព្រះជាម្ចាស់បានសម្រេចព្រះហឫទ័យនឹងល្បងលចិត្តរបស់លោកអប្រាហាំ។

1. នៅក្នុងខ ២ តើព្រះជាម្ចាស់បានណែនាំដល់លោក អប្រាហាំ យ៉ាងដូចម្ដេចខ្លះ? ________

   ________________________________________________

   ________________________________________________

2. គួរតែជាគ្មានកំហុសអ្វីឡើយចំពោះអស់អ្នកណាដែលព្រះជាម្ចាស់បានកំណត់សំដៅដោយ មានព្រះបន្ទូលថា "ចូរយក ______________________ របស់អ្នកតែមួយ ______________________ ដែលជាទីស្រលាញ់របស់អ្នក"។

3. ពួកគេបានធ្វើដំណើរទៅកាន់តំបន់ម៉ូរីយ៉ា! ភ្នំម៉ូរីយ៉ា គឺជាបរិវេនដែលត្រូវបានគេកសាងទីក្រុងយេរូសាឡឹម ហើយជាកន្លែងដែលក្រោយមក ____________________ នៃស្តេច ____________________________ ត្រូវបានសាងសង់ (២ របាក្សត្រ ៣:១)។ ហើយដែលក្រោយមកទៀតគេបានហៅថា ភ្នំស៊ីយ៉ូន។

**សេចក្តីបង្រៀន:** សំណូមពរឲ្យលោក អប្រាហាំ យកកូនប្រុសរបស់គាត់ទៅថ្វាយជាយញ្ញបូជាដុតតាមទម្លាប់មួយឆ្នាំម្តង ដែលមនុស្សគ្រប់គ្នារស់នៅលើទឹកដីនោះត្រូវថ្វាយយញ្ញបូជាដុតថ្វាយទៅដល់ព្រះរបស់ពួកគេ។ ការថ្វាយយញ្ញបូជាគឺជាការគោរពដល់ព្រះរបស់ពួកគេ ហើយត្រូវធ្វើទៅតាមអ្វីដែលព្រះរបស់ពួកគេបង្គាប់។ ក្នុងមួយឆ្នាំម្តង ព្រះជាម្ចាស់នៃលោក អប្រាហាំ ក៏បានបង្គាប់ឲ្យរាស្ត្ររបស់ទ្រង់ធ្វើការថ្វាយយញ្ញបូជាដល់ទ្រង់ដែរ។ ចូរនឹកចាំថាលោក អដាំ និង នាង អេវ៉ា មិនមែនត្រូវបានយកទៅសម្លាប់ដោយសារព្រះជាម្ចាស់នោះទេ តែមកពីអំពើបាបរបស់ពួកគេគឺការដែលមិនស្តាប់បង្គាប់ព្រះ។ កាអ៊ីនក៏មិនមែនត្រូវបានស្លាប់ដោយសារព្រះជាម្ចាស់ គឺព្រោះតែគាត់បានសម្លាប់បងប្អូនខ្លួនឯងដែរ! លោក ណូអេ លោក អប្រាហាំ នាងហាហ្គា និង លោកស្រី សារ៉ា ក៏សុទ្ធត្រូវបានស្លាប់ព្រោះតែអំពើបាបរបស់ពួកគេដូចគ្នាដែរ។ ព្រះនៃលោក អប្រាហាំ បានប្រាប់គាត់ថា គាត់នឹងបានទៅជាឪពុកនៃជាតិសាសន៍មួយដ៏ធំ គឺព្រះមួយអង្គនោះហើយដែលបានចងសម្ព័ន្ធមេត្រីជាមួយនឹងលោក អប្រាហាំ ថាទ្រង់នឹងធ្វើជាព្រះអម្ចាស់របស់គាត់ ហើយគ្រប់ដំណរនៃពូជពង្សកូនចៅរបស់គ្រប់ៗជំនាន់នឹងធ្វើជារាស្ត្ររបស់ទ្រង់តែមួយអង្គគត់។

**សំនួរឆ្លុះបញ្ចាំង:** តើលោកអ្នកគិតថា ហេតុអ្វីបានព្រះជាម្ចាស់បង្គាប់ឲ្យលោក អប្រាហាំ យកអ៊ីសាក់ដែលជាកូនប្រុសនៃសេចក្តីសន្យាទៅថ្វាយជាយញ្ញបូជាដុតថ្វាយទ្រង់ដូច្នេះ? __________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

**ការឆ្លុះបញ្ចាំង:**

1. តើលោកអ្នកអាចស្រមៃថាលោក អប្រាហាំមានចិត្តក្តុកក្តួលយ៉ាងណាក្នុងពេលដែលគាត់ប្រុងប្រៀបរៀបចំចេញដំណើរទៅ? (៦៣) នៅព្រលឹមស្រាងៗនាថ្ងៃបន្ទាប់ គាត់រឹតតែមានទុក្ខព្រួយជាងថ្ងៃពីម្សិលទៅទៀតក្នុងខណៈពេលគាត់កំពុងតែរៀបចំចងឱសជាបាច់ រួចគាត់ក៏បានចេញដំណើរទៅជាមួយនឹង អ៊ីសាក់ និង អ្នកបម្រើពីរនាក់ទៀត។ តើលោកអ្នកបាននឹកដល់ការ

ពេលពាក្យលាទៅកាន់សារ៉ាភរិយារបស់គាត់ដែរឬទេ? តើគាត់មានបានប្រាប់ភរិយារបស់គាត់ថាព្រះជាម្ចាស់បានបង្គាប់ឲ្យគាត់ធ្វើអ្វីដែរឬទេ? តើលោកស្រីសារ៉ា បានដឹងថាគាត់នឹងលែងបានឃើញមុខកូនប្រុសសម្លាញ់តែមួយរបស់គាត់ដែរឬទេ? មានរឿងជាច្រើនដែលយើងមិនអាចដឹងការពិតថាយ៉ាងណា គឺបានត្រឹមតែស្រមៃប៉ុណ្ណោះ។ តើក្នុងគំនិតរបស់លោកអ្នកមានក្តីស្រមៃយ៉ាងដូចម្តេចខ្លះ? ________________________________________________

________________________________________________

________________________________________________

2. ការធ្វើដំណើរអស់រយៈពេលបីថ្ងៃទើបលោក អប្រាហាំ បានដឹងថាពេលវេលាដែលត្រូវថ្វាយអ៊ីសាក់ធ្វើជាយញ្ញបូជាដុតជិតមកដល់ហើយ (៦៤)។ នៅក្នុង ៦៥ ពួកគេក៏ត្រូវបែកពីអ្នកបម្រើទាំងពីរដោយប្រាប់ថាចូរចាំនៅត្រង់នេះ គាត់ត្រូវឡើងទៅលើភ្នំដើម្បីថ្វាយបង្គំព្រះជាម្ចាស់ហើយគាត់នឹងត្រឡប់មកវិញ។ សម្រាប់លោក អប្រាហាំ ការធ្វើអាសនាដើម្បីថ្វាយបង្គំព្រះ គឺមិនដូចរាល់ឆ្នាំឡើយ! យើងមិនដឹងការពិតយ៉ាងណានោះទេ តែបើតាមការសន្និដ្ឋាឃើញថាអ៊ីសាក់ គឺធ្លាប់បានដឹងត្រឹមតែការយកសត្វទៅសម្លាប់ដើម្បីថ្វាយយញ្ញបូជាប៉ុណ្ណោះ។
3. នៅក្នុង៦៦ បានប្រាប់យើងឲ្យដឹងថាលោក អប្រាហាំ បានដាក់ឧសឲ្យ អ៊ីសាក់ជាអ្នកលីហើយគាត់កាន់ភ្លើង (ប្រហែលជាគុបភ្លើង) និង កាំបិតដើរបណ្តើរគ្នាឡើងទៅលើភ្នំ។ ចូរស្រមៃពីការសន្ទនាគ្នាដ៏គួរឲ្យសង្វេករហូតដល់កន្លែងថ្វាយយញ្ញបូជា។ រំពេចនោះ អ៊ីសាក់ បានដឹងថាគឺមានខ្វះអ្វីម្យ៉ាង ព្រោះពួកគេមានឧស មានភ្លើង ប៉ុន្តែ ពួកគេមិនទាន់មានកូនចៀមសម្រាប់ដុតថ្វាយយញ្ញបូជានៅឡើយ។
4. ចូរស្រមៃដល់អ្នកបម្រើទាំងពីរនាក់នោះវិញ ពួកគេមិនបានសម្រិបជើងឪពុកកូនគេទាំងពីរទៀតឡើយ ព្រោះបានដើរជំរង់ទៅរកកន្លែងថ្វាយបង្គំព្រះបានកាន់តែឆ្ងាយណាស់ហើយ។

**ការទន្ទេញចាំមាត់៖** មានពាក្យសម្តីមួយចំនួនដែលលោក អប្រាហាំ និយាយទៅកាន់កូនប្រុសរបស់គាត់ដែលធ្វើយើងមិនអាចបំភ្លេចបាន។ តើគាត់បាននិយាយដូចម្តេចខ្លះ (៦៨)? ចូរសរសេរពាក្យទាំងនោះ "ព្រះជាម្ចាស់នឹង ________________________________________________

________________________________________________"។

ជាមួយគ្នានេះដែរ លោកអ្នកក៏ត្រូវបានលើកទឹកចិត្តឲ្យកត់ត្រាទុកនូវពាក្យទាំងអស់នោះនៅលើក្រដាសកត់ចំណាំរបស់លោកអ្នកផងដែរ។ បន្ថែមពីលើការកត់ត្រានូវពាក្យសម្តីរបស់គាត់ហើយ ចូរសរសេរនូវ គំនិត ឬ សេចក្តីអធិស្ឋាននៅក្នុងចិត្តរបស់លោកអ្នក ធ្វើដូច្នេះ បើថ្ងៃក្រោយទៅការសិក្សាតម្រូវឲ្យសិក្សអំពីខមួយនេះ នោះវាមិនទៅណាឆ្ងាយពីលោកអ្នកឡើយ។

## ផ្នែកទី ៣
## លំហាត់:

1. នៅក្នុងខ ៩ និង ខ១០ គឺជាអង្គហេតុសំខាន់នៃសាច់រឿង! តើលោក អប្រាហាំ បានធ្វើអ្វីខ្លះ?
   ក. បានស្អាង ________________________________
   ខ. ដំរៀប ________________________________
   គ. បានចង ________________________________
   ឃ. ដាក់ផ្តេក ________________________________
   ង. លូកដៃទៅចាប់យក ________________________________
   ច. ប្រុងនឹង ________________________________
2. គឺរឿងមួយមិនអាចជួយបានទេ តែសំនួរសួរថា: ចុះចំណែកអ៊ីសាក់វិញ? តើអ៊ីសាក់គិតនឹងត្រូវធ្វើដូចម្តេច នៅពេលបានដឹងថាខ្លួនត្រូវជុតសម្រាប់ជាយញ្ញបូជានោះ? តើលោកអ្នកគិតថាអ៊ីសាក់បានរៀនពី សេចក្តីជំនឿ និង ឳពុករបស់ខ្លួនយ៉ាងដូចម្តេចខ្លះដែលមានទៅលើព្រះ?

   ________________________________

   ________________________________

   ________________________________

   ________________________________

3. តើមានអ្វីដែលពិបាកសម្រាប់ឳពុងជាងហេតុការណ៍នេះដែរឬទេ? ហើយនេះគឺជាខណ:ពេលដែលព្រះជាម្ចាស់ទូលអង្វរ! នៅក្នុងខ ១១ មានពាក្យមួយបានបន្លឺឡើងថា "ប៉ុន្តែ" នោះទេវត្តានៃព្រះជាម្ចាស់បានពោលមកកាន់លោក អប្រាហាំ។ តើទេវត្តាបានពោលមកកាន់ អប្រាហាំ ថាដូចម្តេច (ខ១២)? ________________________________

   ________________________________

   ________________________________

4. ហេតុអ្វីគឺជាការសាកល្បង (ខ១២)? ________________________________

   ________________________________

ព្រះជាម្ចាស់ទ្រង់ជ្រាប លោក អប្រាហាំ បានដឹង ហើយអ៊ីសាក់ក៏បានដឹង!

**សេចក្តីបង្រៀន:** យើងបានដឹងថាលោក អប្រាហាំ គាត់មានសេចក្តីកោតខ្លាចដល់ព្រះជាម្ចាស់ (លោកុប្បត្តិ ២២:១២)

**និយមន័យ:** ពាក្យថា "ខ្លាច" មានអត្ថន័យផ្សេងៗពីគ្នាជាច្រើន! នៅក្នុងបទគម្ពីរពាក្យថា "ខ្លាច" មិនមានន័យថា ភ័យខ្លាចគួរឲ្យញញើតនោះទេ តែវាមានបង្កប់អត្ថន័យដោយសេចក្តីស្រលាញ់ ការគោរព ការជឿជាក់ គោរពកោតខ្លាច។ លោក អប្រាហាំ បានគោរពកោតខ្លាចចំពោះព្រះជាម្ចាស់ ថ្វីដ្បិតតែគាត់មានសេចក្តីស្រលាញ់ចំពោះកូនប្រុសរបស់គាត់យ៉ាងណាក៏ដោយ។

**ចូលឱ្យកាន់តែជ្រៅ:** នៅក្នុងខ ១២ យើងឃើញមានពាក្យថា "កូនតែមួយ" ពាក្យនេះត្រូវបានចង្អុលបង្ហាញក្នុងខយោងនៃចុងទំព័រនៃព្រះគម្ពីរ ហើយនៅមានមួយកន្លែងទៀតគឺនៅក្នុងលោកុប្បត្តិ ២២:២ ដែលព្រះជាម្ចាស់មានព្រះបន្ទូលយ៉ាងប្រុងប្រយ័ត្នទៅកាន់លោក អប្រាហាំ ថាឲ្យគាត់យកកូនប្រុសតែមួយទៅថ្វាយជាយញ្ញបូជាដុត។ នៅមានខគម្ពីរមួយកន្លែងទៀតដែលបានប្រើពាក្យដូចគ្នានេះដែរគឺនៅក្នុងព្រះគម្ពីរ យ៉ូហាន ៣:១៦។ ចូរកត់ត្រាទុកនូវខទាំងនេះ ____________________

____________________________________________________________

____________________________________________________________

____________________________________________________________

1. នៅក្នុងបទគម្ពីរតើនរណាដែលព្រះវរបិតា? ____________________________
2. តើនរណាគឺជាកូនប្រុស ដែលជាកូនប្រុសតែមួយ? ________________________

តាមរយៈខគម្ពីរយោងទាំងអស់នេះ យើងបានសិក្សាអំពីសាច់រឿងនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២២ គឺជាព្រឹត្តិការណ៍ដំបូងគេដែលបានកើតឡើងជាច្រើនឆ្នាំណាស់មកហើយ នៅលើភ្នំម៉ូរីយ៉ា ឬ ភ្នំស៊ីយ៉ូន នៅពេលដែល ព្រះជាម្ចាស់បានបង្ហូរសេចក្តីស្រលាញ់ដ៏អស្ចារ្យរបស់ទ្រង់មកសម្រាប់យើងតាមរយៈការប្រទានព្រះបុត្រាស្ងួនភ្ងាតែមួយរបស់ទ្រង់ គឺជាអង្គព្រះយេស៊ូវឲ្យមកធ្វើជាដង្វាយលោះបាបចុងក្រោយបង្អស់ដើម្បីលោះបាបពួកយើងទាំងអស់គ្នា និង មនុស្សគ្រប់គ្នាក្នុងលោកីយ៍នេះទាំងមូលដែរ។

ចំពោះយញ្ញបូជាសម្រាប់លោះបាប ព្រះវរបិតាជាអម្ចាស់ដែលគង់នៅស្ថានសួគ៌ ទ្រង់មិនអាចនឹងបញ្ឈប់ការថ្វាយបុត្រាស្ងួនភ្ងារបស់ទ្រង់ទុកជាយញ្ញបូជានៅលើអាសនានៃឈើឆ្កាងបានឡើយ។ ទ្រង់នឹងមិនបញ្ឈប់ការថ្វាយយញ្ញបូជាឡើយ លុះត្រាណាតែមនុស្សលោកទាំងអស់ត្រូវបានសង្គ្រោះឲ្យរួចពីសេចក្តីស្លាប់ដ៏អស់កល្បជានិច្ច។ កូនចៀមត្រូវបានឃើញនៅនឹងគម្ពោតព្រៃ! គ្មានការថ្វាយយញ្ញបូជាណាមួយផ្សេងទៀតដែលអាចរកឃើញនោះឡើយ គឺមានតែសេចក្តីការសុគត់របស់ព្រះបុត្រាដ៏គ្រប់លក្ខណ៍

ទើបអាចជួយបាន! ដូច្នេះហើយទើបបានជាទ្រង់ត្រូវធ្វើដូច្នេះ ហើយដោយសារការបង្ហូរព្រះលោហិតរបស់ព្រះយេស៊ូវ ទើបមនុស្សទាំងអស់នៅលើផែនដីអាចទទួលការអត់ទោសឲ្យរួចពីអំពើបាប។ គ្រប់ៗគ្នាអាចប្រកាសថាពួកគេបានរួចពីចំណងនៃអំពើបាបដោយសារដង្វាយយញ្ញបូជានៃអង្គព្រះយេស៊ូវ។

សម្រាប់អស់អ្នកដែលមានចិត្តចង់ដឹង ចង់យល់គឺនៅមានខយោងមួយទៀត។ បន្ថែមលើបទគម្ពីរ យ៉ូហាន ៣:១៦ ចូរពិចារណាពី ១ យ៉ូហាន ៤:៩! ជាថ្មីម្តងទៀតយើងអាចយល់ឃើញថា ទាំងក្នុងព្រះគម្ពីរសញ្ញាចាស់ និង សញ្ញាថ្មី សុទ្ធតែមានការពាក់ព័ន្ធគ្នាដោយមានខយោងនៅខាងក្រោមនៃទំព័រព្រះគម្ពីររបស់យើង។ តើមានការយល់ដឹងអ្វីខ្លះតាមរយៈបទគម្ពីរទាំងនេះ សម្រាប់ដាក់បញ្ចូលបន្ថែមទៅក្នុងការសិក្សារបស់លោកអ្នក អំពីដង្វាយយញ្ញបូជារបស់ព្រះជាម្ចាស់ដើម្បីលោះបាបមនុស្សទាំងអស់នៅលើផែនដីនេះ? ____________________________________________

____________________________________________

____________________________________________

**ការទន្ទេញចាំមាត់:** នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២២:១២ មានពាក្យមួយឃ្លាបានថ្លែងឡើងថា "ឥឡូវនេះយើងដឹង..." លោកអ្នកត្រូវបានលើកទឹកចិត្តឲ្យទន្ទេញនូវបទគម្ពីរបន្ថែមគឺ យ៉ូហាន ៣:១៦ និង ១ យ៉ូហាន ៤:៩។ ចូរដាក់ក្រដាសកត់ចំណាំរបស់លោកអ្នកឲ្យបានត្រឹមត្រូវល្អ ដ្បិតវានឹងជួយដល់លោកអ្នក ហើយវានឹងក្លាយទៅជាកំណព្វសម្បត្តិនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្រាប់លោកអ្នក។ ជាមួយគ្នានោះលោកអ្នកក៏ត្រូវតែអាននូវខគម្ពីរចំនួនទៀតដែលនៅជាប់នឹងខយោងទាំងនោះផងដែរ ជាពិសេសគឺនៅក្នុងព្រះគម្ពីរសញ្ញាថ្មីតែម្តង នោះនឹងបានជាជំនួយបន្ថែមដល់ប្រាជ្ញា និង ការយល់ដឹងសម្រាប់បន្តការសិក្សារបស់លោកអ្នកទៅថ្ងៃខាងមុខទៀត។ ចូរមានចិត្តរីករាយជាមួយនឹងទ្រព្យ សម្បត្តិដែលបានមកពីការប្រម៉ាញ់ គឺការប្រម៉ាញ់ទ្រព្យសម្បត្តិនៃព្រះបន្ទូលព្រះជាម្ចាស់ ហើយចូរកុំភ្លេចឲ្យសោះថាលោកអ្នកត្រូវតែចែករំលែកនូវទ្រព្យសម្បត្តិទាំងនេះទៅអ្នកដទៃយ៉ាងពេញទំហឹង។

## ផ្នែកទី ៤

**លំហាត់:** អារម្មណ៍ដ៏រីករាយរបស់ឪពុក និង កូនប្រុស គឺពិតជាមានយ៉ាងលើសលប់ប្រាកដណាស់! បុត្រារបស់ទ្រង់ គឺត្រូវដាក់ព្រះជន្មរបស់ទ្រង់ទុកជាដង្វាយយញ្ញបូជា!

1. នៅក្នុងខ ១៣ ជំនួសដោយការសម្លាប់អ៊ីសាកធ្វើជាយញ្ញបូជា តើមានអ្វីមកធ្វើជាដង្វាយយញ្ញបូជាថ្វាយដល់ព្រះជាម្ចាស់ជំនួសអ៊ីសាក់? ________________________ សូមរំលឹកជាថ្មីម្តងទៀតថាដង្វាយដែលត្រូវថ្វាយទៅព្រះទាល់តែមានការសម្លាប់ដោយបង្ហូរឈាម។

2. លោក អប្រាហាំបានហៅកន្លែងនោះថា ព្រះយេហូវ៉ា យូរេ៉ ដែលមានន័យថា ________ ____________________ ។ ក្នុងខណៈពេលដែលយើងពិចារណាអំពីបទគម្ពីរ យ៉ូហាន ៣:១៦ យើងនឹកឃើញម្តងទៀតថាព្រះជាម្ចាស់បានប្រទានព្រះបុត្រារបស់ទ្រង់ឲ្យមកធ្វើជាអង្គសង្គ្រោះដល់យើង។
3. នៅក្នុងខ ១៥-១៨ គឺមានសម្លេងស្រដៀងៗគ្នា! នៅក្នុងពាក្យពេជ្ររបស់លោកអ្នក តើព្រះជាជាម្ចាស់មានបន្ទូលទៅកាន់លោក អប្រាហាំ យ៉ាងដូចម្តេច? ____________________

____________________________________________________________

____________________________________________________________

4. នៅក្នុងខ ១៩ តាមព្រះគម្ពីរបានប្រាប់យើងថាលោក អប្រាហាំ និង អ៊ីសាក់បានរស់នៅឯណា?

____________________________________________________________

**តើយើងបានរៀនអ្វីខ្លះអំពីព្រះជាម្ចាស់?** ប្រហែលជាមានពាក្យមួយដែលធ្វើឲ្យយើងនឹកឃើញដល់សេចក្តីស្រលាញ់ដ៏អស្ចារ្យព្រះជាម្ចាស់សំពោះមនុស្សលោក នោះគឺជាពាក្យដ៏មានតម្លៃណាស់។ ព្រះអម្ចាស់បានផ្តល់នូវព្រះគុណចំពោះលោកស្រីសារ៉ា ដោយព្រោះទ្រង់បានគោរពតាមសេចក្តីសន្យារបស់ទ្រង់ជាមួយនឹងនាង ដូច្នេះតាមរយៈមេរៀននេះបានធ្វើឲ្យបានដឹងថា ព្រះអម្ចាស់នៃយើងទ្រង់ពិតជាប្រកបដោយព្រះគុណយ៉ាងក្រៃលែង។ ព្រះគុណនៃព្រះជាម្ចាស់បានបង្ហូរមកយើងរាល់គ្នា គឺជាអ្វីដែលយើងមិនរកបានទោះបីខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ! ព្រះអង្គប្រកបដោយព្រះគុណដោយទ្រង់បានគោរពតាមសេចក្តីសន្យាជានិច្ច ទ្រង់បានសង្គ្រោះយើងឲ្យរួចពីអំពើបាបដោយគ្មានលក្ខ័ណ្ឌតាមគឺតាមរយៈព្រះរាជបុត្រាទ្រង់តែមួយ ទ្រង់បានបំពេញគ្រប់ទាំងសេចក្តីត្រូវការរបស់យើងទាំងខាងសាច់ឈាម និង ខាងព្រលឹងវិញ្ញាណ។

## ការអនុវត្តន៍ផ្ទាល់ខ្លួនៈ

1. កាលណាយើងបានរៀនអំពីព្រះជាម្ចាស់កាន់តែច្រើន នោះយើងនឹងបានដឹងថាយើងអាចធ្វើបានកាន់តែតិច! យើងអាចប្រមូលនូវការអនុវត្តន៏ទាំងប៉ុន្មានសម្រាប់មេរៀនមួយនេះ ខណៈពេលដែលយើងធ្វើការសង្កេតអំពីលោក អប្រាហាំ។ គាត់ទទួលការឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងព្រះគុណនៃព្រះជាម្ចាស់ គឺទៅថ្វាយបង្គំទ្រង់។ គាត់បានថ្វាយបង្គំរហូតដល់គាត់ និង អ៊ីសាក់កូនប្រុសតែមួយរបស់គាត់ដើម្បីទុកធ្វើជាដង្វាយយញ្ញបូជាដល់ព្រះជំនួសកូនចៀម។ តើយើងមានអ្វីធ្វើទុកជាដង្វាយយញ្ញបូជុត ដែលសម្គាល់ពីការថ្វាយបង្គំរបស់យើង? នៅក្នុងព្រះគម្ពីរទំនុកដម្កើង ៥១:១៧ បានប្រាប់យើងថាតើដង្វាយបែបណាដែលព្រះជាម្ចាស់ទ្រង់សព្វព្រះ

ហឫទ័យ។ ចូរកត់ត្រាខគម្ពីរនោះទុក "ដង្វាយដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ ______

______________________________________________

______________________________ ដែលលោកអ្នកនឹងគ្មានបំណងចិត្តចង់បាន។

2. តើលោកអ្នកនឹងមានដង្វាយអ្វីដើម្បីថ្វាយទៅចំពោះព្រះភ័ក្រព្រះជាម្ចាស់ ដួងចិត្តដែលខ្ទេចខ្ទាំការលន់តួបាប ដួងចិត្តនៃការកែប្រែចិត្តគំនិតចេញពីអំពើបាប និង សេចក្ដីអាម៉ាស់។ ចូរធ្វើការចំណាយពេលវេលាខ្លះ ដើម្បីចែកចាយដោយភាពស្មោះត្រង់នូវរឿងរ៉ាវទាំងនេះទៅចំពោះព្រះជាម្ចាស់ ______________________________________

______________________________________________

______________________________________________

3. ព្រះជាម្ចាស់ទ្រង់សព្វព្រះហឫទ័យនឹងពាក្យសម្ដី និង ការអរព្រះគុណរបស់យើងទៅចំពោះទ្រង់! ចូរអានទំនុកដម្កើង ៥១:១៥ "....នោះមាត់ទូលបង្គំនឹងបានប្រកាសប្រាប់ពីសេចក្ដីសរសើររបស់ទ្រង់"។ ដូច្នេះ តើយើងសរសើរដម្កើងព្រះជាម្ចាស់យ៉ាងដូចម្ដេច? តើមានន័យដូចម្ដេច? បើសិនជាយើងសរសើរដម្កើងដល់ទ្រង់ តើយើងនឹងថ្លែងចេញយ៉ាងដូចម្ដេច? យើងសរសើរដម្កើងទ្រង់ដោយការចែកចាយជាមួយនឹងទ្រង់ជាមួយនឹងពាក្យសម្ដីនៃការអរព្រះគុណរបស់យើង។ យើងអរព្រះគុណទ្រង់ ដ្បិតទ្រង់គឺជាព្រះអស់លើទាំងព្រះ! ចូររំលឹងសារឡើងវិញ ខ្លះៗថាតើ "យើងបានរៀនអ្វីខ្លះអំពីព្រះជាម្ចាស់" នៅត្រង់ផ្នែកនេះ និង ផ្នែកមុន? ចូរអរព្រះគុណទ្រង់ចំពោះកិច្ចការទាំងប៉ុន្មានដែលទ្រង់បានធ្វើ សម្រាប់សេចក្ដីផ្គត់ផ្គង់នានា។ យើងទាំងអស់គ្នាពិតជាមានចិត្តរីករាយណាស់ នៅពេលដែលបានទទួលការដឹងគុណចំពោះអ្វីដែលយើងបាននិយាយ ឬ បានធ្វើ។ យើងមានសេចក្ដីអំណរនៅក្នុងចិត្តណាស់ នៅពេលណាដែលមនុស្សម្នាបានទទួលស្គាល់អំពីអ្វីម្យ៉ាងអំពីចរិតលក្ខណៈ និង អាកប្បកិរិយាផ្ទាល់របស់យើង។ ចូរយើងទាំងអស់គ្នាពោលពាក្យសរសើរដម្កើង និង ការអរព្រះគុណដល់ព្រះជាម្ចាស់ចុះ!

**សេចក្ដីអធិស្ឋានៈ** ចូរឲ្យពេលវេលានេះ គឺជាឱកាសសម្រាប់លោកអ្នករីករាយក្នុងការថ្វាយដង្វាយនៃការអរព្រះគុណ និង ការសរសើរដម្កើងរបស់លោកអ្នកៈ ______________________

______________________________________________

______________________________________________

______________________________________________

______________________________________________

## ផ្នែកទី ៥

**សេចក្ដីណែនាំ:** យើងប្រហែលជាត្រូវបញ្ចប់សាច់រឿងរបស់លោក អប្រាហាំត្រឹមនេះចុះ! នៅក្នុង លោកុប្បត្តិ ២៣ បានប្រាប់យើងអំពីលោកស្រីសារ៉ា គាត់រស់បាន __________ ឆ្នាំ ហើយគាត់ស្លាប់ នៅ ________________________________។ នៅក្នុងជំពូកនេះ ក៏មានជាប់ទាក់ទងនឹង លោក អប្រាហាំ ដែលគាត់បានរៀបដីមួយកន្លែងត្រៀមសម្រាប់ទុកកប់សពដែរ។ ឥឡូវនេះ ចូររំលង ផ្លោះទៅដល់ លោកុប្បត្តិ ២៥ តែម្ដង!

**កិច្ចការ:** ចូរលោកអ្នកអាចព្រះគម្ពីរលោកុប្បត្តិ ២៥:៧-១១

**លំហាត់:**

1. តើលោក អប្រាហាំរស់នៅបានអាយុប៉ុន្មានឆ្នាំ (ខ៧)? ______________________
2. តើនៅក្នុងខ ៨ បានប្រាប់យើងដូចម្ដេចខ្លះអំពីលោក អប្រាហាំ នៅពេលដែលគាត់ស្លាប់? ______________________________________________________
______________________________________________________
3. តើនរណាជាអ្នកកប់សពរបស់គាត់ (ខ៩)? ______________________
4. តើគេកប់សពរបស់គាត់នៅឯណា (ខ៩-១០)? ______________________
5. តើគេកប់សពរបស់លោក អប្រាហាំជាមួយនរណា? ______________________
6. ព្រះជាម្ចាស់បានប្រទានពរដល់ អ៊ីសាក់ក្រោយពីឪពុកគាត់បានស្លាប់ទៅ តើអ៊ីសាក់បានទៅរស់នៅឯណា? ______________________________________________

   **ចំណាំ:** ទិដ្ឋភាពបន្ទាប់នៃមេរៀននេះ គឺត្រូវបានរចនាឡើងសម្រាប់ឲ្យលោកអ្នកអនុវត្តជាមួយ នឹង ខយោង ឬ សេចក្ដីយោង។ បើសិនជានៅក្នុងព្រះគម្ពីររបស់លោកអ្នកគ្មានខយោងទេ ដូច្នេះលោកអ្នកត្រូវប្រើប្រាស់ខយោងដែលបានផ្ដល់ជូនតាមរយៈលំហាត់។

7. ចូរកំណត់ចំណាំខយោងនៅបន្ទាប់ពាក្យថា "រយ" ចូរស្វែងរកខយោងដែលបានបង្ហាញជូន។ ចូរអានខនូវបទគម្ពីរ លោកុប្បត្តិ ១៦:៧-១៤ អ៊ីសាក់គឺជាកូនប្រុសរបស់លោក អប្រាហាំ បានផ្លាស់ទៅរស់នៅជិត តំបន់ ឡាហា-រយ។ រំលឹកសារឡើងវិញនូវបទពិសោធន៏ខុសឆ្គងរបស់នាង ហាហ្គា ម្ដាយរបស់អ៊ីស្មាអែល ហើយអ៊ីស្មាអែលគឺជាកូនប្រុសម្នាក់ទៀតរបស់លោក អប្រាហាំ កាលពួកគេនៅតំបន់ ឡាហា-រយ មុនពេលដែលអ៊ីស្មាអែលបានកើតមក នៅពេលដែលនាង បានចាកចេញពីលោកស្រីសារ៉ាយ។

**សំនួរឆ្លុះបញ្ចាំង:** សេចក្តីស្លាប់គឺមិនមែនជារឿងដែលយើងត្រូវបានគិតជាញឹកញាប់នោះទេ ជាពិសេសក្នុងកាលដែលយើងនៅមានវ័យក្មេងនៅឡើយ។ ប៉ុន្តែ ប្រហែលជានឹងដល់ពេលវេលាមួយសមរម្យ ក្នុងការពិចារណាអំពីវ័យដែលចេះតែធ្វើដំណើរទៅមុខ ហើយ ការពិតនឹងត្រូវកើតឡើងក្នុងថ្ងៃណាមួយមិនខាន យើងទាំងអស់គ្នាក៏មិនខុសពីលោក អប្រាហាំ និង លោកស្រីសារ៉ាដែរ គឺនឹងទៅជាចាស់ ហើយស្លាប់។

1. តើលោកអ្នកគិតថាក្រោយពេលដែលលោកអ្នកស្លាប់ទៅនឹងត្រូវកប់នៅឯណាដែរទេ?
2. តើលោកអ្នកគិតថានឹងឲ្យគេកប់សពរបស់លោកអ្នកជាមួយនរណា?
3. តើនរណានឹងត្រូវទទួលយកកេរ្តិ៍មរតករបស់លោកអ្នកក្រោយពីស្លាប់ទៅ?
4. តើលោកអ្នកនឹងផ្តល់អំណោយដល់អស់អ្នកដែលនឹងរស់នៅបន្ទាប់ពីលោកអ្នកដែរឬទេ?
5. តើលោកអ្នកចង់អ្នកដទៃនិយាយអំពីលោកអ្នកដូចម្តេចនៅពេលស្លាប់ទៅ?
6. តើលោកអ្នកចង់បន្សល់ទុកកេរ្តិ៍ដំណែលអ្វីសម្រាប់កូនចៅរបស់លោកអ្នក?
7. តើលោកអ្នករៀបចំជំហានដូចម្តេចសម្រាប់ហេតុការណ៍ទាំងអស់នោះ?

**សេចក្តីអធិស្ឋាន:** ឱព្រះអម្ចាស់អើយ! ព្រះអង្គបានប្រទានពរដល់លោក អប្រាហាំ និង លោកស្រីសារ៉ា ឲ្យពួកគេមានអាយុវែង ទ្រង់បានស្មោះត្រង់ជាមួយពួកគេដោយបានគោរពតាមសេចក្តីសន្យាថែមទាំងប្រទានឲ្យគេមានដី និង កូនប្រុសទៀតផង។ ព្រះអង្គបានធ្វើឲ្យពួកគេទាំងពីរនាក់បានទៅជាឪពុកម្តាយនៃជាតិសាសន៍មួយដ៏ធំ មិនតែប៉ុណ្ណោះក៏ប្រទានពរដល់អ៊ីសាក់ផងដែរ។ ដោយសារទ្រង់បានស្មោះត្រង់ចំពោះពួកគេទាំងនោះ ដូច្នេះទ្រង់ក៏នឹងស្មោះត្រង់ចំពោះទូលបង្គំដែរ! ទូលបង្គំសូមអរព្រះគុណសម្រាប់សេចក្តីស្រលាញ់ដ៏អស្ចារ្យដែលទ្រង់បានបង្ហូរមកលើទូលបង្គំ និង អស់អ្នកដែលទូលបង្គំស្រលាញ់។ ខណៈពេលដែលទូលបង្គំនឹកគិតដល់រឿងនេះ ជីវិតរបស់ទូលបង្គំក៏នឹងដូច្នោះដែរ គឺនឹងត្រូវស្លាប់ទៅក្នុងថ្ងៃណាមួយ ហេតុនេះទូលបង្គំសូមអធិស្ឋាន ______________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

**សេចក្តីបង្រៀន:** តួអង្គដូចជា អេបិល លោក ណូអេ គឺសុទ្ធតែត្រូវបានលើកមកនិយាយ នៅក្នុងមេរៀន **ផែនការរបស់ព្រះជាម្ចាស់ ជម្រើសរបស់យើង**។ តាមរយៈសេចក្តីយោងបន្ថែមអំពីសេចក្តីជំនឿត្រូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរហេព្រើរជំពូក ១១ ខណៈពេលដែលយើងហៀបនឹងបញ្ចប់សាច់រឿងរបស់លោក អប្រាហាំ យើងត្រឡប់ក្រោយមករកពាក្យថា "ដោយសារសេចក្តីជំនឿ... " ចូរអាន

ព្រះគម្ពីរហេព្រើរ ១១:៨-១៩ រួចចូរកូសចំណាំនូវខយោងនិមួយៗ។ ក្រោយពីបានអានចប់ លោកអ្នកហាក់ដូចជាធ្លាប់បានដឹងពីមុនមក ពីព្រោះថាលោកធ្លាប់បានសិក្សាអំពីសាច់រឿងរបស់លោក អប្រាហាំ និង លោកស្រីសារ៉ា ម្ដងរួចមកហើយគឺនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១២-២៥។

## លំហាត់:

1. នៅក្នុងព្រះគម្ពីរហេព្រើរ ១១:៨ គឺបានផ្ដល់នូវខយោងពីរ! តើលោកអ្នកអាចកំណត់ទីតាំង អំពីកន្លែងនៃសាច់រឿងរបស់លោក អប្រាហាំ ដែលត្រូវបានប្រាប់នៅក្នុងខយោងទាំងនេះ

   ក. តើគឺជាសាច់រឿងអ្វី? ______________________________

   ខ. តើខយោងបានប្រាប់យ៉ាងដូចម្ដេចខ្លះ? ______________________

   គ. តើនៅក្នុងជំពូកណាដែលលោក អប្រាហាំត្រូវបានត្រាស់ហៅ បានប្រទានសេចក្ដីសន្យា ហើយការស្ដាប់បង្គាប់នៅតែបន្តរហូត ទោះបីជាគាត់មិនដឹងច្បាស់ថានឹងត្រូវទៅជាយ៉ាងណាក៏ដោយ។ គឺនៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក ______________________

   **ចំណាំ:** ក្នុងចំណោមពួកយើង អស់អ្នកណាដែលមានព្រះគម្ពីរគ្មាន១យោងនៅខាងក្រោម ដូច្នេះ ១យោងគឺនៅក្នុងលោកុប្បត្តិ ១២:១-៤,៧។

2. នៅក្នុងព្រះគម្ពីរហេព្រើរ ១១:៩ បានប្រាប់យើងថា "ដោយសារសេចក្ដីជំនឿ" លោក អប្រាហាំបានសង់ផ្ទះរបស់គាត់នៅលើទឹកដីសន្យា ហើយគាត់បានរស់នៅលើទឹកដីនោះដូចជាសាសន៍ដទៃ គឺដោយរស់នៅក្រោមក្រណាត់តង់ធ្វើជាជំរូល។

   ក. តើខយោងបានប្រាប់ដូចម្ដេចអំពីពាក្យថា "តង់"? ________________

   ______________________________________________

   ខ. តើនៅក្នុងជំពូកណានៃព្រះគម្ពីរលោកុប្បត្តិដែលបានប្រាប់ពីអត្ថន័យនេះ? លោកុប្បត្តិ _ ________________ និង លោកុប្បត្តិ ________________

   **ចំណាំ:** បើសិនជានៅក្នុងព្រះគម្ពីររបស់លោកអ្នកគ្មាន១យោងទេ ដូច្នេះលោកអ្នកត្រូវតែប្រើ ការកំណត់ទីតាំងនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១២:៨ និង ១៨:១,៩។

3. នៅក្នុងព្រះគម្ពីរហេព្រើរ ១១:១១ គឺបានផ្ដល់នូវខយោងជាច្រើន

   ក. តើគឺជារឿងអ្វី? ______________________________

   ខ. តើខយោងបានបញ្ជាក់អត្ថន័យនៃពាក្យថា "ឪពុក" យ៉ាងដូចម្ដេច? __________

   គ. តើព្រះគម្ពីរលោកុប្បត្តិជំពូកណា ដែលបានបញ្ជាក់ថាសេចក្ដីសន្យារបស់ព្រះជាម្ចាស់ត្រូវបានសម្រេចចំពោះអប្រាហាំ? លោកុប្បត្តិ______________________

**ចំណាំ:** បើសិនជានៅក្នុងព្រះគម្ពីររបស់លោកអ្នកគ្មានខយោងទេ ដូច្នេះលោកអ្នកត្រូវតែប្រើ ការកំណត់ទីតាំងនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២១:២។

4. **នៅក្នុងព្រះគម្ពីរហេព្រើរ ១១:១២...**
   **ក. តើខយោងដូចម្ដេចអំពីពាក្យថា "មាត់សមុទ្រ"? ____________________**
   **ខ.តើព្រះគម្ពីរលោកុប្បត្តិជំពូកណា ដែលបានប្រាប់ថាព្រះជាម្ចាស់ចង់សម្ព័ន្ធមេត្រីនៃសេចក្ដីសន្យាជាមួយលោក អប្រាហាំ? លោកុប្បត្តិ ____________________**
   **គ. តើសម្ព័ន្ធមេត្រីនៃសេចក្ដីសន្យាគឺជាអ្វី? ____________________**

________________________________________

**ចំណាំ:** បើសិនជានៅក្នុងព្រះគម្ពីររបស់លោកអ្នកគ្មានខយោងទេ ដូច្នេះលោកអ្នកត្រូវតែប្រើ ការកំណត់ទីតាំងនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២២:១៧។

5. **នៅក្នុងព្រះគម្ពីរហេព្រើរ ១១:១៧-១៩ នៅមានរឿងមួយទៀតដែលនិយាយស្រដៀងគ្នាដែរ។**
   **ក. តើគឺជាសាច់រឿងអ្វី? ____________________**
   **ខ. តើមានខយោងអ្វីដែលលោកអ្នកអាចយកមកប្រើដើម្បីកំណត់ថាសាច់រឿងនេះត្រូវបានរកឃើញនៅឯណា? ____________________**
   **ខយោងតទៅនេះប្រហែលជាពាក្យថា "ថ្វាយយញ្ញបូជា"។**
   **គ. តើព្រះគម្ពីរលោកុប្បត្តិជំពូកណា ដែលព្រះជាម្ចាស់បានសាកល្បងចិត្តលោក អប្រាហាំ អំពីការស្ដាប់បង្គាប់ដោយបង្គាប់ឲ្យយក អ៊ីសាក់ដែលជាកូនប្រុសតែមួយរបស់គាត់ទៅថ្វាយជាយញ្ញបូជាដុតថ្វាយទៅព្រះជាម្ចាស់? លោកុប្បត្តិ ____________________**

**ចំណាំ:** បើសិនជានៅក្នុងព្រះគម្ពីររបស់លោកអ្នកគ្មានខយោងទេ ដូច្នេះលោកអ្នកត្រូវតែប្រើ ការកំណត់ទីតាំងនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ២២:១-១០។

**នៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិមានជាច្រើនជំពូក ដែលបានរៀបរាប់អំពីសាច់រឿងរបស់លោក អប្រាហាំ ហើយនៅក្នុងកណ្ឌគម្ពីរហេព្រើរក៏មានជាច្រើនខដែរបានរំលឹកយើងអំពីរឿងរ៉ាវទាំងអស់នោះ ព្រមទាំងលើកទឹកចិត្តយើងឲ្យមានការប្រព្រឹត្តដោយសេចក្ដីជំនឿ នៅក្នុងដំណើរជីវិតរបស់យើងម្នាក់ៗទៀតផង។ ដំណើរសាច់រឿងរបស់លោក អប្រាហាំ ទាំងប៉ុន្មានគឺសុទ្ធតែមានការជាប់ទាក់ទងជាមួយយើងគ្រប់គ្នាអំពីព្រះគុណនៃព្រះជាម្ចាស់ទាំងអស់។ ក្ដីស្រលាញ់ដែលគ្មានលក្ខខណ្ឌរបស់ទ្រង់ គឺមានសម្រាប់អស់អ្នកណារស់នៅក្នុងជីវិតដែលមានទំនាក់ទំនង**

ជាមួយនឹងទ្រង់។ ក្នុងពេលជាមួយគ្នានោះដែល តាមរយៈសាច់រឿងនៃដំណើរជីវិតរបស់លោកអប្រាហាំ ក៏បានរំលឹកយើងឲ្យដឹងអំពីភាពយុត្តិធម៌របស់ទ្រង់ផងដែរ។ ព្រះអង្គប្រព្រឹត្តដោយសេចក្តីមេត្តាករុណាដល់អស់អ្នកដែលបានជឿលើព្រះនាមព្រះអង្គ! ទ្រង់នឹងដាក់ទោសចំពោះអស់អ្នកណាដែលបានប្រព្រឹត្តអំពើបាប ប៉ុន្តែទ្រង់ក៏នៅតែស្តាប់ឮសម្លេងនៃវិញ្ញាណទូលអង្វរសម្រាប់យើងពួកគេដែរ។ សេចក្តីសន្យារបស់ព្រះជាម្ចាស់គឺពិតជាព្រះពរដ៏ពិតរបស់យើង!

## មេរៀនសារឡើងវិញ

# សេចក្ដីសន្យារបស់ព្រះជាម្ចាស់ ព្រះពររបស់យើង

# រំលឹកសារឡើងវិញ

សំនួរទាំងប៉ុន្មានដូចមានខាងក្រោមនេះ គឺត្រូវបានរៀបចំឡើងក្នុងគោលបំណងធ្វើការបញ្ជាក់បន្ថែមអំពីការរីកចម្រើនចំណេះដឹងផ្នែកព្រះគម្ពីរសញ្ញាចាស់ ក្នុងជំពូកណាដែលមានឈ្មោះរបស់លោក អប្រាហាំ និង លោកស្រី សារ៉ា។ ចូរយើងចំណាយពេលវេលាខ្លះដើម្បីរំលឹកសារឡើងវិញទៅតាមជំហាន១ដូចខាងក្រោមនេះ

1. យើងបានអានសាច់រឿងដាច់ដោយឡែកផ្សេងៗពីគ្នា ហើយក៏ បានកត់ត្រាចំណាំពីអង្គហេតុនៃសាច់រឿងទៀតផង ដោយបានភ្ជាប់ជាមួយនូវព្រឹត្តិការណ៍។ ចាប់ពីមេរៀនទី ៣ ដល់ទី ៦ តើសាច់រឿងទាំងបួនដែលយើងបានសិក្សារួចមកនោះមានអ្វីខ្លះ?
   ក. មេរៀនទី ៣ ________________________________________
   ខ. មេរៀនទី ៤ ________________________________________
   គ. មេរៀនទី ៥ ________________________________________
   ឃ. មេរៀនទី ៦ ________________________________________
2. យើងបានសិក្សាអំពីភាពខុសគ្នាជាច្រើនចំណុចរវាងព្រះជាម្ចាស់ និង មនុស្ស។ តើ មានសេចក្ដីពិតខុសគ្នាយើងដូចម្ដេចខ្លះ តាមរយៈមេរៀនដែលយើងបានសិក្សាកន្លងមកក្នុង ផ្នែកមួយមានចំណងជើងថា "តើយើងបានរៀនអ្វីខ្លះអំពីព្រះជាម្ចាស់?"
   ក. មេរៀនទី ៣ ________________________________________
   ខ. មេរៀនទី ៤ ________________________________________
   គ. មេរៀនទី ៥ ________________________________________
   ឃ. មេរៀនទី ៦ ________________________________________
3. យើងបានស្វែងរកមធ្យោបាយ ដើម្បីអនុវត្តមេរៀននៃសាច់រឿងនានាដែលបានកើតឡើងតាំងពីយូរលង់ណាស់មកហើយ យើងស្វែងរកអត្ថន័យ និង ការអនុវត្តន៍ផ្ទាល់ខ្លួនសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់យើងពួកយើងម្នាក់ៗ។ តើមានការអនុវត្តន៍យ៉ាងដូចម្ដេចខ្លះដែលយើងបានសិក្សាក្នុងផ្នែកនិមួយៗនាពេលកន្លងមក?
   ក. មេរៀនទី ៣ ________________________________________
   ខ. មេរៀនទី ៤ ________________________________________
   គ. មេរៀនទី ៥ ________________________________________
   ឃ. មេរៀនទី ៦ ________________________________________

4. នៅទីបញ្ចប់យើងបានសិក្សានៅកំណ្ឌគម្ពីរហេព្រើរជំពូក ១១! នៅក្នុងជំពូកនេះ គឺមានសាច់រឿងជាច្រើនដែលបានកត់ត្រាទុកជាការបើកសម្ដែងអំពីសេចក្ដីជំនឿរបស់លោកអប្រាហាំ។ យើងបានសិក្សាដោយការប្រើប្រាស់ខយោង ដើម្បីធ្វើឲ្យយើងអាចដៅកន្លែងបានយ៉ាងឆាប់រហ័សអំពីភាពប្រទាក់គ្នាពីព្រះគម្ពីរសញ្ញាចាស់ ទៅនឹងអំណះអំណាងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយកន្លងមកយើងក៏ធ្លាប់បានដៅកន្លែងបញ្ច្រាសពីសញ្ញាថ្មីទៅសញ្ញាចាស់វិញដែរ។ បើសិនជាលោកអ្នកពិតជាចង់សិក្សាអំពីបទគម្ពីរហេព្រើរជំពូក ១១ ហើយចង់ធ្វើការរំលឹងសារឡើងវិញនូវសាច់រឿងទាំងនេះ ប៉ុន្តែលោកអ្នកមិនដឹងថាសាច់រឿងទាំងនោះមាននៅក្នុងកំណ្ឌគម្ពីរណា ជំពូកណា ឥឡូវនេះលោកអ្នកមានខយោង ទុកជាជំនួយមួយយ៉ាងប្រសើរបំផុងសម្រាប់លោកអ្នក!

## នៅចុងបញ្ចប់នៃមេរៀន សេចក្ដីសន្យារបស់ព្រះជាម្ចាស់ ព្រះពររបស់យើង:

លោកអ្នកត្រូវបានលើកទឹកចិត្តឲ្យធ្វើការបង្ហាញនូវអ្វីដែលលោកអ្នកបានសិក្សាថាតើ សិក្សាបានកម្រិតណា។ លោកអ្នកអាចស្វែងរកឃើញបានដោយងាយបំផុតតាមរយៈព្រះគម្ពីរ! លោកអ្នកកំពុងអភិវឌ្ឍន៏កម្រិតនៃការកំសាន្តចិត្តមួយ ក្នុងខណៈពេលលោកអ្នកកំពុងបន្តការសិក្សាអំពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកអ្នក។

**សេចក្ដីអធិស្ឋាន:** ឱព្រះអម្ចាស់អើយ! ទូលបង្គំសូមអរព្រះគុណទ្រង់ចំពោះព្រះបន្ទូលទ្រង់ដែលបានប្រាប់ដល់ទូលបង្គំអំពីសេចក្ដីជំនឿរបស់បុរសម្នាក់គឺលោក អប្រាហាំ។ ទោះបីជាគាត់មិនធ្លាប់មានបទពិសោធន៏អំពីសេចក្ដីសន្យារបស់ទ្រង់ទាំងអស់ក៏ដោយ តែព្រះអង្គបានធ្វើឲ្យគាត់បានឃើញដោយភ្នែករបស់គាត់អំពីសេចក្ដីជំនឿទៅថ្ងៃអនាគត។ សូមព្រះអង្គប្រទាននូវសេចក្ដីជំនឿបែបនេះមកទូលបង្គំផង ដើម្បីឲ្យទូលបង្គំបានកាន់តែជឿជាក់ថាព្រះអង្គគឺពិតជាព្រះប្រកបដោយព្រះគុណ និង សេចក្ដីមេត្តាករុណាប្រាកដមែន ឲ្យទូលបង្គំបានកាន់តែជឿជាក់ថាព្រះអម្ចាស់យេស៊ូវគឺជាសេចក្ដីសង្ឃឹមរបស់ទូលបង្គំ! ហើយសូមទ្រង់ប្រទានកែវភ្នែកនៃសេចក្ដីជំនឿ ដើម្បីឲ្យទូលបង្គំបានដឹងថា ទូលបង្គំមានសេចក្ដីសន្យាថានឹងមានជីវិតអស់កល្បជាមួយនឹងព្រះអង្គនៅឯនរគស្ថានសួគ៌។ ____________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

មានបទគម្ពីរយោងបន្ថែមជាច្រើនទៀតដែលលោកអ្នកអាចទាញយក
បានដោយឥតគិតថ្លៃ
សូមចូលទៅកាន់គេហទំព័រ www.crosscm.org
សង្ឃឹមថានឹងបានទទួលដំណឹងពីអស់លោកអ្នកបងប្អូនទាំងអស់គ្នា!
ទំនាក់ទំនងមកយើងខ្ញុំតាមរយៈ admin@crosscm.org